សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal university of Law and Economics


## សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងរដ្ឋបាលស្រុកមេមត់ ចាប់ពីឆ្នាំ ២០១៨-២០២៣

ចាប់ស្រាវជ្រាវពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **កញ្ញា ញ៉ូ ចន្ធូ**

**លោក ជា វីសិទ្ធ**

ណែនាំដោយគ្រូ

**បណ្ឌិត ឌី ពុទ្ធារ៉ា**


ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី១៧

ឆ្នាំចូលរៀន ២០២០

ឆ្នាំសរសេរសារណា ២០២៤

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងរដ្ឋបាលស្រុកមេមត់ ចាប់ពីឆ្នាំ ២០១៨-២០២៣

ចាប់ស្រាវជ្រាវពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **កញ្ញា ញ៉ូ ចន្ធូ**

**លោក ជា វីសិទ្ធ**

ណែនាំដោយ

**បណ្ឌិត ឌី ពុទ្ធារ៉ា**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី១៧

ឆ្នាំចូលរៀន ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

ជាបឋមខ្ញុំបាទឈ្មោះ **ជា ទីសិទ្ធ** និងនាងខ្ញុំឈ្មោះ **ញ៉ វ ចន្ធូ** ជានិស្សិតថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈក្រុម P4A02 ឆ្នាំសិក្សា ២០២១-២០២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ខ្ញុំបាទឈ្មោះ **ជា ទីសិទ្ធ** សូមសម្តែងការគោរពដឹងគុណដ៏ជ្រាលជ្រៅចំពោះ លោកឪពុក និង អ្នកម្តាយ ដែលបានផ្តល់នូវកំណើត និងចិញ្ចឹមបីបាច់ថែរក្សារូបកូន ទាំងកាយវាចា ចំណេះជំនាញ ស្មារតី និងសម្ភារៈ ថវិកា។ ជាពិសេសបានផ្តល់នូវការទូន្មានប្រៀនប្រដៅល្អៗប្រកបដោយព្រហ្មវិហារធម៌ដល់រូបកូន ចាប់តាំងពីពេលរូបកូននៅកុមាររហូតដល់ធំដឹងក្តី និង អ្វីដែលកូនមិនអាចបំភ្លេចបានគឺការទទួលបាននូវការទំនុកបម្រុងរបស់លោកឪពុក និង អ្នកម្តាយដល់រូបកូនបានទទួលនូវការបណ្តុះបណ្តាលចាប់តាំងពីថ្នាក់បឋមរហូតដល់ថ្នាក់ឧត្តមសិក្សានឹងបានធ្វើការបញ្ចប់ថ្នាក់បរិញ្ញាបត្រ រដ្ឋបាលសាធារណៈ ទាំងស្រុងដោយជោគជ័យ និងទទួលបាននូវលទ្ធផលជាទីគាប់ចិត្ត។

នាងខ្ញុំឈ្មោះ **ញ៉ វ ចន្ធូ** ជានិស្សិតថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈឆ្នាំទី៤ជំនាញរដ្ឋបាលសាធារណៈជំនាន់ទី១៧នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ចសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ **អ្នកម្តាយ ទិន សូរី** ជាទីគោរព និងសូមឧទ្ទិសដល់វិញ្ញាណខ័ន្ធ **លោកឪពុក សឿន ឌុទ្ធី** ដែលបានផ្តល់កំណើតដល់រូបកូន ចិញ្ចឹមបីបាច់ថែរក្សាយ៉ាងកក់ក្តៅតាំងពីកូននៅតូច រហូតដល់កូនធំ។ ជាពិសេសលោកទាំងពីរបានចិញ្ចឹមរូបកូនប្រកបដោយព្រហ្មវិហារធម៌ព្រមទាំងទូន្មានប្រៀនប្រដៅនិងទំនុកបម្រុងកូនគ្រប់បែបយ៉ាងមិនឱ្យរូបកូនខ្វះខាតតាំងពីថ្នាក់បឋមសិក្សារហូតដល់បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ។ ដោយសារតែទទួលបានការលើកទឹកចិត្តនិងភាពកក់ក្តៅរបស់លោកទាំងពីរដែលជាកម្លាំងចិត្តដ៏មហិមារទើបនាងខ្ញុំអាចក្លាយជានិស្សិតមួយរូបដែលបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រព្រមទាំងក្លាយជាធនធានដ៏ល្អសម្រាប់សង្គមជាតិ។

ក្រុមយើងខ្ញុំទាំងពីរសូមថ្លែងអំណរគុណ **ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ** គ្រប់រូប នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានយកចិត្តទុកដាក់ផ្តល់នូវការ ដំបូន្មាន និងការយកចិត្តទុកដាក់យ៉ាងខ្ពង់ខ្ពស់ ចំពោះការសិក្សារបស់និស្សិតទាំងអស់ លោកតែងតែដាស់តឿន ទូន្មាន អប់រំសិស្សនិស្សិតទាំងឡាយឱ្យខិតខំរៀនសូត្រស្វែងរកចំណេះវិជ្ជាដាក់ខ្លួន និងហ្វឹកហាត់ខ្លួនឯងធ្វើយ៉ាងណាឱ្យកាន់តែរឹងមាំឡើង និង ពោរពេញទៅ ដោយសមត្ថភាពដើម្បីក្លាយជាមនុស្សល្អដែលតម្រូវការក្នុងសង្គម។ លោកគ្រូ អ្នកគ្រូ

សាស្ត្រាចារ្យ តែងតែបង្ហាត់ បង្រៀនពីការសិក្សាស្រាវជ្រាវ រិះរកបកគំហើញថ្មីៗ បន្ថែមដើម្បីផ្ទេរនូវពុទ្ធិ និងបទពិសោធន៍ល្អៗដល់សិស្សនិស្សិតគ្រប់រូប។ ជាពិសេស លោកគ្រូ **បណ្ឌិត ឌី ពុទ្ធារ៉ា** ដែលបានចំណាយពេលវេលាក្នុងការណែនាំ និងបានផ្តល់នូវដំបូន្មានល្អៗត្រួតពិនិត្យរួមទាំងកែសម្រួលនូវចំណុចខ្វះខាតទៅលើការសរសេរសារណាបញ្ចប់ការសិក្សារបស់ពួកយើងយ៉ាងយកចិត្តទុកដាក់។

ជាពិសេសយើងខ្ញុំទាំងពីសូមថ្លែងអំណរគុណយ៉ាងជ្រាជ្រៅដល់ លោក **ញឹក នៅ** អភិបាលរងស្រុកមេមត់ និង **លោកស្រី ជីន ម៉ុនថាច** ប្រធានការិយាល័យផែនការ និងគាំទ្រឃុំ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ និងបានសម្របសម្រួលផ្តល់ឱកាសឱ្យយើងខ្ញុំទាំងពីរធ្វើការស្រាវជ្រាវ និងប្រមូលឯកសារដែលពាក់ព័ន្ធនឹងការសរសេរសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំ។

ជាចុងក្រោយយើងខ្ញុំទាំងពីរនាក់ពិតជាមិនអាចបំភ្លេចនូវគុណូបការៈនេះបានឡើយហើយសូមប្រសិទ្ធពរជ័យជូន **លោកឪពុកអ្នកម្តាយ ឯកឧត្តម លោក លោកស្រី** ឱ្យមានសុខភាពល្អជាពិសេសទទួលបាននូវជោគជ័យគ្រប់ ភារកិច្ច ហើយសូមឱ្យជួបតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ជាកិច្ចចាប់ផ្ដើមមុននឹងឈានដល់ការបកស្រាយនៃប្រធានបទខាងលើនេះ យើងខ្ញុំ **ខា ទីសិទ្ធ** និង **ភញ្ញា ញ៉ៅ ចន្ទ** សូមគោរព និងស្វាគមន៍ដល់ បណ្ឌិត សាស្ត្រាចារ្យ លោកគ្រូអ្នកគ្រូ សិស្សនិស្សិត និងមិត្តអ្នកអានទាំងអស់ជាទីគោរពរាប់អាន។

បន្ទាប់ពីការសិក្សាអស់រយៈពេលបួនឆ្នាំ នៃជំនាញរដ្ឋបាលសាធារណៈនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច យើងខ្ញុំទាំងពីរធ្វើកិច្ចការសារណានេះឡើងក្នុងគោលបំណងស្វែងយល់ និង ស្រាវជ្រាវឱ្យកាន់តែស៊ីជម្រៅអំពីដំណើរការនៃការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ បញ្ហាប្រឈមផ្សេងៗនៃការគ្រប់គ្រងរដ្ឋបាលរដ្ឋស្រុកដូចជា បញ្ហាធនធានមនុស្ស បញ្ហាហិរញ្ញវត្ថុ ថវិកាគាំទ្រស្រុក ឃុំ សេដ្ឋកិច្ច សន្តិសុខសណ្ដាប់ធ្នាប់សាធារណៈជាដើម។ ក្នុងគោលដៅសម្រេចឱ្យបាននូវការបញ្ចប់ការសិក្សាទាំងផ្នែកទ្រឹស្ដី និងការចុះស្រាវជ្រាវដោយផ្ទាល់ បន្ថែមពីនេះចូលរួមចំណែកក្នុងការកែលម្អ និងស្វែងរកចំណុចខ្វះខាតក្នុងស្មារតីទទួលបាននូវប្រសិទ្ធិភាព និងជាពិសេសលើកកម្ពស់ប្រជា ធិបតេយ្យនៅមូលដ្ឋាន ដែលជាចំណែកសំខាន់ក្នុងការអភិវឌ្ឍប្រទេសឱ្យមានការរីកចម្រើនលើគ្រប់វិស័យ និងប្រកបដោយចីរភាព។

កិច្ចការសារណានេះពិតជាមានសារៈសំខាន់ណាស់ក្នុងការបម្រើឱ្យការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗធ្វើការស្រាវជ្រាវបន្តជាពិសេសនិស្សិតផ្នែករដ្ឋបាលសាធារណៈដែលចង់ដឹង និង ស្វែងយល់បន្ថែមអំពីប្រធានបទ ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ។ យើងខ្ញុំបានធ្វើការចងក្រងនូវសារណានេះឡើងពិតជាមាន សេចក្ដីសោមនស្សរីករាយយ៉ាងក្រៃលែងក្នុងការចំណាយពេលវេលាផ្ទាល់ខ្លួនចងក្រងទុកជាឯកសារស្នាដៃដែលបានសិក្សាអស់រយៈពេល៤ឆ្នាំ ជាពិសេសកម្លាំងកាយព្រមទាំងកម្លាំងចិត្ត និងធនធានផ្ទាល់ខ្លួនដើម្បីចងក្រងនូវកិច្ចការសារណានេះឱ្យបានពេញលេញចេញជារូបរាងឡើង។

ជាកិច្ចបញ្ចប់យើងខ្ញុំសូមអភ័យទោសដល់ បណ្ឌិត សាស្ត្រាចារ្យ លោកគ្រូអ្នកគ្រូ និង សិស្ស និស្សិត រាល់កង្វះខាត និង ពាក្យពេចន៍មិនសមរម្យទាំងឡាយណានៅក្នុងកិច្ចការសារណាមួយនេះ។ យើងខ្ញុំនឹងទទួលពាក្យរិះគន់ដើម្បីស្ថាបនាពីសំណាក់មិត្តអ្នកអានទាំងអស់គ្រប់វិនាទី។ យើងខ្ញុំសូមគោរពជូនពរដល់ បណ្ឌិត សាស្ត្រាចារ្យ លោកគ្រូអ្នកគ្រូ និង សិស្សនិស្សិត ឱ្យជួបប្រទះតែសេចក្ដីសុខដុមរមនារុងរឿងកុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

**សេចក្តីផ្តើម** ........................................................................................................ ១

## ជំពូកទី១

## ស្ថានភាពទូទៅនៃការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ

**១.១. ប្រវត្តិនៃការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា** .................................. ៥
១.១.១. ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិមុនឆ្នាំ១៩០៨ ........................................ ៥
១.១.២. ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ១៩០៨ ដល់ឆ្នាំ១៩៥៥ .......................... ៥
១.១.៣. ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៧៩ .......................... ៦
១.១.៤. ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិចាប់ពីឆ្នាំ១៩៧៤ ដល់ឆ្នាំ១៩៩៣ ................ ៧
១.១.៥. ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិក្រោយឆ្នាំ១៩៩៣ .................................. ៨
**១.២. ការរៀបចំរដ្ឋបាលថ្នាក់ក្រោមជាតិ** ....................................................... ៩
**១.៣. រចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ** .................................................... ១១
**១.៤. ទិដ្ឋភាពទូទៅនៃការគ្រប់គ្រងរដ្ឋបាល** ..................................................... ១១
១.៤.១. ប្រព័ន្ធគ្រប់គ្រងបែបមជ្ឈការ ............................................................ ១២
១.៤.២. ប្រព័ន្ធគ្រប់គ្រងតាមបែបវិសហមជ្ឈការ ................................................. ១២
១.៤.៣. ប្រព័ន្ធគ្រប់គ្រងបែបវិមជ្ឈការ ........................................................... ១២
**១.៥. ក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ** ................................................ ១៣
**១.៦. អង្គប្រតិបត្តិនៃរដ្ឋបាលថ្នាក់ក្រោមជាតិ** .................................................. ១៣
១.៦.១. មេឃុំ និងចៅសង្កាត់ ..................................................................... ១៥
១.៦.២. គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ......................................... ១៦
**១.៧. ទំនាក់ទំនងអន្តររដ្ឋបាល** ..................................................................... ១៦

១.៧.១. ទំនាក់ទំនងរវាងក្រុមប្រឹក្សាស្រុក និង គណៈអភិបាលស្រុក ..........១៦
១.៧.២. ទំនាក់ទំនងរវាងរដ្ឋបាលស្រុកជាមួយក្រសួង ស្ថាប័ន ..........១៨
១.៧.៣. ទំនាក់ទំនងរវាងរដ្ឋបាលស្រុកជាមួយរដ្ឋបាលខេត្ត ..........១៩
១.៧.៤. ទំនាក់ទំនងរវាងរដ្ឋបាលស្រុកជាមួយរដ្ឋបាលឃុំ សង្កាត់ ..........២០
**១.៨. មុខងាររបស់រដ្ឋបាលស្រុក** ..........២១
**១.៩. ហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ** ..........២២

## ជំពូកទី២

## ស្ថានភាពទូទៅនៃស្រុកមេមត់

**២.១. ទីតាំងភូមិសាស្ត្រ និងប្រជាជន** ..........២៤
**២.២. ស្ថានភាពសេដ្ឋកិច្ច** ..........២៤
២.២.១. វិស័យកសិកម្ម ..........២៥
២.២.២. វិស័យឧស្សាហកម្ម និង សិប្បកម្ម ..........២៥
២.២.៣. វិស័យគមនាគមន៍ ..........២៦
២.២.៤. វិស័យអាជីវកម្ម ..........២៦
**២.៣. ស្ថានភាពសង្គមកិច្ច** ..........២៧
២.៣.១. វិស័យសុខាភិបាល ..........២៧
២.៣.២. វិស័យអប់រំ ..........២៨
២.៣.៣. ស្ថានភាពយេនឌ័រ ..........៣០
២.៣.៤. ស្ថានភាពនៃភាពក្រីក្រ ..........៣០
២.៣.៥. ស្ថានភាពសាសនា ..........៣១
២.៣.៦. ស្ថានភាពអន្តោប្រវេសន៍ និងការផ្លាស់លំនៅ ..........៣១
២.៣.៧. ស្ថានភាពធនធានធម្មជាតិ បរិស្ថាននិង ការប្រែប្រួលអាកាសធាតុ ..........៣១

២.៣.៧.១. ការងារបរិស្ថាន...............................................................................................៣១

២.៣.៧.២. ការងារគ្រោះមហន្តរាយចម្រុងៗ ..................................................................៣២

២.៣.៧.៣. ការគ្រប់គ្រងធនធានធម្មជាតិ ......................................................................៣២

២.៣.៧.៤. ការប្រើប្រាស់ដីធ្លី..........................................................................................៣៣

**២.៤. ការគ្រប់គ្រងនគរូបនីយកម្ម**.........................................................................................៣៣

២.៤.១. ការងារការរៀបចំដែនដី នគរូបនីយកម្ម.......................................................................៣៣

២.៤.២. ការងារភូមិបាល ...........................................................................................................៣៤

២.៤.៣. ការងារសំណង់ និងលំនៅដ្ឋាន ....................................................................................៣៤

**២.៥. សន្តិសុខ និងការគ្រប់គ្រងសណ្តាប់ធ្នាប់សាធារណៈ** ............................................៣៥

២.៥.១. ស្ថានភាពសន្តិសុខស្រុកមេមត់ .....................................................................................៣៥

២.៥.២. ការបង្ក្រាបបទល្មើសផ្សេងៗ ........................................................................................៣៥

២.៥.៣. ការគ្រប់គ្រងច្រកព្រំដែន និងជនអន្តោប្រវេសន៍..........................................................៣៧

**ជំពូកទី៣**

**ដំណើរការប្រព្រឹត្តទៅនៃការគ្រប់គ្រងរដ្ឋបាលស្រុកមេមត់**

**៣.១. រចនាសម្ព័ន្ធរដ្ឋបាលស្រុកមេមត់ និង អង្គដឹកនាំរដ្ឋបាលស្រុក** ...........................៣៦

**៣.២. តួនាទី និងភារកិច្ច** ..................................................................................................៣៩

៣.២.១. តួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សារដ្ឋបាលស្រុកមេមត់.......................................................៣៩

៣.២.២. តួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់គណៈអភិបាលស្រុកមេមត់...................................៣៩

៣.២.៣. តួនាទី ភាគកិច្ច និងសិទ្ធិអំណាចរបស់នាយករដ្ឋបាល................................................៤១

**៣.៣. ការិយាល័យចំណុះរដ្ឋបាលស្រុកមេមត់**..................................................................៤២

៣.៣.១. ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ ................................................................................៤២

៣.៣.២. ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់.....................................................................៤៣

៣.៣.៣. ការិយាល័យអន្តរវិស័យ ...............................................................................................៤៣

៣.៣.៤. អង្គភាពលទ្ធកម្ម ...............................................................................................................៤៤

៣.៣.៥. ការិយាល័យគ្រប់គ្រងធនធានមនុស្ស.......................................................................................៤៥

៣.៣.៦. ការកសាងសមត្ថភាព ...........................................................................................................៤៦

**៣.៤. ការធ្វើផែនការ និងការគាំទ្រឃុំ**...............................................................................................៤៧

៣.៤.១. ការធ្វើផែនអភិវឌ្ឍន៍ប្រាំឆ្នាំ...................................................................................................៤៧

៣.៤.២.គោលដៅ និង គោលបំណងក្នុងការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច .............................................................៤៧

៣.៤.៣. គោលដៅ និងគោលបំណងអភិវឌ្ឍន៍ ផ្នែកសង្គមកិច្ច..................................................................៤៨

៣.៤.៤. គោលបំណងអភិវឌ្ឍន៍ ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់....................................................៥០

៣.៤.៥. យុទ្ធសាស្ត្រក្នុងការអភិវឌ្ឍ ....................................................................................................៥២

៣.៤.៦. កម្មវិធីវិនិយោគបីឆ្នាំរំកិល.....................................................................................................៥៥

៣.៤.៧. ការរៀបចំផែនការគម្រោង.....................................................................................................៥៥

៣.៤.៨. ការអនុវត្តផែនការគម្រោង.....................................................................................................៥៧

៣.៤.៩. ការគាំទ្រឃុំ សង្កាត់.............................................................................................................៥៨

៣.៤.១០. ការងារលទ្ធកម្ម.................................................................................................................៥៩

**៣.៥. ហិរញ្ញវត្ថុរដ្ឋបាលស្រុកមេមត់**....................................................................................................៦០

៣.៥.១. ការអនុវត្តចំណូល និងចំណាយ................................................................................................៦០

៣.៥.២. ការគ្រប់គ្រងទ្រព្យសម្បត្តិ.......................................................................................................៦០

**៣.៦.ការងាររដ្ឋបាល**.......................................................................................................................៦១

៣.៦.១. ការគ្រប់គ្រងអត្រានុកូលដ្ឋាន..................................................................................................៦១

៣.៦.២. ការចេញលិខិតស្នាម និងឯកសារប្រជាពលរដ្ឋ...........................................................................៦២

៣.៦.៣. ការគ្រប់គ្រងប្រជាពលរដ្ឋ ......................................................................................................៦២

៣.៦.៤. ការផ្សព្វផ្សាយ ព័ត៌មាន ទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ................៦៣
៣.៦.៥. ការងារគណៈអភិបាល..........................................................................................៦៤
៣.៦.៦. ការងារក្រុមប្រឹក្សា និងគណៈកម្មាធិការនានា.............................................................៦៧
៣.៦.៧. ការរៀបចំវេទិកា.................................................................................................៦៨
**៣.៧. ចក្ខុវិស័យនាពេលអនាគត** ...................................................................................៦៨
**៣.៨. បញ្ហាប្រឈមផ្សេងៗ** ...........................................................................................៦៩
**សេចក្ដីសន្និដ្ឋាន** .........................................................................................................៦៦
**អនុសាសន៍** .................................................................................................................៦៧
**ឯកសារយោង**
**បញ្ជីឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ការគ្រប់គ្រងរដ្ឋបាលគឺជាផ្នែកមួយដ៏សំខាន់បំផុតក្នុងការគ្រប់គ្រង និងអភិវឌ្ឍនៅក្នុង អង្គភាព ស្ថាប័ន និងនៅក្នុងប្រទេសទាំងមូលមិនថាប្រទេសអភិវឌ្ឍឬកំពុងអភិវឌ្ឍនោះទេគឺ ត្រូវមានការរៀបចំប្រព័ន្ធរដ្ឋបាល។ ម្យ៉ាងទៀតកម្ពុជាជាប្រទេសដែលបានឆ្លងកាត់ការរៀបចំប្រព័ន្ធគ្រប់គ្រងរដ្ឋបាលជាច្រើនទៅតាមសម័យកាល ដែលជាប្រព័ន្ធគ្រប់គ្រងតាមបែបមជ្ឈការដោយអំណាចទាំងអស់ត្រូវប្រមូលផ្តុំនៅរដ្ឋបាលថ្នាក់ជាតិ ឬរដ្ឋបាលថ្នាក់កណ្តាល។ នៅចុងទសវត្សរ៍ទី៩០រាជរដ្ឋាភិបាលបានគិតគូរផ្ទេរការទទួលខុសត្រូវឱ្យទៅរដ្ឋបាលមូលដ្ឋាន (ថ្នាក់ក្រោមជាតិ)ដើម្បីជួយដល់រដ្ឋាភិបាលអភិវឌ្ឍមូលដ្ឋាន និងផ្តល់សេវាជូនប្រជាពលរដ្ឋទាន់ពេលវេលា។ នៅឆ្នាំ២០០១រដ្ឋាភិបាលកម្ពុជាបានរៀបចំឱ្យមាន ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ និងមានការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់នៅឆ្នាំ២០០២។ ទន្ទឹមនឹងនោះនៅឆ្នាំ២០០៨ក៏មានការលេចឡើងនូវច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

រាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងបានយកចិត្តទុកដាក់រិះរកវិធីសាស្ត្រណាដែលមានប្រសិទ្ធភាពខ្ពស់អាចផ្តល់សេវាជូនប្រជាពលរដ្ឋឱ្យបានឆាប់រហ័សមានភាពងាយស្រួលនិងទាន់ពេលវេលាដូច្នេះទើបរាជរដ្ឋាភិបាលបានសម្រេចចិត្តដាក់ឱ្យអនុវត្តនូវគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការគោលនយោបាយនេះមានគោលដៅអភិវឌ្ឍគ្រឹះលទ្ធិប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាននិងលើកកម្ពស់សិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។ ការរៀបចំរដ្ឋបាលថ្នាក់មូលដ្ឋានឬអាជ្ញាធរដែនដីនៃប្រទេសកម្ពុជាបែងចែកចេញជារាជធានីខេត្តក្រុងស្រុកខណ្ឌឃុំនិងសង្កាត់ការបែងចែកនេះត្រូវបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

បច្ចុប្បន្នព្រះរាជាណាចក្រកម្ពុជាមានរាជធានី ខេត្ត២៥ ស្រុក១៦២ ក្រុង២៨ ខណ្ឌ១៤ ឃុំ១៤០៥ សង្កាត់២៤១។ ខេត្តដែលទើបនឹងបង្កើតថ្មីគឺ ខេត្តត្បូងឃ្មុំដែលជាតំបន់ដែលបំបែកចេញពីខេត្តកំពង់ចាមតាមព្រះរាជក្រឹត្យលេខនស/រកត/១២០៣/១៤៤៥ចុះថ្ងៃទី៣១ធ្នូ២០១៣ និងសម្ពោធឱ្យប្រើប្រាស់នូវសាលាខេត្តត្បូងឃ្មុំនៅថ្ងៃទី០២ មិថុនា ២០១៤។ បន្ថែមពីនេះ ស្រុកមេមត់ជាស្រុកមួយនៅក្នុងចំណោមស្រុកទាំង០៧ នៃខេត្តត្បូងឃ្មុំដែលមានផ្ទៃដី សរុប១៦០,១៣០គីឡូម៉ែត្រការ៉េហើយក៏ជារដ្ឋបាលដែនដីមួយដែលប្រសូត្រចេញពីច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្តក្រុងស្រុកខណ្ឌឃុំសង្កាត់ មានតួនាទីភារកិច្ចមុខងារ និងកាតព្វកិច្ចជាច្រើនដែលត្រូវបំពេញឱ្យបាននៅក្នុងការកសាងអភិវឌ្ឍឱ្យបានសម្រេចចេញជាសមិទ្ធិផលទៅតាមគោលនយោបាយយុទ្ធសាស្ត្រនានារបស់រដ្ឋាភិបាល។ ហេតុដូច្នេះហើយដើម្បីជាត្រីវិស័យក្នុងការការសិក្សាស្វែងយល់

ឱ្យកាន់តែស៊ីជម្រៅ នូវដំណើរការនៃការគ្រប់គ្រងរដ្ឋបាលស្រុកមេមត់យើងខ្ញុំទាំងពីរនាក់បានលើកយកប្រធានបទមួយស្តីពី **ការគ្រប់គ្រងរដ្ឋបាលស្រុកមេមត់ ឆ្នាំ ២០១៨-២០២៣** មកធ្វើការសិក្សា។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

រាជធានីខេត្តក្រុងស្រុកខណ្ឌគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាពដើម្បីបង្កើតជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនយោបាយវិសហមជ្ឈការ និងវិមជ្ឈការដែលជាកំណែទម្រង់មួយដែលមានសារៈសំខាន់ជាទីបំផុតក្នុងការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការប្រើសេវាសាធារណៈ និងការអភិវឌ្ឍជាមូលដ្ឋានប្រកបដោយគុណភាពមានការចូលរួមពីប្រជាពលរដ្ឋកាន់តែទូលំទូលាយនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តនានានៅក្នុងមូលដ្ឋានរបស់ខ្លួន។ ដោយមើលឃើញពីគុណតម្លៃ និងផ្តល់ឱកាសដល់អ្នកសិក្សាស្រាវជ្រាវចង់ស្វែងយល់បន្ថែមឱ្យកាន់តែច្បាស់និងស៊ីជម្រៅជាងនេះទើបប្រធានបទ **ការគ្រប់គ្រងរដ្ឋបាលស្រុកមេមត់ឆ្នាំ២០១៨-២០២៣** មានចំណោទបញ្ហាមួយចំនួនដូចជា៖

- តើដំណើរការនៃការគ្រប់គ្រងរដ្ឋបាលស្រុកមេមត់ប្រព្រឹត្តទៅយ៉ាងដូចម្តេច?
- តើគណៈអភិបាលស្រុកមានវិធីសាស្ត្របែបណាដើម្បីដំណើរការគ្រប់គ្រងឱ្យមានប្រសិទ្ធិភាព និងគុណភាពខ្ពស់?
- តើនៅស្រុកមេមត់បញ្ហាប្រឈមអ្វីខ្លះដែលរាំងស្ទះដល់ការអភិវឌ្ឍន៍របស់រដ្ឋបាលស្រុក?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការសិក្សាស្រាវជ្រាវនេះគឺដើម្បីបង្កើននូវចំណេះដឹងសម្រាប់ក្រុមយើងខ្ញុំដែលបានធ្វើការសិក្សាស្រាវជ្រាវពីការគ្រប់គ្រងរដ្ឋបាលនៅក្នុងស្រុកមេមត់ម្យ៉ាងទៀតវាក៏ជា ឯកសារមួយដើម្បីបន្សល់ទុកឱ្យនិស្សិតជំនាន់ក្រោយងាយស្រួលក្នុងការសិក្សាស្រាវជ្រាវ។ គោលបំណងចម្បងនៃការសិក្សាស្រាវជ្រាវនេះនឹងផ្តោតសំខាន់ទៅលើចំណុចសំខាន់ដូចជា៖

- សិក្សាលើការគ្រប់គ្រងរដ្ឋបាលស្រុក លទ្ធផលបញ្ហាប្រឈមនិងដំណើរការរបស់រដ្ឋបាលស្រុកមេមត់។
- ធ្វើការស្វែងយល់ឱ្យកាន់តែច្បាស់ និងឱ្យកាន់តែស៊ីជម្រៅលើប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ៤. ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ

ទិន្នន័យដែលក្រុមយើងខ្ញុំធ្វើការសិក្សាស្រាវជ្រាវមានដែនកំណត់ត្រឹមឆ្នាំ២០១៨-២០២៣ប៉ុណ្ណោះដែលមានទីតាំងនៅស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ការកំណត់នូវទំហំ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវធ្វើឱ្យយើងមានភាពងាយស្រួលក្នុងការកំណត់វិធីសាស្ត្រនៃការស្រាវជ្រាវ។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

វិធីសាស្ត្រក្នុងការស្រាវជ្រាវលើប្រធានបទនេះក្រុមយើងខ្ញុំបានធ្វើការប្រមូលព័ត៌មានយកមកចងក្រងជាសារណានេះឱ្យបានល្អគឺធ្វើសកម្មភាពស្រាវជ្រាវដូចជា៖

- ការស្នើចុះទៅសុំឯកសារដោយផ្ទាល់ពីសាលាស្រុកមេមត់
- ឯកសារគតិយុត្ត(ច្បាប់ព្រះរាជក្រឹត្យប្រកាសសេចក្តីណែនាំ និងសៀវភៅដែលទាក់ទងនិងការគ្រប់គ្រងរដ្ឋបាលនៅប្រទេសកម្ពុជា)
- ឯកសារដែលយើងខ្ញុំធ្លាប់បានសិក្សាពីមុនៗមក
- ឯកសារដែលក្រុមយើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវលើប្រព័ន្ធInternetឬតាមគេហទំព័រណាមួយដើម្បីបានឯកសាបន្ថែមសម្រាប់ធ្វើឱ្យប្រធានបទកាន់តែមានន័យ។

## ៦.សារៈសំខាន់នៃការស្រាវជ្រាវ

តាមរយៈការសិក្សាស្រាវជ្រាវសារណាទៅលើប្រធានបទ **ការគ្រប់គ្រងរដ្ឋបាលស្រុកមេមត់ឆ្នាំ ២០១៨-២០២៣** នេះក្រុមរបស់យើងខ្ញុំបានទទួលនូវចំណេះដឹងទាក់ទងនឹងការគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ស្រុក និងទទួលបានបទពិសោធន៍ពីដំណើរការចុះទៅសុំឯកសារពីស្រុកដោយផ្ទាល់។ រីឯសារៈសំខាន់នៃប្រធានបទខាងលើមានដូចជា៖

- សារៈសំខាន់ចំពោះរដ្ឋបាលស្រុក ដើម្បីផ្តល់នូវចំណុចខ្វះខាតដែលស្រុកគួរកែលម្អ និងបន្តនូវកិច្ចអភិវឌ្ឍស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល
- ដើម្បីបង្កើនសមត្ថភាពឱ្យបានសមស្របសម្រាប់តម្រូវការសង្គម
- ដើម្បីកាត់បន្ថយភាពខ្វះខាតមួយចំនួនដែលពាក់ព័ន្ធនិងការគ្រប់គ្រងរដ្ឋបាលមូលដ្ឋាន
- ដើម្បីទទួលបានបទពិសោធន៍ថ្មីៗដោយភ្ជាប់ជាមួយទ្រឹស្តីនិងការអនុវត្ត និងដើម្បីបានបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែករដ្ឋបាលសាធារណៈដោយជោគជ័យ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ចំពោះរចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវរបស់ក្រុមយើងខ្ញុំលើប្រធានបទ ការគ្រប់គ្រងរដ្ឋបាលស្រុកមេមត់ ឆ្នាំ២០១៨-២០២៣ ក្រុមយើងខ្ញុំបានបែកចែកចេញជា៣ជំពូកមានដូចខាងជា ផ្នែកទី១ សេចក្តីផ្តើម ជំពូកទី១ ស្ថានភាពទូទៅនៃការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ និងផ្នែនទី២ ជំពូកទី២ ស្ថានភាពទូទៅនៃ

ស្រុកមេមត់ និងផ្នែកទី៣ ជំពូកទី៣ ដំណើរការប្រព្រឹត្តទៅនៃការគ្រប់គ្រងរដ្ឋបាលស្រុកមេមត់ សេចក្តីសន្និដ្ឋាន ឯកសារយោង អនុសាសន៍ និងឧបសម្ព័ន្ធ។

# ជំពូកទី១

# ស្ថានភាពទូទៅនៃការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ

# ជំពូកទី១

# ស្ថានភាពទូទៅនៃការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ

## ១.១. ប្រវត្តិនៃការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា

ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជាបានឆ្លងកាត់ការផ្លាស់ប្ដូរសំខាន់ៗជាច្រើនឆ្នាំ ជាពិសេសនៅក្នុងបរិបទនៃកិច្ចខិតខំប្រឹងប្រែងរិមជ្ឈការក្នុងគោលបំណង ពង្រឹងរចនាសម្ព័ន្ធអភិបាលកិច្ចមូលដ្ឋាន និងការកែលម្អការផ្តល់សេវាសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យកាន់តែមានភាពស៊ីចង្វាក់គ្នា និងបង្កើនប្រសិទ្ធភាពខ្ពស់ឱ្យអ្នកប្រើប្រាស់។ ពិសេសឆ្លើយតបទៅនឹងការផ្លាស់ប្តូរនយោបាយ សង្គម និងសេដ្ឋកិច្ចក្នុងប្រទេស។

### ១.១.១. ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិមុនឆ្នាំ១៩០៨

មុនពេលការដាក់អណានិគមពីសំណាក់ប្រទេសបារាំងនៅមុនឆ្នាំ១៩០៨ ប្រទេសកម្ពុជាមានប្រព័ន្ធរដ្ឋបាលដែលមានអំណាចប្រមូលផ្តុំនៅក្នុងដៃព្រះមហាក្សត្រ និងសម្តេចត្រាញ់ដែលជាអ្នកមានមុខមាត់មានកិត្តិយសនៅក្នុងព្រះរាជវាំង។ មានរចនាសម្ព័ន្ធអភិបាលកិច្ចមូលដ្ឋាននៅមានកម្រិតហើយការសម្រេចចិត្តផ្នែករដ្ឋបាលភាគច្រើនត្រូវបានធ្វើឡើងដោយចៅហ្វាយស្រុក ឬអភិបាលដែលត្រូវបានតែងតាំង។ ចៅហ្វាយស្រុកមានអ្នកនៅក្រោមបង្គាប់ដែលជាភ្នាក់ងារប្រតិបត្តិ ដូចជា balat, snàng, kralapéas។[១] អ្នកទាំងនេះស្នាក់នៅ និងធ្វើការជាមួយចៅហ្វាយស្រុក និងជាអ្នកពាំនាំនូវបទបញ្ជារបស់ចៅហ្វាយស្រុកទៅកាន់អ្នកស្រុក។ មេស្រុកត្រូវបានចាត់ទុកជាអ្នកគ្រប់គ្រងភូមិ និងជាអ្នកតំណាងដែលត្រូវបានជ្រើសរើសដោយអភិបាលដើម្បីប្រមូលពន្ធ និងទទួលខុសត្រូវនៅតាមកន្លែងនីមួយៗនៅក្នុងស្រុកឬខេត្តដែលខ្លួនគ្រប់គ្រង។

### ១.១.២. ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ១៩០៨ ដល់ឆ្នាំ១៩៥៥

នៅឆ្នាំ១៩០៨ ដល់ឆ្នាំ១៩៥៥ ប្រទេសកម្ពុជាបានធ្វើការរៀបចំឱ្យមានប្រព័ន្ធគ្រប់គ្រង់រដ្ឋបាលថ្មីមួយដោយបានចាប់ផ្តើមដាក់ឱ្យអនុវត្តនៅក្នុងឆ្នាំ១៩០៨ តាមរយៈការដាក់ឱ្យប្រើនូវក្រឹត្យច្បាប់ស្តីពីការរៀបចំរដ្ឋបាលឃុំដែលបានចូលជាធរមាននៅទី០៥ ខែមិថុនា ឆ្នាំ១៩០៨។ ក្រឹត្យមានគោលបំណងលុបចោលនូវរបៀបគ្រប់គ្រងដែនដីដោយស្តេចត្រាញ់ ហើយបានរៀបចំឱ្យមានប្រព័ន្ធគ្រប់គ្រងតាមឃុំវិញ។ ដោយផ្អែកតាមស្មារតីនៃក្រឹត្យនេះបានចែកទឹកដីនៃប្រទេសកម្ពុជាចែកចេញជា ខេត្ត ស្រុក ឃុំ និងភូមិ។ ម្យ៉ាងទៀត ក្រឹត្យនេះតាមរយៈការរៀបចំថ្មី អភិបាលដែលពីមុនហៅថា **ចៅហ្វាយស្រុក** បានក្លាយទៅជា **ចៅហ្វាយខេត្ត** ហើយ **មេស្រុក** បានក្លាយជា

---

[១]សៀវភៅ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា, សម្តេចក្រឡាហោម ស ខេង, បោះពុម្ពឆ្នាំ២០១៨ ទំព័រទី៤

**មេឃុំ**។ ដោយផ្អែកតាមក្រឹត្យនេះបានតម្រូវឱ្យមេឃុំត្រូវធ្វើការបោះឆ្នោតជ្រើសរើសដោយផ្ទាល់ពី ប្រជាជននៅក្នុងឃុំដើម្បីបំពេញតួនាទីនៅក្នុងឃុំតាមរយៈមុខងារ និងធនធានដែលផ្តល់ឱ្យដោយក្រឹត្យ។ ក្រឹត្យច្បាប់ការគ្រប់គ្រងឃុំឆ្នាំ១៩០៨ នេះត្រូវបានកែសម្រួលឡើងវិញចំនួនពីរលើក ដោយលើកទីមួយនៅឆ្នាំ១៩១៩ និងលើកទីពីរនៅឆ្នាំ១៩២៥ និងបានចូលជាធរមាននៅថ្ងៃ០១ ខែមករា ឆ្នាំ១៩២៦ ដោយបានបញ្ជាក់កាន់តែច្បាស់អំពីការជ្រើសរើសក្រុមប្រឹក្សាឃុំ មេឃុំ ការចូលកាន់ដំណែង ប្រព័ន្ធគ្រប់គ្រង របៀបរបបការងារ ថវិកាជាដើម។ ជាពិសេសគឺការរៀបចំឱ្យមានប្រព័ន្ធរដ្ឋបាលថ្មីដែលបានធ្វើឱ្យឃុំក្លាយជាថ្នាក់រដ្ឋបាលមួយជាក់លាក់ក្នុងប្រព័ន្ធរដ្ឋបាលកម្ពុជាតាមរយៈក្រឹត្យច្បាប់ឆ្នាំ១៩២៦ បានផ្តល់នូវសិទ្ធអំណាច និងធនធានកាន់តែច្រើនដើម្បីអភិវឌ្ឍមូលដ្ឋាន។

### ១.១.៣. ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៧៩

ក្រោយផ្អាកការបោះឆ្នោតនៅថ្នាក់ឃុំទាំងស្រុងដោយសារការប្រឈមមុខទៅនឹងសង្គ្រាមឈ្លានពានក្នុងឆ្នាំ១៩៤៨។ នៅក្នុងឆ្នាំ១៩៥៥ ដោយមានកិច្ចខិតខំប្រឹងប្រែងរាជរដ្ឋាភិបាលសង្គមរាស្ត្រនិយមបានរៀបចំឱ្យមានការបោះឆ្នោតនៅថ្នាក់ឃុំឡើងវិញផងដែរ។ បន្ថែមពីនេះនៅក្នុងឆ្នាំ១៩៥៥ មានសារាចរណែនាំមួយដែលណែនាំឱ្យមានការរៀបចំការបោះឆ្នោតថ្នាក់ឃុំឡើងវិញ ប៉ុន្តែនៅក្នុងកំឡុងពេលនោះការអនុវត្តពុំសូវទទួលបានលទ្ធផលឡើយព្រោះមានលក្ខណៈគ្រាន់តែបង្គ្រប់កិច្ចតាមច្បាប់ប៉ុណ្ណោះដោយសារតែប្រជាពលរដ្ឋពុំសូវសកម្មក្នុងការចូលរួម និងពុំមានជំនឿលើសមត្ថភាពដឹកនាំរបស់មេឃុំ។ បន្ទាប់មកនៅឆ្នាំ១៩៥៩ មានព្រះរាជក្រមមួយទៀតដែលតម្រូវឱ្យមានការបោះឆ្នោតជ្រើសរើសក្រុមជំនុំឃុំហើយបានផ្តល់ឱ្យឃុំនូវឋានៈជានីតិបុគ្គលដូចក្នុងឆ្នាំ១៩២៦។ ក្រុមជំនុំឃុំមានអណត្តិរយៈពេល០៤ឆ្នាំ ផ្អែកតាមក្រមនេះមេឃុំ និងជំទប់ត្រូវជ្រើសរើសពីក្នុងក្រុមជំនុំដែលជាប់ឆ្នោតដោយសំឡេងភាគច្រើន។ ចៅហ្វាយខេត្តជាអ្នកចេញដីកាខេត្តប្រកាសសុពលភាពហើយតែងតាំងមេឃុំ និងក្រុមជំនុំឃុំ។ ទន្ទឹមនេះក្រឹត្យនេះក៏ផ្តល់អំណាចដល់ចៅហ្វាយខេត្តក្នុងការប្រកាសមោឃភាពលិខិតបទដ្ឋានទាំងឡាយរបស់ឃុំដែលមានលក្ខណៈអនីត្យានុកូលភាពផងដែរ។ ប៉ុន្តែមិនដល់រយៈពេលបីខែផង ព្រះរាជក្រមនេះត្រូវបានដាក់ព្យួរតាមរយៈការធ្វើប្រជាមតិនៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៥៩ ហើយមេឃុំចៅសង្កាត់ និង ជំទប់ត្រូវតែងតាំងតាមរយៈដីកាខេត្តតាមសំណើរបស់អភិបាលស្រុក។ បន្ទាប់ពីធ្វើសមាជជាតិលើកទី២០ នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៦៥ ពាក្យសង្កាត់ត្រូវបានចាប់ផ្តើមប្រើប្រាស់សម្រាប់ឃុំនៅក្នុងទីក្រុង។ ក្នុងពេលជាមួយគ្នានោះពាក្យចៅហ្វាយខេត្ត ក្រុង ស្រុក ក៏ត្រូវបានផ្លាស់ប្តូរដោយប្រើជំនួយវិញនូវពាក្យ អភិបាល។

នៅក្នុងរបបសាធារណរដ្ឋខ្មែរឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ ទោះបីរដ្ឋធម្មនុញ្ញព្យាយាមធ្វើវិមជ្ឈការនៅគ្រប់ថ្នាក់រដ្ឋបាលថ្នាក់ក្រោមជាតិក៏ដោយក៏ប៉ុន្តែដោយសារតែសង្គ្រាមស៊ីវិល ការបោះឆ្នោតគ្រប់ថ្នាក់នៅមូលដ្ឋានមិន

អាចដំណើរការបានឡើយហើយមេឃុំនៅតែបន្តតែងតាំងដោយអភិបាលខេត្ត។ ដោយឡែកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) រដ្ឋធម្មនុញ្ញនៃរបបនេះមានតែ២១មាត្រាប៉ុណ្ណោះដែលខ្លឹមសារភាគច្រើនផ្តោតទៅលើអំណាច **យោធា** និង**អង្គការ**។ មាត្រា៩នៃរដ្ឋធម្មនុញ្ញនេះបានបញ្ញត្តអំពីរបបដឹកនាំដែលធ្វើការងារជា **របបសមូហភាពដឹកនាំ និងធ្វើការងារ**។ ប៉ុន្តែក្នុងស្ថានភាពជាក់ស្តែងរបបនេះមិនបានអនុវត្តតាមរដ្ឋធម្មនុញ្ញឬច្បាប់អ្វីទាំងអស់។ ក្នុងរបបនេះរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលសេដ្ឋកិច្ច និងសង្គមត្រូវបានបំផ្លាញចោលទាំងស្រុងហើយប្រជាពលរដ្ឋនៅទូទាំងប្រទេសត្រូវបានជម្លៀសទៅធ្វើស្រែចម្ការនៅតាមតំបន់ជនបទ និងរស់នៅប្រមូលផ្តុំគ្នារបៀបជា **សហករណ៍** ក្រោមការដឹកនាំ និង បញ្ជាផ្តាច់ការពីអង្គការ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានធ្វើឱ្យប្រជាពលរដ្ឋកម្ពុជាបាត់បង់អាយុជីវិតអស់រាប់លាននាក់ក្នុងរយៈពេលតែប្រមាណជាង៣ឆ្នាំប៉ុណ្ណោះ។ អំឡុងពេលជាមួយគ្នានេះរចនាសម្ព័ន្ធប្រព័ន្ធគ្រប់គ្រងប្រទេសត្រូវបានបំផ្លាញចោលទាំងស្រុង។

### ១.១.៤. ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិចាប់ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៣

ក្រោយការដួលរលំរបបខ្មែរក្រហមឆ្នាំ១៩៧៩ ហេដ្ឋារចនាសម្ព័ន្ធ សេដ្ឋកិច្ចលើគ្រប់វិស័យ ជាពិសេសហេដ្ឋារចនាសម្ព័ន្ធផ្នែករដ្ឋបាលត្រូវបានស្តារឡើងវិញពីចំណុចលេខសូន្យ។ នៅចុងឆ្នាំ១៩៧៩ មានក្រសួងស្ថាប័នចំនួន១២ ត្រូវបានបង្កើតឡើង និងមានខេត្តចំនួន១៨ ក្រុង០២ ត្រូវបានរៀបចំ។ នៅក្នុងឆ្នាំ១៩៨១ ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជាបានធ្វើការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដោយមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋចំនួន ៣.៤១៧.៣៣៩នាក់ ប្រមាណ(៩៧.៨២%) បានចេញទៅបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រចំនួន១១៧រូប ក្នុងចំនោមបេក្ខជនឈរឈ្មោះបោះឆ្នោត១៤៨រូប។ រដ្ឋសភាបានបើកសម័យប្រជុំលើកទី១ពីថ្ងៃទី២៤ ដល់ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨១ ដោយបានបោះឆ្នោតជ្រើសតាំងសម្តេច ជា ស៊ីម ជាប្រធានរដ្ឋសភា។

នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៨១ រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាបានចូលជាធរមាន។ រដ្ឋធម្មនុញ្ញឆ្នាំ១៩៨១បានកំណត់ដែនដីរដ្ឋបាលនៅកម្ពុជាដូចខាងក្រោម៖

- ដែនដីនៃប្រទេសកម្ពុជាចែកជាខេត្ត និង ក្រុង។
- ខេត្តចែកជា ស្រុក។ ស្រុកចែកជាឃុំ និង ក្រុងចែកជា សង្កាត់។

ក្រោយមក នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៨៩ រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ត្រូវបានធ្វើវិសោធនកម្មដោយបានកែប្រែឈ្មោះប្រទេសមកជា រដ្ឋកម្ពុជា វិញក្នុងគោលដៅធ្វើការផ្សះផ្សាបង្រួបបង្រួមជាតិពីគ្រប់និន្នាការនយោបាយដើម្បីលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមនៅកម្ពុជាឱ្យសមស្របជាមួយ

នឹងការវិវត្តនៃសភាពការណ៍នយោបាយ សង្គម សេដ្ឋកិច្ចនៅកម្ពុជាក្នុងតំបន់ និងនៅលើពិភពលោកនាពេលនោះ។ រដ្ឋធម្មនុញ្ញឆ្នាំ១៩៨៩បានធ្វើការកែសម្រួលការបែងចែកទឹកដីដូចខាងក្រោម៖

- ដែនដីប្រទេសកម្ពុជាចែកជាខេត្តនិងក្រុង។
- ខេត្តបែងចែកជាទីរួមខេត្តនិងស្រុក។ ទីរួមខេត្តបែងចែកជាសង្កាត់។ ស្រុកបែងចែកជាឃុំ។
- ក្រុងបែងចែកជាខណ្ឌនិងស្រុកជាយក្រុង។ ខណ្ឌបែងចែកជាសង្កាត់។ ស្រុកជាយក្រុងបែងចែកជាឃុំដូចស្រុកចំណុះខេត្ត។

ចំពោះរចនាសម្ព័ន្ធគ្រប់គ្រង និងអាណត្តិការងារនៅតាមដែនដីរដ្ឋបាលនីមួយៗមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងការរៀបចំតាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៨១ ដែរដោយគ្រាន់តែប្តូរឈ្មោះពីគណៈកម្មាធិការប្រជាជនបដិវត្តន៍មកជាគណៈកម្មាធិការប្រជាជនវិញ។

### ១.១.៥. ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិក្រោយឆ្នាំ១៩៩៣

ក្រោយសង្គ្រាមស៊ីវិលបានអូសបន្លាយជាងបីទសវត្សរ៍ ផលប៉ះពាល់ជាច្រើនបានបន្ទច់បង្អាក់ការអភិវឌ្ឍនៅកម្ពុជាលើគ្រប់វិស័យមិនតែប៉ុណ្ណោះទេថែមទាំងបានបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរនូវរចនាសម្ព័ន្ធ ប្រព័ន្ធនយោបាយរដ្ឋបាល សង្គម សេដ្ឋកិច្ច វប្បធម៌ប្រពៃណី ទំនៀមទម្លាប់ជាពិសេសក្នុងរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ដល់ដើម ឆ្នាំ១៩៧៩។ រដ្ឋាភិបាលនៃរដ្ឋកម្ពុជាក្នុងគោលបំណងធ្វើការផ្សះផ្សាបង្រួបបង្រួមជាតិបញ្ចប់សង្គ្រាមស៊ីវិលដ៏រ៉ាំរ៉ៃដើម្បីនាំមកនូវសន្តិភាពការឯកភាពជាតិ ឯកភាពទឹកដី សំដៅធ្វើការកសាងជាតិឡើងវិញលើគ្រប់វិស័យ រដ្ឋាភិបាលនៃរដ្ឋកម្ពុជាបានសម្រេចចិត្តធ្វើការចរចាសម្របសម្រួលជាមួយគ្រប់ភាគីជម្លោះនានាក្នុងសង្គ្រាមស៊ីវិលនៅកម្ពុជារហូតសម្រេចបាន "**កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស**" ស្តីពីដំណោះស្រាយនយោបាយនៅ កម្ពុជានៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១។ ដោយផ្អែកលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសនៅខែឧសភា ឆ្នាំ១៩៩៣ កម្ពុជាបានធ្វើការបោះឆ្នោតដោយផ្ទាល់ជ្រើសរើសតំណាងរាស្ត្រតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សជាលើកដំបូងបន្ទាប់ពីជម្លោះផ្ទៃក្នុង និងសង្គ្រាមស៊ីវិលដែលបានអូសបន្លាយជិត៣ទសវត្សរ៍។ ការបោះឆ្នោតនេះត្រូវបានរៀបចំឡើងក្រោមការចាត់ចែងរបស់អង្គការសហប្រជាជាតិ និងមានការចូលរួមពីគណបក្សនយោបាយចំនួន២០។ ដោយឡែកនៅរដ្ឋបាលថ្នាក់ក្រោមជាតិក៏បានរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងឡើងវិញ ព្រមទាំងធ្វើការបែងចែកមុខតំណែងអភិបាល អភិបាលរងខេត្ត ក្រុង ក្នុងចំណោមគណបក្សនយោបាយក្នុងរាជរដ្ឋាភិបាលចម្រុះដែលក្នុងនោះមានរាជធានីភ្នំពេញ និងខេត្តចំនួន១០ គណបក្សហ្វ៊ុនស៊ិនប៉ិចទទួលមុខតំណែងជាអភិបាល និងខេត្តចំនួន១០ទៀតគណបក្សប្រជាជនកម្ពុជាទទួលមុខតំណែងជាអភិបាល។ ការបែងចែកមុខតំណែងជាអភិបាល និងអភិបាលរងក្នុងចំណោមគណបក្សនយោបាយនៅក្នុង

រាជរដ្ឋាភិបាលចម្រុះនេះត្រូវបានបញ្ចប់នៅចុងអាណត្តិទី២ និងដើមអាណត្តិទី៣ នៃរដ្ឋសភាដោយគណបក្សប្រជាជនកម្ពុជា ជាគណបក្សទទួលបានសំឡេងភាគច្រើននៅក្នុងរដ្ឋសភាបានមុខតំណែងអភិបាលរាជធានីខេត្តទាំងអស់។

ចំពោះថ្នាក់ស្រុក ខណ្ឌ ឃុំ សង្កាត់ ក៏បានធ្វើការកែសម្រួលរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងប៉ុន្តែក្នុងអាណត្តិទី១ និងដើមអាណត្តិទី២នៃរាជរដ្ឋាភិបាលចម្រុះមិនមានការចុះសម្រុងគ្នាក្នុងការសម្របសម្រួលខាងនយោបាយ ដើម្បីបែងចែកអំណាចនៅថ្នាក់រដ្ឋបាលទាំងនេះឡើយ។ តាមរយៈការរៀបចំឡើងវិញនេះ បានធ្វើឱ្យរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលគ្រប់ថ្នាក់នៅថ្នាក់ក្រោមជាតិមានលក្ខណៈជាការគ្រប់គ្រងបែបមជ្ឈការវិញ។ តួនាទី មុខងារ អំណាច ធនធាន ទាំងធនធាន មនុស្ស និងធនធានហិរញ្ញវត្ថុ ដែលបានផ្ដល់យ៉ាងក្រាស់ក្រែលមុនឆ្នាំ១៩៩៣ ធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិជារដ្ឋបាលប្រកបដោយថាមពលគ្រប់វិស័យនៅមូលដ្ឋានត្រូវបានដកហូតមកក្រោមការគ្រប់គ្រងរបស់ថ្នាក់ជាតិតាមប្រព័ន្ធខ្សែបណ្ដោយវិញ។ សាលាខេត្ត សាលាក្រុងត្រូវស្ថិតនៅជាខ្សែបណ្ដោយរបស់ក្រសួងមហាផ្ទៃ។ សាលាស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវបានចាត់ទុកជាសាខា ឬអង្គភាពមួយរបស់សាលាខេត្ត ឬសាលាក្រុងសាមី។

## ១.២. ការរៀបចំរដ្ឋបាលថ្នាក់ក្រោមជាតិ

ផ្អែកតាមច្បាប់ស្ដីច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ធ្វើឱ្យរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ ឃុំ សង្កាត់ និងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានរៀបចំឡើងវិញឱ្យស្របតាមច្បាប់នេះ។ រដ្ឋបាលនីមួយៗបានក្លាយជានីតិបុគ្គលដែលមានក្រុមប្រឹក្សាជាតំណាងកើតឡើងពីការបោះឆ្នោតផ្ទាល់ មិនផ្ទាល់ និងមានឆន្ទានុសិទ្ធិក្នុងការគ្រប់គ្រងចាត់ចែងកិច្ចការផ្សេងៗនៅមូលដ្ឋានរបស់ខ្លួនដើម្បីឆ្លើយតបតាមតម្រូវការរបស់ប្រជាពលរដ្ឋជាពិសេសអភិវឌ្ឍមូលដ្ឋានប្រកបដោយប្រសិទ្ធភាព និរន្តភាព សមធម៌ និងចីរភាព។

ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិបានចែកចេញជាពីរប្រភេទគឺ៖

- ប្រព័ន្ធរដ្ឋបាលខេត្ត ដែលមានចរិតលក្ខណៈជារដ្ឋបាលតំបន់ដែលមានតួនាទីភារកិច្ចអនុវត្តមុខងារជាតំណាងរាជរដ្ឋាភិបាលតំណាងក្រសួងស្ថាប័ននៅថ្នាក់ជាតិក្នុងការគាំទ្រនិងសម្របសម្រួលរដ្ឋបាលមូលដ្ឋានក្នុងដែនដីរបស់ខ្លួនទាំងរដ្ឋបាលទីប្រជុំជន (ក្រុង) និងជនបទ (ស្រុក ឃុំ និងសង្កាត់ក្នុងស្រុក)។ ទន្ទឹមនេះរដ្ឋបាលតំបន់មានតួនាទីភារកិច្ចអនុវត្តមុខងាររបស់ថ្នាក់ជាតិដែលថ្នាក់ជាតិធ្វើប្រតិភូកម្ម ជាពិសេសមុខងារដែលពាក់ព័ន្ធសន្តិសុខសណ្ដាប់ធ្នាប់សាធារណៈ ច្បាប់យុត្តិធម៌សង្គម ឬមុខងារពាក់ព័ន្ធការអភិវឌ្ឍ ការផ្ដល់សេវាសង្គមដែលថ្នាក់ជាតិមិនទាន់ប្រគល់ឱ្យបានពេញលេញ។ ជាងនេះទៅទៀតរដ្ឋ

បាលតំបន់ត្រូវអនុវត្តមុខងារក្នុងការផ្តល់សេវា និងការអភិវឌ្ឍដែលមានផលប៉ះពាល់ក្នុងរដ្ឋបាលខេត្តទាំងមូល ហើយដែលមិនអាចរ៉ាប់រងឬអនុវត្តបានដោយរដ្ឋបាលមូលដ្ឋាន។

- រដ្ឋបាលមូលដ្ឋានជារដ្ឋបាលដែលនៅកៀក ឬនៅជាប់ដោយផ្ទាល់ជាមួយប្រជាពលរដ្ឋដែលមានលទ្ធភាពសមត្ថភាពក្នុងការផ្តល់សេវា និងការអភិវឌ្ឍបានឆាប់រហ័សជាងថ្នាក់ជាតិ។ ចំពោះប្រសិទ្ធភាព និងការឆ្លើយតបលឿនជាងរដ្ឋបាលថ្នាក់ជាតិចំពោះសេចក្តីត្រូវការចាំបាច់របស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។ [២]

តាមរយៈគោលការណ៍នៃការរៀបចំរដ្ឋបាលថ្នាក់ក្រោមជាតិនៃព្រះរាជាណាចក្រកម្ពុជាដោយយោងតាមមាត្រា២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋ  បាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានចែងថា "រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាពដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ"។ មាត្រានេះបានផ្តល់នូវគោលការណ៍សំខាន់០២ ក្នុងការរៀបចំប្រព័ន្ធអភិបាលកិច្ចនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។[៣] ទីមួយគឺ ការរៀបចំរដ្ឋបាលឯកភាព និងទីពីរគឺ ការធានាបាននូវចីរភាពនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ចំពោះការរៀបចំប្រព័ន្ធអភិបាលកិច្ចមូលដ្ឋានឱ្យស្របតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ គឺជាការរៀបចំប្រព័ន្ធអភិបាលកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យមានលក្ខណៈឆ្លើយតបទៅនឹងសមាសធាតុទាំង០៨ នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យដូចដែលបានកំណត់នៅក្នុងមាត្រា១២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងនោះរួម មាន៖

- ភាពជាតំណាងសាធារណៈ
- ស្វ័យភាពរបស់មូលដ្ឋាន
- ការពិគ្រោះយោបល់ និងការចូលរួម
- ការឆ្លើយតប និងគណនេយ្យភាព
- ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជននៅក្នុងមូលដ្ឋាន
- ការលើកស្ទួយសមធម៌
- តម្លាភាព និងសុចរិតភាព
- វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច។

---

[២] សៀវភៅប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា, សម្តេចក្រឡាហោម ស ខេង, បោះពុម្ពឆ្នាំ២០១៨ ទំព័រទី២៧

[៣] ច្បាប់ស្តីពីការគ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខនស/រកម/០៥០៨/០១៧, ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨, មាត្រា២, មាត្រា១២

## ១.៣. រចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ

ដោយយោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងលិខិតបទដ្ឋានអនុវត្តតម្រូវឱ្យក្រុមប្រឹក្សានីមួយៗរៀបចំឱ្យមានអង្គភាពមួយចំនួននៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់ខ្លួនដើម្បីក្រុមប្រឹក្សាអាចបំពេញតួនាទីភារកិច្ចប្រកបដោយប្រសិទ្ធភាព។[៤]

<u>រូបភាព៖ រចនាសម្ព័នរដ្ឋបាលស្រុក</u>




## ១.៤. ទិដ្ឋភាពទូទៅនៃការគ្រប់គ្រងរដ្ឋបាល

ការធ្វើកំណែទម្រង់ការគ្រប់គ្រងវិមជ្ឈការនៅក្នុងប្រព័ន្ធរដ្ឋបាលនៅប្រទេសកម្ពុជាបានចាប់ផ្តើមតាំងពីខែកុម្ភៈ ឆ្នាំ២០០២ គឺចាប់ពីមានការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ដោយផ្ទាល់ជាលើកដំបូងក្នុងប្រវត្តិសាស្ត្រនៅឃុំ សង្កាត់ទាំង១៦២១ នៅទូទាំងប្រទេសដោយផ្អែកតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលប្រកាសឱ្យប្រើប្រាស់ក្នុងឆ្នាំ២០០១។ ក្នុងគោលដៅ និងជាការតាំងចិត្តខ្ពស់របស់រាជរដ្ឋាភិបាល ក្នុងការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងប្រព័ន្ធរដ្ឋបាលនៃប្រទេសកម្ពុជា ដែលបានកំណត់នូវគោលបំណងយ៉ាងច្បាស់លាស់ គឺការពង្រឹង និងការពង្រីកលទ្ធិប្រជាធិតេយ្យនៅមូលដ្ឋាន និងជំរុញការផ្តល់សេវាសាធារណៈតាមបែបឌីជីថល និងកាត់បន្ថយភាពក្រីក្រ។

[៤] សៀវភៅប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា, សម្តេចក្រឡាហោម ស ខេង, បោះពុម្ពឆ្នាំ២០១៨ ទំព័រទី៣២-៣៣

### ១.៤.១. ប្រព័ន្ធគ្រប់គ្រងបែបមជ្ឈការ

ការគ្រប់គ្រងបែបមជ្ឈការជាការគ្រប់គ្រងមួយប្រភេទដែលរដ្ឋបាលកណ្តាលដឹកនាំរដ្ឋបាលដោយផ្ទាល់ (អំណាចប្រមូលផ្តុំ) ដោយសិទ្ធិអំណាច សេចក្តីសម្រេច និងធនធានទាំងអស់ត្រូវបានប្រមូលផ្តុំនៅរដ្ឋបាលថ្នាក់កណ្តាលដែលសមត្ថកិច្ចអនុវត្តនូវតួនាទីភារកិច្ចផ្នែកនយោបាយ ផ្នែករដ្ឋបាល និងផ្នែកបច្ចេកទេសនៅថ្នាក់លើ ឬ នៅរដ្ឋបាលថ្នាក់ជាតិ។ ពោល គឺអំណាចកណ្តាលមានន័យថា ជាអំណាចរដ្ឋបាលរបស់រដ្ឋាភិបាលកាន់កាប់ដោយនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ឬ ប្រធានស្ថាប័ន។ ប្រព័ន្ធមជ្ឈការមានគោលបំណង៣សំខាន់ គឺ ទី១ នីតិបុគ្គលសាធារណៈមានតែរដ្ឋ ទី២ អំណាចសម្រេចសេចក្តី និងបញ្ហាស្ថិតនៅរដ្ឋកណ្តាលទាំងអស់ និង ទី៣ រដ្ឋបាលទាំងអស់ត្រូវរៀបចំតាមឋានានុក្រម។

### ១.៤.២. ប្រព័ន្ធគ្រប់គ្រងតាមបែបវិសហមជ្ឈការ

ដើម្បីកាត់បន្ថយផលអាក្រក់នៃការប្រមូលផ្តុំអំណាចលើរដ្ឋបាលកណ្តាលរដ្ឋជាច្រើននៅលើពិភពលោកបានអនុវត្តរូបមន្តនៃការពង្រាយអំណាចរដ្ឋបាលទៅរដ្ឋបាលថ្នាក់ក្រោមមូលដ្ឋានពោលគឺ ការធ្វើវិសហមជ្ឈការ។ ក្នុងប្រព័ន្ធគ្រប់គ្រងតាមបែបវិសហមជ្ឈការជាបច្ចេកទេសរដ្ឋបាលមួយប្រភេទដែលអាជ្ញាធររដ្ឋបាលកណ្តាលចែករំលែកអំណាច (បែងចែក) កិច្ចការមួយចំនួនទៅឱ្យរដ្ឋបាលមូលដ្ឋានធ្វើការសម្រេចចិត្តដោយខ្លួនឯងតាមរយៈការធ្វើប្រតិភូកម្ម។ ប៉ុន្តែការធ្វើប្រតិភូកម្មនេះមិនមែនមានន័យថាប្រគល់សិទ្ធិដោយស្វ័យភាពទេ។ ផ្ទុយទៅវិញ គឺជាប្រគល់សិទ្ធិឱ្យសម្រេចក្នុងនាមរដ្ឋាភិបាលមានលក្ខណៈច្បាស់លាស់ជាលាយល័ក្ខណ៍អក្សរពីការកំណត់ព្រំដែននៃសិទ្ធិ និងស្ថិតក្រោមការត្រួតពិនិត្យតាមឋានានុក្រមដ៏ហ្មត់ចត់ថែមទៀត។ ប្រតិភូកម្ម គឺជាវិធីសាស្ត្រមួយក្នុងការរំលែក ឬប្រគល់អំណាចមួយចំនួនទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ប្រតិភូកម្មមានពីរ គឺ ប្រតិភូកម្មអំណាច និងប្រតិភូកម្មហត្ថលេខា។ ប្រតិភូកម្មអំណាចជាការរំលែកសមត្ថកិច្ចមួយផ្នែកទៅឱ្យអាជ្ញាធររដ្ឋបាលទាំងឡាយក្នុងឋានានុក្រមរបស់ខ្លួន(ពីអង្គភាពមួយទៅអង្គភាពមួយ)។ ប្រតិភូកម្មហត្ថលេខាជាវិធីសាស្ត្រមួយដែលអាជ្ញាធរនីមួយៗអាចប្រគល់ទៅឱ្យសហការីណាម្នាក់របស់ខ្លួននូវការចុះហត្ថលេខាជួសនូវសេចក្តីសម្រេចខ្លះៗ (ធ្វើពីបុគ្គលមួយទៅបុគ្គលមួយ ឬធ្វើពីអាជ្ញាធរមួយទៅសហការី)។

### ១.៤.៣. ប្រព័ន្ធគ្រប់គ្រងបែបវិមជ្ឈការ

ជាប្រព័ន្ធមួយដែលអាជ្ញាធររដ្ឋបាលកណ្តាលទទួលស្គាល់នូវសិទ្ធិអំណាចក្នុងការសម្រេចរបស់អាជ្ញាធរនៅមូលដ្ឋានដោយមានចែងនៅក្នុងច្បាប់ និងរដ្ឋធម្មនុញ្ញ។ នៅក្នុងការទទួលស្គាល់នូវសិទ្ធិអំណាចរបស់អាជ្ញាធរមូលដ្ឋាននេះគឺជាការផ្ទេរអំណាច និងផ្ទេរការទទួលខុសត្រូវលើកិច្ចការមួយចំនួនឱ្យទៅអាជ្ញាធរមូលដ្ឋានចាត់ចែង ការងារដើម្បីបំរើផលប្រយោជន៍មូលដ្ឋានរបស់ខ្លួនដោយផ្ទាល់។ ប្រព័ន្ធនេះអាជ្ញាធរកើតចេញពីការ

បោះឆ្នោត និងមានគោលបំណងលើកកំពស់ការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ អភិបាលកិច្ចល្អ លើកកម្ពស់គុណភាពជីវភាពរស់នៅ និងជាការផ្តល់ជូនប្រជាពលរដ្ឋនូវឱកាសកាន់តែច្រើនដើម្បីសម្រេចលើជោគវាសនារបស់ខ្លួនឯង។ ម្យ៉ាងទៀតដើម្បីធ្វើឱ្យមានវិមជ្ឈការពិតប្រាកដនោះ ចាំបាច់ត្រូវឱ្យមានស្វ័យភាពនៃអំណាចមូលដ្ឋានចំពោះអំណាចកណ្តាល។ ប៉ុន្តែក៏មិនត្រូវឱ្យមានស្វ័យភាពពេញលេញដែរ ព្រោះវាអាចធ្លាក់ចូលទៅក្នុងសម្ព័ន្ធភាពនិយម ពោលគឺ ការផ្តាច់ខ្លួនដើម្បីទាមទារឯករាជ្យក្នុងមណ្ឌលរបស់ខ្លួន។ ការធ្វើស្វ័យភាពពីអំណាចរដ្ឋបាលកណ្តាលនេះនៅតែអមទៅដោយការត្រួតពិនិត្យខ្លាំង ឬតិចពីរដ្ឋអំណាចកណ្តាលដែលការត្រួតពិនិត្យនេះគេឱ្យឈ្មោះថា ការត្រួតពិនិត្យ អាណាព្យាបាល ដែលប្រែប្រួលទៅតាមស្ថានភាពនៃពេលវេលា។




## ១.៥. ក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ

ក្រុមប្រឹក្សា គឺជាតំណាងប្រជាពលរដ្ឋ និងជាអ្នកធ្វើសេចក្តីសម្រេចនានាក្នុងនាមប្រជាពលរដ្ឋដែលពាក់ព័ន្ធទៅនឹងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍក្នុងមូលដ្ឋានសំដៅដល់ការបម្រើផលប្រយោជន៍ និងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនប្រកបដោយភាពទំនួលខុសត្រូវខ្ពស់ និងការឆ្លើយតបទាន់ពេលវេលា។

ជាគោលការណ៍ច្បាប់ស្តីពី រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវមានក្រុមប្រឹក្សារបស់ខ្លួន ដែលត្រូវបានជ្រើសរើសឡើងតាមការបោះឆ្នោតអសកលស្របតាមនីតិវិធីដែលកំណត់ ដោយច្បាប់ ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលហៅកាត់ថា **ក្រុមប្រឹក្សា**។ ក្រុមប្រឹក្សានេះមានអាណត្តិ៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលក្រុមប្រឹក្សាថ្មីចូលកាន់តំណែង ហើយអាណត្តិនោះត្រូវគិតចាប់ពីថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងផុតកំណត់នៅថ្ងៃបោះឆ្នោតបន្ទាប់។ ក្រុមប្រឹក្សានីមួយៗ ត្រូវមានប្រធានម្នាក់ ដោយប្រធានគឺជាបេក្ខជនដែលស្ថិតនៅលំដាប់លេខរៀងលើគេនៃបញ្ជីបេក្ខជនដែលមានអាសនៈច្រើនជាងគេនៅក្នុងក្រុមប្រឹក្សា។ ក្នុងករណីដែលបញ្ជីបេក្ខជនមានអាសនៈស្មើគ្នានៅក្នុងក្រុមប្រឹក្សា ប្រធានក្រុមប្រឹក្សា ត្រូវជ្រើសរើសយកបេក្ខជនដែលមានលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលមាន

សំឡេងឆ្នោតបានការច្រើនជាងគេ។ ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សានីមួយៗត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្រ្តីក្រសួងមហាផ្ទៃក្នុងរយៈពេលយ៉ាងតិច១២០ថ្ងៃ មុនពេលផុតកំណត់អាណត្តិរបស់ក្រុមប្រឹក្សា។ ក្នុងករណីគ្មានអនុក្រឹត្យចែងអំពីចំនួនសមាជិកក្រុមប្រឹក្សាអាណត្តិបន្ទាប់ទេនោះចំនួនសមាជិកសរុបរបស់ក្រុមប្រឹក្សាសម្រាប់ក្រុមប្រឹក្សានីមួយៗត្រូវយកតាមចំនួនសរុបចុងក្រោយនៃក្រុមប្រឹក្សាអាណត្តិចាស់។ ចំណែកឯការកំណត់ចំនួនសមាជិកក្រុមប្រឹក្សានីមួយៗត្រូវបានកំណត់ដោយផ្អែកតាមកត្តាប្រជាសាស្ត្រ និងកត្តាភូមិសាស្ត្រ[៥]ដូចខាងក្រោម៖

- ក្រុមប្រឹក្សារាជធានីភ្នំពេញ មាចចំនួនសមាជិកមិនលើសពីម្ភៃមួយ ២១រូប
- ក្រុមប្រឹក្សាខេត្ត មានចំនួនសមាជិកពីប្រាំបួន ០៩រូប ដល់ម្ភៃមួយ ២១រូប
- ក្រុមប្រឹក្សាក្រុង មានចំនួនសមាជិកពីប្រាំពីរ ០៧រូប ដល់ដប់ប្រាំ ១៥រូប
- ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ មានចំនួនសមាជិកពីប្រាំពីរ ០៧រូប ដល់ ដប់ប្រាំបួន ១៩រូប។
- ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ មានចំនួនសមាជិកពីប្រាំ ០៥រូប ដល់ ដប់មួយរូប។

ដោយផ្អែកតាមច្បាប់ស្តីការគ្រប់គ្រង់រដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា២៩ ក្រុមប្រឹក្សាមានតួនាទីចាត់ចែងកិច្ចការចាំបាច់នានាដើម្បីសម្រេចនូវគោលបំណងក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យព្រមទាំងដើម្បីបំពេញមុខងារភារកិច្ចដែលបានប្រគល់ និងដែលបានធ្វើប្រតិភូកម្មតាមច្បាប់ ឬស្របតាមច្បាប់នេះ។ ក្រុមប្រឹក្សាអាចធ្វើការអង្កេតលើករណីទាំងឡាយណាដែលខ្លួនយល់ឃើញថាមានសារៈសំខាន់ដល់ប្រជាពលរដ្ឋដែលខ្លួនជាតំណាងព្រមទាំងអាចផ្សព្វផ្សាយលទ្ធផលនៃការធ្វើអង្កេតនោះរួចហើយត្រូវផ្តល់គោលការណ៍ណែនាំអនុវត្តដល់គណៈអភិបាល និងអភិបាល។ រៀងរាល់កិច្ចប្រជុំរបស់ខ្លួន ក្រុមប្រឹក្សា ត្រូវធ្វើសេចក្តីសម្រេច ឬដីកាតាមការចាំបាច់នានាដែលទាក់ទិនទៅនឹង៖

- ការរៀបចំដើម្បីទទួលមុខងារ ភារកិច្ច និងធនធានថ្មី ស្របតាមច្បាប់នេះ
- មុខងារជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សា
- មុខងារជាជម្រើសរបស់ក្រុមប្រឹក្សា
- កម្មវិធីវិនិយោគបី(៣)ឆ្នាំ រំកិលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍរយៈពេលប្រាំ (៥)ឆ្នាំ រួមទាំងសមាសភាគនៃផែនការនោះដែលស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ក្រុមប្រឹក្សារួមគ្នាប្រភេទក្រុមប្រឹក្សាផ្សេងៗទៀត ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា

[៥] ច្បាប់លេខ នស/រកម/០៥០៨/០១៧, ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨, មាត្រា១៧-១៨

- គម្រោងថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម
- បញ្ហាហិរញ្ញវត្ថុផ្សេងទៀត
- ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និង ធនធាន រួមទាំង គណៈកម្មាធិការ អង្គភាព និងបុគ្គលិករបស់ក្រុមប្រឹក្សា
- ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិ
- ដំណើរការពិគ្រោះយោបល់ ជាមួយសាធារណជនក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា និងការផ្សព្វផ្សាយព័ត៌មាននានា ជូនប្រជាពលរដ្ឋ
- កិច្ចការផ្សេងៗទៀត ដែលកំណត់ដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានដែលបានធ្វើឡើងស្របតាមច្បាប់នេះ។

ក្រុមប្រឹក្សា មានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិ។ សិទ្ធិពិសេសមួយទៀតរបស់ក្រុមប្រឹក្សា គឺធ្វើសំណើទៅរាជរដ្ឋាភិបាលក្នុងការដកហូតតំណែងគណៈអភិបាល ឧទាហរណ៍ដូចជា ក្រុមប្រឹក្សាខេត្ត មានសិទ្ធិស្នើដកអភិបាលខេត្ត ឬអភិបាលរងខេត្តជាដើម។ ក្រុមប្រឹក្សាត្រូវបំពេញមុខងារ និងភារកិច្ចដោយធ្វើសេចក្តីសម្រេចនៅក្នុងអង្គប្រជុំក្រុមប្រឹក្សារបស់ខ្លួន និងត្រូវធានាថាសេចក្តីសម្រេចនោះត្រូវបានអនុវត្ត។

ក្រុមប្រឹក្សាអាចប្រើប្រាស់សិទ្ធិអំណាចប្រតិបត្តិរបស់ខ្លួនដោយធ្វើសេចក្តីសម្រេចនៅក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សា។ បន្ថែមពីនេះក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋទាំងអស់អំពីជម្រើសជាអាទិភាពដើម្បីធ្វើសេចក្តីសម្រេចធានាបានការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

## ១.៦. អង្គប្រតិបត្តិនៃរដ្ឋបាលថ្នាក់ក្រោមជាតិ

បើយើងនិយាយពីអង្គប្រតិបត្តិនៅរដ្ឋបាលថ្នាក់ក្រោមជាតិនោះគេចង់សំដៅដល់មន្ត្រីដែលកំពុងបំពេញការងារនៅក្នុងមូលដ្ឋានដូនជា រដ្ឋបាលខេត្ត រដ្ឋបាលស្រុក និងរដ្ឋបាលឃុំជាដើមដែលសុទ្ធសឹងតែជាអ្នកផ្តល់សេវាសាធារណៈយ៉ាងជិតដិតជាមួយប្រជាពលរដ្ឋ។

### ១.៦.១. មេឃុំ និងចៅសង្កាត់

នៅក្នុងប្រទេសកម្ពុជា មេឃុំ និងចៅសង្កាត់មានតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រង និងអភិបាលកិច្ចនៅក្នុងមូលដ្ឋាន។ មុខតំណែងនេះគឺមានសារៈសំខាន់នៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលវិមជ្ឈការនៃប្រទេសកម្ពុជា

ដែលមានបំណងនាំយកសេវាកម្មរបស់រដ្ឋាភិបាល និងការសម្រេចចិត្តប្រកបដោយប្រសិទ្ធភាពខ្ពស់ និងកាន់តែជិតស្និទ្ធជាមួយប្រជាជន។ ភារកិច្ចរបស់ពួកគេរួមមាន ត្រួតពិនិត្យគម្រោងអភិវឌ្ឍន៍មូលដ្ឋាន រក្សាសណ្តាប់ធ្នាប់សាធារណៈ គ្រប់គ្រងធនធានសាធារណៈ និងតស៊ូមតិសម្រាប់តម្រូវការមូលដ្ឋាន និងធានាការអនុវត្តគោលនយោបាយប្រកបដោយប្រសិទ្ធភាព។ មេឃុំ និងចៅសង្កាត់ជានីតិបុគ្គលមានទំនាក់ទំនងរវាងរដ្ឋបាលកណ្តាល និងសហគមន៍មូលដ្ឋាន ដោយធានាថាតម្រូវការ និងកង្វល់របស់ប្រជាពលរដ្ឋត្រូវបានលើកឡើងទៅរដ្ឋបាលថ្នាក់ជាតិ។ បន្ថែមពីនេះដោយយោងតាមច្បាប់ស្តីពីការគ្រប់គ្រងឃុំ សង្កាត់ និងអនុក្រឹត្យ ស្តីពីការផ្ទេរមុខងារ អំណាច តួនាទី និង ភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ឃុំ សង្កាត់ ជានីតិបុគ្គលហើយមានអំណាចដឹកនាំ និងគ្រប់គ្រងឃុំ សង្កាត់ ដោយបានមកពីការបោះឆ្នោតជាទូទៅ ជាសកល ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ ដោយសម្ងាត់ ក្នុងក្របខណ្ឌនៃឃុំ សង្កាត់នីមួយៗ។

### ១.៦.២. គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺជាមន្ត្រីរាជការស៊ីវិលដែលត្រូវបាន តែងតាំងឱ្យទៅបំពេញការងារជាមួយក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។ គណៈអភិបាល រួមមានប្រធានមួយរូបដែលហៅថា អភិបាល និង អភិបាលរងមួយចំនួន។ តាមស្មារតីនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចំនួនគណៈអភិបាលត្រូវបានកំណត់ដូចខាងក្រោម[៦]៖

- គណៈអភិបាលរាជធានីភ្នំពេញមានចំនួនយ៉ាងច្រើន ០៧រូប
- គណៈអភិបាលខេត្តមានចំនួន ០៣ ទៅ ០៧រូប
- គណៈអភិបាលក្រុង ស្រុក ខណ្ឌមានចំនួនពី ០៣ ទៅ ០៥រូប។

ចំពោះចំនួនជាក់ស្តែងនៃគណៈអភិបាលសម្រាប់ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ១.៧. ទំនាក់ទំនងអន្តររដ្ឋបាល

### ១.៧.១. ទំនាក់ទំនងរវាងក្រុមប្រឹក្សាស្រុក និង គណៈអភិបាលស្រុក

ទំនាក់ទំនងរវាងក្រុមប្រឹក្សាស្រុក និងគណៈអភិបាលស្រុក មានដូចខាងក្រោម ៖

[៦] ច្បាប់លេខ នស/រកម/០៥០៨/០១៧, ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨, មាត្រា១៣៩-១៤០

- អំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិទាំងអស់ដែលក្រុមប្រឹក្សាស្រុកបានសម្រេចរួចហើយគណៈអភិបាលស្រុកត្រូវទទួលខុសត្រូវចាត់ចែងអនុវត្តក្នុងនាមក្រុមប្រឹក្សាស្រុករបស់ខ្លួន។ ដូច្នេះគណៈអភិបាលស្រុក គឺជាអ្នកអនុវត្តទាំងសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិរបស់ក្រុមប្រឹក្សាស្រុក
- ក្រុមប្រឹក្សាស្រុកត្រូវតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើកិច្ចការដែលអនុវត្តដោយ គណៈអភិបាលស្រុក ដើម្បីធានាថាគណៈអភិបាលស្រុកអនុវត្តកិច្ចការទាំងនោះបានត្រឹមត្រូវតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងការសម្រេចរបស់ក្រុមប្រឹក្សាស្រុក
- គណៈអភិបាលស្រុកត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សាស្រុករបស់ខ្លួនរៀងរាល់កិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញរបស់ក្រុមប្រឹក្សាស្រុក
- គណៈអភិបាលស្រុកត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សាស្រុករបស់ខ្លួនអំពីការអនុវត្តសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាស្រុក និងមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលអំពីការអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា
- អភិបាលស្រុកដោយមាននាយករដ្ឋបាលសាលាស្រុកជាជំនួយការត្រូវរៀបចំសេចក្តីរាយការណ៍អំពីសកម្មភាព និងលទ្ធផលនៃការអនុវត្តតួនាទីជាតំណាងរាជរដ្ឋាភិបាល និងតំណាងក្រសួង ស្ថាប័ននានា ព្រមទាំងស្ថានភាពនៃការងារទាំងនោះក្នុងរបាយការណ៍ប្រចាំខែត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំដើម្បីរាយការណ៍ជូនក្រុមប្រឹក្សាស្រុករបស់ខ្លួន
- ក្នុងករណីមានបញ្ហាណាមួយដែលពាក់ព័ន្ធដល់ការអនុវត្តតួនាទីរបស់អភិបាលស្រុកក្នុងនាមជាតំណាងរាជរដ្ឋាភិបាល និងតំណាងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ហើយដែលមានការប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋ ឬមានការទាមទារតវ៉ាពីប្រជាពលរដ្ឋ ក្រុមប្រឹក្សាស្រុកអាចតម្រូវឱ្យអភិបាលស្រុកធ្វើសេចក្តីរាយការណ៍ជាពិសេសជូនកិច្ចប្រជុំក្រុមប្រឹក្សាស្រុក
- ក្រុមប្រឹក្សាស្រុកអាចផ្តល់អនុសាសន៍ និងការណែនាំដល់អភិបាលស្រុក អំពីការអនុវត្តតួនាទីខាងលើនេះដើម្បីឆ្លើយតបតម្រូវការជាអាទិភាព និងបញ្ហាប្រឈមនានារបស់មូលដ្ឋាន។ អភិបាលស្រុកត្រូវទទួលយកអនុសាសន៍ និងការណែនាំពីក្រុមប្រឹក្សាស្រុករបស់ខ្លួនដើម្បីធ្វើការណែនាំ សម្របសម្រួល និងតម្រង់ទិសដល់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័ន ដែលប្រចាំនៅស្រុកក្នុងការឆ្លើយតបតម្រូវការទាំងនោះហើយត្រូវរាយការណ៍ជូនក្រុមប្រឹក្សាស្រុករបស់ខ្លួនវិញ។

### ១.៧.២. ទំនាក់ទំនងរវាងរដ្ឋបាលស្រុកជាមួយក្រសួង ស្ថាប័ន

ទំនាក់ទំនងរវាងរដ្ឋបាលស្រុក ជាមួយក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ស្ថាប័នរបស់រាជរដ្ឋាភិបាលរួមមាន[៧]៖

- ក្រុមប្រឹក្សាស្រុកត្រូវស្ថិតក្នុងក្របខ័ណ្ឌនៃអំណាចប្រតិបត្តិរបស់ជាតិ។ អំណាចប្រតិបត្តិរបស់រាជរដ្ឋាភិបាលមានសិទ្ធិណែនាំ និងត្រួតពិនិត្យនីត្យានុកូលភាពនៃការសម្រេច និងការធ្វើសកម្មភាពរបស់ក្រុមប្រឹក្សា ដើម្បីធានាឱ្យបានថាក្រុមប្រឹក្សាគោរពយ៉ាងត្រឹមត្រូវនូវធម្មនុញ្ញ ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងគោល នយោបាយរបស់ជាតិ។
- ក្នុងការអនុវត្តការងារប្រចាំថ្ងៃគណៈអភិបាលខេត្ត គឺជាខ្សែរយៈទំនាក់ទំនងទៅវិញទៅមករវាងរាជរដ្ឋាភិបាល
- ក្រសួងស្ថាប័ននានានៃរាជរដ្ឋាភិបាលជាមួយរដ្ឋបាលស្រុក ព្រមទាំងការគាំទ្រដល់រដ្ឋបាលស្រុកក្នុងខេត្ត។
- ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព អាចធ្វើទំនាក់ទំនង និងកិច្ចសហការដោយផ្ទាល់ជាមួយរដ្ឋបាលស្រុកតាមការ ចាំបាច់ប៉ុន្តែត្រូវជូនដំណឹងដល់រដ្ឋបាលខេត្ត
- ក្រសួងមហាផ្ទៃ ត្រូវធ្វើការសម្របសម្រួលដោះស្រាយស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុតិនានា នៅពេលមានភាពមិនចុះសម្រុងគ្នារវាងរដ្ឋបាលខេត្តជាមួយរដ្ឋបាលស្រុក
- គ.ជ.អ.ប ត្រូវសម្របសម្រួលដោះស្រាយផ្អែកតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា នៅពេលមានភាព មិនចុះសម្រុងគ្នារវាងក្រសួងស្ថាប័ននានារបស់រាជរដ្ឋាភិបាលជាមួយក្រុមប្រឹក្សាស្រុកក្នុងខេត្ត
- ក្រុមប្រឹក្សាខេត្តត្រូវធានាឱ្យមានការពិគ្រោះយោបល់សមស្របជាមួយរដ្ឋបាលស្រុកក្នុងខេត្តសម្រាប់ជាមូលដ្ឋានក្នុងការពិគ្រោះពិភាក្សាជាមួយ គ.ជ.អ.ប និងក្រសួង ស្ថាប័ននានាអំពីការបែងចែកមុខងារ ធនធាន ទ្រព្យសម្បត្តិ ការគ្រប់គ្រង និងការកៀរគរចំណូលព្រមទាំងការកែសម្រួលឡើងវិញនូវបុគ្គលិកថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- ផ្អែកតាមការសម្រេចរបស់ គ.ជ.អ.ប ក្រុមប្រឹក្សាខេត្តត្រូវធានាធ្វើការសម្របសម្រួលជាមួយ រដ្ឋបាលស្រុកដើម្បីបែងចែកមុខងារ ធនធាន ទ្រព្យសម្បត្តិ ការគ្រប់គ្រង និងការកៀរគរចំណូលព្រមទាំងបុគ្គលិក

---

[៧] អនុក្រឹត្យស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក, លេខ១៨៤ អនក្រ.បក,ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩,មាត្រា៣៧

ឱ្យបានសមស្របតាមស្ថានភាពជាក់ស្តែងនៃតំបន់នីមួយៗ រួមទាំងតំបន់ប្រជុំជន និងតំបន់ជនបទក្នុងខេត្ត

- ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព នានាត្រូវចូលរួម និងគាំទ្រយ៉ាងសកម្មចំពោះដំណើរការនៃការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យតាមរយៈនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ ស្រុក។
- ក្រសួង ស្ថាប័ននីមួយៗ ត្រូវធ្វើការប្រគល់ និងធ្វើប្រតិភូកម្មមុខងារភារកិច្ចសមស្របដោយភ្ជាប់ជាមួយនូវ ធនធានហិរញ្ញវត្ថុ បុគ្គលិក និងសមត្ថភាពទៅឱ្យក្រុមប្រឹក្សាស្រុក។

### ១.៧.៣. ទំនាក់ទំនងរវាងរដ្ឋបាលស្រុកជាមួយរដ្ឋបាលខេត្ត

ក្រៅពីទំនាក់ទំនងនានាដែលបានកំណត់ក្នុងតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក រដ្ឋបាលខេត្ត រដ្ឋបាលស្រុកនៅមានទំនាក់ទំនងមួយចំនួន ទៀតដូចជា៖

- ក្រុមប្រឹក្សាខេត្តត្រូវសហការជាមួយក្រុមប្រឹក្សាស្រុកក្នុងខេត្តរបស់ខ្លួនដើម្បីពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំក្នុងខេត្តរបស់ខ្លួនក្នុងគោលបំណងឆ្លើយតបតម្រូវការចាំបាច់របស់ក្រុមប្រឹក្សាឃុំ
- គណៈអភិបាលខេត្ត គណៈអភិបាលស្រុក មានភារកិច្ចអនុវត្តកិច្ចការប្រចាំថ្ងៃក្នុងការទំនាក់ទំនងទៅវិញទៅមករវាងខេត្ត ស្រុក ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន
- ក្រុមប្រឹក្សាខេត្តត្រូវបានទទួលការធ្វើប្រតិភូកម្មអំណាចក្នុងនាមរាជរដ្ឋាភិបាលដើម្បីផ្តល់ការគាំទ្រ និងការត្រួតពិនិត្យ
- ពិនិត្យនីត្យានុកូលភាពលើសេចក្តីសម្រេច និងសកម្មភាពរបស់រដ្ឋបាលស្រុក ដើម្បីអាចធានាថារដ្ឋបាលស្រុកបំពេញមុខងារ ភារកិច្ច ដែលបានប្រគល់ ឬធ្វើប្រតិភូកម្មស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា ស្របតាមគោលនយោបាយរបស់ជាតិ។ ការធ្វើប្រតិភូកម្មរួមមាន៖
  - ការវាយតម្លៃ និងការរៀបចំយុទ្ធសាស្ត្រសមស្របសម្រាប់ផ្តល់ការគាំទ្រខាងសមត្ថភាពដល់ក្រុមប្រឹក្សាស្រុកព្រមទាំងមន្ត្រីបុគ្គលិកនៃក្រុមប្រឹក្សាស្រុក
  - ការណែនាំ និងសម្របសម្រួលគាំទ្រដល់ក្រុមប្រឹក្សាស្រុកក្នុងការអនុវត្តមុខងារភារកិច្ច និងធនធានដែលបានប្រគល់ឱ្យស្របទៅតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងគោលនយោបាយជាតិ
  - ត្រូវធានាថាស្រុកបានធ្វើការគាំទ្រយ៉ាងត្រឹមត្រូវដល់ឃុំក្នុងស្រុក។

- ក្រុមប្រឹក្សាខេត្តត្រូវបំពេញតួនាទីខាងលើនេះលើមូលដ្ឋាននៃការធានាស្វ័យភាពរបស់ស្រុកឱ្យស្របតាមគោលការណ៍នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋ បាលឃុំ សង្កាត់ ច្បាប់ អនុក្រឹត្យ លិខិតបទដ្ឋានគតិយុត្តនានាព្រមទាំងការសម្រេចរបស់ គ.ជ.អ.ប
- ក្រុមប្រឹក្សាខេត្តត្រូវបានទទួលប្រតិភូកម្មពីរាជរដ្ឋាភិបាលដើម្បីផ្តល់ការគាំទ្រ ការសម្របសម្រួល និងការធ្វើសហប្រតិបត្តិការជាមួយរដ្ឋបាលស្រុក ដើម្បីរួមគ្នាសម្រេចឱ្យបាននូវគោលនយោបាយជាតិ។
- ក្រុមប្រឹក្សាខេត្តត្រូវធានាថារដ្ឋបាលស្រុកក្នុងខេត្ត បំពេញមុខងារ ភារកិច្ចដែលបានប្រគល់ ឬបានធ្វើប្រតិភូកម្មឱ្យស្របទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងគោលនយោបាយរបស់ជាតិ។

### ១.៧.៤. ទំនាក់ទំនងរវាងរដ្ឋបាលស្រុកជាមួយរដ្ឋបាលឃុំ សង្កាត់

ក្រៅពីទំនាក់ទំនងនានាដែលបានកំណត់ក្នុងតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក រដ្ឋបាលស្រុកនៅមានទំនាក់ទំនងមួយចំនួនទៀតជាមួយរដ្ឋបាលឃុំ រដ្ឋបាលសង្កាត់ដូចជា៖

- ជួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងស្រុកឱ្យបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
- រួមជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងស្រុក ដើម្បីជំរុញឱ្យមានការចូលរួមពីសាធារណជនក្នុងដំណើរការអភិបាលកិច្ចនៅក្នុងស្រុក និងឃុំ សង្កាត់ក្នុងស្រុក
- ស្វែងយល់ និងឆ្លើយតបចំពោះតម្រូវការក្នុងស្រុករបស់ខ្លួន និងចំពោះសំណើរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងស្រុក។

ដើម្បីឱ្យក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ក្នុងស្រុកមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលបានមុខងារ និងធនធានកាន់តែច្រើន ក្រុមប្រឹក្សាស្រុកត្រូវពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ពាក់ព័ន្ធដើម្បី៖

- អប់រំផ្សព្វផ្សាយអំពីអភិបាលកិច្ចមូលដ្ឋានតាមបែបប្រជាធិបតេយ្យ និងវិមជ្ឈការ វិសហមជ្ឈការដល់ប្រជាពលរដ្ឋដើម្បីលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការអភិបាលកិច្ចក្នុងស្រុក និងឃុំសង្កាត់ក្នុងស្រុក
- ផ្អែកលើការវាយតម្លៃសមត្ថភាព និងការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុមប្រឹក្សាស្រុកត្រូវសម្របសម្រួល និងគាំទ្រដល់ការបង្កើនសមត្ថភាពផ្នែករដ្ឋបាលធនធានផ្នែករដ្ឋបាលដែលចាំបាច់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ សំដៅធានាឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ មានសមត្ថកិច្ច។

## ១.៨. មុខងាររបស់រដ្ឋបាលស្រុក

ដោយយោងតាមអនុក្រឹត្យ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក ដែលមានគោលបំណងលើកកម្ពស់ប្រសិទ្ធភាពក្នុងការគ្រប់គ្រងរដ្ឋបាលការផ្តល់សេវាសារធារណៈ និងការអភិវឌ្ឍមូលដ្ឋាន និងមានគោលដៅកំណត់ពីមុខងារ រចនាសម្ព័ន្ធ តួនាទី ទំនាក់ទំនងការងារ និងគណនេយ្យភាពរបស់រដ្ឋបាលស្រុក។ នៅក្នុងជំពូកទី២ បានចែងអំពីមុខងាររបស់រដ្ឋបាលស្រុក ដោយក្នុងមាត្រា៤ បានកំណត់ថាៈ[៨]

រដ្ឋបាលស្រុកត្រូវបំពេញមុខងារតាមការកំណត់នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមុខងារដែលបានផ្ទេរពីរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់។

មុខងារពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានក្នុងវិស័យនីមួយៗត្រូវបានប្រគល់ និងប្រតិភូកម្មទៅឱ្យរដ្ឋបាលស្រុកដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះលើកលែងតែមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡារបស់រដ្ឋបាលស្រុកនានានៃខេត្តបាត់ដំបងមានចែងក្នុង ជំពូកទី៧នៃអនុក្រឹត្យនេះ។

ក្រៅពីមុខងារដែលបានកំណត់ក្នុងវាក្យខ័ណ្ឌទី១ និងវាក្យខ័ណ្ឌទី២នៃមាត្រានេះ រដ្ឋបាលស្រុកបំពេញមុខងារជាភ្នាក់ងាររបស់ក្រសួង ស្ថាប័ន រដ្ឋបាលខេត្ត មន្ទីរ និងអង្គភាពនានាតាមការកំណត់ ដោយលិខិតបទដ្ឋានគតិយុត្តជាធរមាន ឬតាមកិច្ចព្រមព្រៀងរវាងក្រសួង ស្ថាប័ន រដ្ឋបាលខេត្ត មន្ទីរ និង អង្គភាពនានាជាមួយរដ្ឋបាលស្រុក។

នៅក្នុងអនុក្រឹត្យនេះដដែល មាត្រា៥ និងមាត្រា៦ បានចែងយ៉ាងច្បាស់ពីការកំណត់មុខងារ និងស្វ័យភាពរបស់រដ្ឋបាលស្រុក ដោយមាត្រា៥ បានចែងថាៈ

មុខងារផ្តល់សេវាសាធារណៈ និងអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលស្រុករួមមានមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើស។

រដ្ឋបាលស្រុកត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាកាតព្វកិច្ចនានាដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយផ្អែកតាមគោលការណ៍ នីតិវិធី ស្តង់ដាសេវា និង ធនធានដែលបានផ្ទេរមានភ្ជាប់លក្ខខណ្ឌ ព្រមទាំងអាចប្រើប្រាស់ធនធានរបស់ខ្លួន ឬធនធានដែលគៀរគរបានពីប្រភពស្របច្បាប់ផ្សេងទៀត ដើម្បីអនុវត្តមុខងារជាកាតព្វកិច្ចទាំងនោះឱ្យកាន់តែមាន ប្រសិទ្ធភាព។

[៨] អនុក្រឹត្យ លេខ១៨៤ អនក្រ.បក,ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩, មាត្រា៤, មាត្រា៥, មាត្រា៦

គោលការណ៍ នីតិវិធី និងស្តង់ដាសេវាសម្រាប់គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាកាតព្វកិច្ច ត្រូវរៀបចំ និងកំណត់ដោយក្រសួង ស្ថាប័ននៃវិស័យនីមួយៗ។ គោលការណ៍ នីតិវិធី និងស្តង់ដាសេវាសម្រាប់គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាកាតព្វកិច្ច ត្រូវរៀបចំ និងកំណត់ដោយក្រសួង ស្ថាប័ននៃវិស័យនីមួយៗ។

លើសពីនេះទៅទៀតនៅក្នុងមាត្រា៦ នៃអនុក្រឹត្យនេះបានចែងពីស្វ័យភាពក្នុងការជ្រើសរើសរបស់រដ្ឋបាលស្រុកផងដែរ ដែលក្នុងមាត្រានេះបានចែងថា៖

រដ្ឋបាលស្រុកមានស្វ័យភាពក្នុងការសម្រេចជ្រើសរើស ឬមិនជ្រើសរើសយកមុខងារជាជម្រើសណាមួយមកអនុវត្ត ផ្អែកតាមតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

រដ្ឋបាលស្រុកត្រូវគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើសក្នុងកម្រិតអតិបរមានៃលទ្ធភាព និងធនធានឆន្ទានុសិទ្ធិរបស់ខ្លួន និងធនធានដែលរដ្ឋបាលស្រុកកៀរគរបានពីប្រភពស្របច្បាប់។

រដ្ឋបាលស្រុកមានសិទ្ធិសម្រេចក្នុងការគ្រប់គ្រង ការចាត់ចែង និង អនុវត្តពីមុនមកដោយក្រសួង ស្ថាប័ន រដ្ឋបាលស្រុកមានសិទ្ធិសម្រេច ឬស្នើសុំមកក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីកំណត់អំពីបទដ្ឋាន នីតិវិធី និងធនធាន សម្រាប់គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារទាំងនោះ។

ក្រសួង ស្ថាប័នអាចផ្តល់ការណែនាំ ការគាំទ្រ និងឬធនធានទៅឱ្យរដ្ឋបាលស្រុកសម្រាប់គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើស។[៩]

## ១.៩. ហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានកំណត់ឱ្យរដ្ឋបាល ថ្នាក់ក្រោមជាតិមានធនធានហិរញ្ញវត្ថុសមស្រប ដើម្បីបំពេញតួនាទី ភារកិច្ចរបស់ខ្លួន និងត្រូវ គ្រប់គ្រងហិរញ្ញវត្ថុរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព មានតម្លាភាព និងមានគណនេយ្យភាព។ មាត្រា២៤៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានកំណត់អំពី ប្រភេទចំណូលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដូចខាងក្រោម[១០]៖

- ប្រភពនៅមូលដ្ឋាន

[៩] អនុក្រឹត្យ លេខ១៨៤ អនក្រ.បក,ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩, មាត្រា៦

[១០] ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ, លេខនស/រកម/០៦១១/០១១, ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១១, មាត្រា២៤

- ប្រភពពីថ្នាក់ជាតិ និង
- ប្រភពផ្សេងៗទៀត។

**ចំណូលពីប្រភពនៅមូលដ្ឋាន រួមមាន៖**

- ពន្ធនៅមូលដ្ឋាន
- ឈ្នួល កម្រៃ និងចំណូលមិនមែនសារពើពន្ធផ្សេងទៀត
- ចំណូលរបស់ក្រុមប្រឹក្សាស្រុក បានមកពីពន្ធ ឈ្នួល និងកម្រៃដែលត្រូវចែករំលែក រវាងក្រុមប្រឹក្សាស្រុកជាមួយក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ក្នុងស្រុក
- អំណោយស្ម័គ្រចិត្ត
- ប្រភពផ្សេងទៀតដែលកំណត់ដោយច្បាប់ ឬអនុក្រឹត្យ។

**ចំណូលពីថ្នាក់ជាតិ រួមមាន៖**

- ចំណូលចែករំលែក
- មូលនិធិផ្ទេរពីថវិកាជាតិ
- ថ្លៃសេវាបានមកពីមុខងារជាភ្នាក់ងារ ដែលអនុវត្តដោយក្រុមប្រឹក្សាក្នុងនាមក្រសួង ស្ថាប័ន។

# ជំពូកទី២

# ស្ថានភាពទូទៅនៃស្រុកមេមត់

# ជំពូកទី២

# ស្ថានភាពទូទៅនៃស្រុកមេមត់

## ២.១. ទីតាំងភូមិសាស្ត្រ និងប្រជាជន

ស្រុកមេមត់ ជាស្រុកមួយក្នុងចំណោមក្រុង ស្រុកទាំង ៧ នៃខេត្តត្បូងឃ្មុំ ស្ថិតនៅប៉ែកខាងកើត ចម្ងាយប្រមាណ៦០គ.ម ពីទីរួមខេត្តត្បូងឃ្មុំ ជាតំបន់ខ្ពង់រាបដែលមានព្រៃប្រទល់ ខាងជើង ទល់នឹង ស្រុកឆ្លូង និងស្រុកស្នួល ខេត្តក្រចេះ ខាងត្បូងទល់នឹង ស្រុកតិនចូវ និងស្រុកតិនបៀន ខេត្តតៃនិញ នៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម ខាងកើត ទល់នឹងស្រុកស្នួល ខេត្តក្រចេះ និងស្រុកឡុកនិញ ខេត្តប៊ីនភឿក នៃសាធារណៈរដ្ឋសង្គមនិយមវៀតណាមដែលមានខ្សែបន្ទាត់ព្រំដែនប្រវែង ១០១គ.ម និងខាងលិច ទល់នឹងស្រុកពញាក្រែក ស្រុកតំបែរ ខេត្តត្បូងឃ្មុំ។ តំបន់រដ្ឋបាលស្រុកចែកចេញជា ១៤ឃុំ ស្មើនឹង ១៨២ភូមិ ក្នុងនោះមានភូមិ១ ស្ថិតនៅក្នុងទឹកដីវៀតណាម និងមានប្រជាពលរដ្ឋប្រមាណ ៣៨,៩៤៩គ្រួសារ មនុស្សចំនួនប្រមាណ ១៦៥,២០៤នាក់ ក្នុងនោះស្រីប្រមាណ ៨៤,០៤៣នាក់។ មានមុខរបរជាកសិករប្រមាណជា ៩0% និងជាអាជីវករលក់ដូរ មន្ត្រីរាជការ និងកម្មកប្រមាណ ១0%។

ស្រុកមេមត់មានផ្ទៃដីរួម ១.៦០១,៣0 គីឡូម៉ែត្រការ៉េ មានសក្តានុពល និងគោលដៅអភិវឌ្ឍ សណ្ឋានដីក្រហមសំបូរជីវជាតិសម្រាប់ដំណាំកសិឧស្សាហកម្មគ្រប់ប្រភេទ អាចដាំដុះគ្រប់រដូវកាលព្រមទាំងមានអំណោយផលក្នុងការបង្កើតរោងចក្រសហគ្រាស និង មានតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រ តំបន់ទេសចរណ៍ធម្មជាតិ និងតំបន់រ៉ែមាសទៀតផង។ ស្រុកមេមត់ជាស្រុកមួយដែលមានសក្តានុពលយ៉ាងខ្លាំងផ្នែកសេដ្ឋកិច្ចជាពិសេសគឺកសិកម្ម ឧស្សាហកម្ម ដូចជាដំណាំកៅស៊ូ ម្រេច និងដំណាំដើមឈើហូបផ្លែ ដោយប្រជាពលរដ្ឋទទួលបានចំណូលខ្ពស់ និងមានជីវភាពប្រសើរពោលគឺកាត់បន្ថយការចំណាកស្រុកទៅក្រៅប្រទេស ដោយមានការងារធ្វើក្នុងស្រុក និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

## ២.២. ស្ថានភាពសេដ្ឋកិច្ច

ស្រុកមេមត់ជាស្រុកមួយដែលមានសក្តានុពលខ្លាំងក្នុងវិស័យកសិកម្ម ឧស្សាហកម្ម និងអាជីវកម្មដោយប្រជាជនមានជីវភាពល្អប្រសើរជម្រុញឱ្យមានការអភិវឌ្ឍលើគ្រប់វិស័យ និងបានកាត់បន្ថយការធ្វើចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេស។

### ២.២.១. វិស័យកសិកម្ម

នៅក្នុងស្រុកមេមត់ មានកសិករប្រមាណ ៧៨.៥% នៃចំនួនប្រជាជនសរុប កសិកម្មគឺជាវិស័យអាទិភាពគន្លឹះក្នុងផ្នែកសេដ្ឋកិច្ច យើងឃើញថាសកម្មភាពសំខាន់ៗក្នុងវិស័យកសិកម្ម រួមមានផលិតកម្មស្រូវ ដំណាំរយៈពេលខ្លី ដំណាំរយៈពេលវែង ដាំដំណាំបន្លែ នេសាទ ចិញ្ចឹមសត្វ និងអនុផលព្រៃឈើជាដើម។ ចំពោះផ្ទៃដីស្រូវប្រាំងមានប្រមាណ ៤៦៩,៧២ហ.ត ភាគរយផ្ទៃដីស្រូវប្រាំងបានដាំដុះជាក់ស្តែង ៩៣,៩% និងផ្ទៃដីស្រូវវស្សាមានប្រមាណ ៧,១៩០ហ.ត ភាគរយផ្ទៃដីស្រូវវស្សាបានដាំដុះជាក់ស្តែង ១០០%។ ក្រៅពីផលិតកម្មស្រូវក៏មានដំណាំរយៈពេលខ្លីមានចំនួន១៧,១% ក្នុងនោះរួមមាន ពោត សណ្តែកសៀង សណ្តែកបាយ សណ្តែក ដំឡូងមីល្ង រីឯដំណាំរយៈពេលវែង មានចំនួនប្រមាណ ៣៩.២% ក្នុងនោះមានដូចជា អំពៅ កៅស៊ូ ម្រេច ស្វាយចន្ទីស្វាយ ធូរេន សាវម៉ាវ មង្ឃុត ក្រូចពោធិ៍សាត់។ ចំពោះដាំដំណាំបន្លែផ្សេងៗវិញមានចំនួន ១.៣% ហើយជាមួយគ្នានេះប្រជាជនដែលបានប្រកបមុខរបរការចិញ្ចឹមសត្វចំនួន១.២%។[១១]

សព្វថ្ងៃនេះរដ្ឋបាលស្រុកមេមត់មានដំណាំសក្តានុពលសំខាន់ៗដូចជាស្រូវ,កៅស៊ូ,ម្រេច,ស្វាយចន្ទីដំឡូងមី ហើយក៏មាន បញ្ហាប្រឈមនានាកំពុងជួបប្រទះផងដែរ ក្នុងនោះដូចជាបញ្ហា៖

- តម្លៃជ័រកៅស៊ូ នៅមានកម្រិតទាប ពិបាករកទីផ្សារអន្តរជាតិដើម្បីប្រកួតប្រជែង ពោលគឺមានតែទីផ្សារក្នុងស្រុក ដោយឈ្មួញជាអ្នកកំណត់តម្លៃ
- តម្លៃម្រេចបានធ្លាក់ចុះ និងម្យ៉ាងទៀតពុំមានការប្រកួតប្រជែងទីផ្សារអន្តរជាតិពោលគឺមានតែឈ្មួញក្នុងស្រុកតែប៉ុណ្ណោះ
- ទិន្នផលស្រូវរបស់ប្រជាកសិករមានការថយចុះជាងឆ្នាំមុន
- ប្រជាជនភាគច្រើនប្រើប្រាស់ថ្នាំ និងជីគីមី ដែលធ្វើឱ្យប៉ះពាល់ដល់សុខភាព និងការបំពុលដល់បរិស្ថានធម្មជាតិច្រើនបំផុត
- កត្តាបម្រែបម្រួលអាកាសធាតុមិនទៀងទាត់។

### ២.២.២. វិស័យឧស្សាហកម្ម និង សិប្បកម្ម

បច្ចុប្បន្ននេះ ស្រុកមានសកម្មភាពសំខាន់ៗក្នុងវិស័យឧស្សាហកម្ម និងសិប្បកម្ម រួមមាន៖ សកម្មភាពសិប្បកម្មទឹកកក សិប្បកម្មទឹកបរិសុទ្ធ សិប្បកម្មផលិតនំប៉ុង សិប្បកម្មកែច្នៃម្រេច សិប្បកម្មឡឥដ្ឋ សិប្បកម្មផលិតគ្រឿងសង្ហារឹមពីឈើ រោងចក្រដំឡូងមី រោងចក្រកែច្នៃជ័រកៅស៊ូក្រែប រោងចក្រម៉ាស៊ីនកិនស្រូវ និងកន្លែងការងារ

[១១] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល ២០២២-២០២៤ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ, រដ្ឋបាលស្រុកមេមត់, បោះពុម្ពឆ្នាំ២០២២

ផ្គត់ផ្គង់ថាមពលអគ្គិសនី។ សក្តានុពលដែលមូលដ្ឋានស្រុកមេមត់មាន៖ រោងចក្រដំឡូងមី រោងចក្រកែច្នៃជ័រកៅស៊ូក្រែប សិប្បកម្មកែច្នៃម្រេច និងរោងចក្រម៉ាស៊ីនកិនស្រូវ ទោះបីជាយ៉ាងណាក៏ដោយបញ្ហាប្រឈមសំខាន់ៗដែលស្រុកមានពាក់ព័ន្ធនឹងវិស័យនេះរួមមាន៖

- ផលិតកម្មកសិឧស្សាហកម្ម សេវាកម្មនានាដើម្បីទាញយកប្រយោជន៍ពីធនធានធម្មជាតិក្នុងស្រុកពុំទាន់មានសកម្មភាពជាដុំកំភួន។
- លទ្ធភាពបណ្តាញចែកចាយផ្គត់ផ្គង់ថាមពលអគ្គីសនីរបស់សេវាករមួយចំនួននៅមានកម្រិត ទន្ទឹមនេះស្ថានភាពជីវភាពប្រជាពលរដ្ឋមួយចំនួនមានការខ្វះខាត
- រោងចក្រកែច្នៃដំឡូងមី ពុំមានជាលក្ខណៈទ្រង់ទ្រាយធំ ត្រូវយកនាំចេញបន្តទៅក្រៅប្រទេស (ប្រទេសវៀតណាម)។

### ២.២.៣. វិស័យគមនាគមន៍

នៅក្នុងស្រុកមេមត់ សរុបប្រវែងផ្លូវមាន ៧៧២,៣៩២ម ក្នុងនោះមានប្រវែងផ្លូវតាមបណ្តាឃុំមាន ៤២៥,៩១៨.០ម ប្រវែងផ្លូវខេត្តស្រុកឆ្លងកាត់តាមបណ្តាឃុំមាន១២៨,៩០០.០ម និងប្រវែងផ្លូវជាតិឆ្លងកាត់តាមបណ្តាឃុំមាន ១២៨,៩០០.០ម។ សព្វថ្ងៃនេះ ក្នុងស្រុក សក្តានុពលនៃប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ មាន៖ ផ្លូវជាតិ ផ្លូវដីស ផ្លូវក្រួសក្រហម ផ្លូវបេតុង។ល។ បញ្ហាប្រឈមសំខាន់ៗដែលមូលដ្ឋានកំពុងជួបប្រទះមាន៖

- ផ្លូវលំជនបទមួយចំនួនពុំទាន់មានគុណភាពល្អ និងមាននិរន្តរភាព
- ការថែទាំពុំបានល្អប្រសើរ
- ខ្វះស្លាកសញ្ញាចរាចរណ៍ដាក់តាមដងផ្លូវ
- ខ្វះការចូលរួមពីប្រជាពលរដ្ឋ
- ការប្រើរថយន្តដឹកទំនិញលើសទម្ងន់កំណត់។

### ២.២.៤. វិស័យអាជីវកម្ម

នៅក្នុងស្រុកមេមត់ សរុបទីតាំងផលិតកម្ម និងសេវាកម្មមាន២,១៦៣កន្លែង ដែលមុខរបរសំខាន់ៗក្នុងវិស័យអាជីវកម្មរួមមាន មុខរបរផ្នែកផលិតកម្មម៉ាស៊ីនកិនស្រូវ សិប្បកម្មផលិតគ្រឿងសង្ហារឹមពីឈើ សិប្បកម្មផលិតទឹកសុទ្ធ។ល។ មុខរបរផ្នែកសេវាកម្ម (លក់គ្រឿងបរិភោគ និងទំនិញប្រើប្រាស់ លក់គ្រឿងអលង្ការ លក់គ្រឿងអេឡិចត្រូនិច លក់គ្រឿងសង្ហារឹម លក់គ្រឿងសំណង់ ភោជនីយដ្ឋាន ជួសជុលឬលក់កង់ ម៉ូតូ ជុសជុលឬ

លក់គ្រឿងយន្ត និងឧបករណ៍កសិកម្ម ជុសជុលគ្រឿងអេឡិត្រូនិច ឱសថស្ថាន គ្លីនិក សណ្ឋាគារ ផ្ទះសំណាក់)។ សក្តានុពល សំខាន់ៗរបស់មូលដ្ឋាន និងបញ្ហាប្រឈមនានា ដែលមូលដ្ឋានកំពុងជួបប្រទះដូចជា៖[១២]

- មុខរបរផ្នែកផលិតកម្ម ពុំសូវមានច្រើនតាមតំបន់ជនបទ គឺបំពេញទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ រីឯផ្នែកសេវាកម្មក៏នៅមានការខ្វះខាតពុំបំពេញទៅតាមតម្រូវការបានគ្រប់គ្រាន់របស់អ្នកប្រើប្រាស់ត្រូវនាំចូលពីក្រៅស្រុក និងក្រៅប្រទេស
- ស្ត្រីជនពិការប្រជាពលរដ្ឋក្រីក្រនៅតាមតំបន់ជនបទខ្វះជំនាញវិជ្ជាជីវៈនិងពុំសូវមានការងារធ្វើ។

## ២.៣. ស្ថានភាពសង្គមកិច្ច

### ២.៣.១. វិស័យសុខាភិបាល

ក្នុងស្ថានភាពវិស័យសុខាភិបាលក្នុងស្រុកមេមត់ មណ្ឌលសុខភាពមាន១៥មណ្ឌល, ចំនួនមន្ទីរពេទ្យបង្អែកមាន១កន្លែង។ ចំពោះស្ថានភាពការស្លាប់របស់ស្ត្រី និងកុមារ អត្រាស្លាប់របស់មាតាក្នុង១០០០កំណើត មាន 0% និងអត្រាស្លាប់របស់ទារកក្នុង១០០០កំណើត 0%។ ភាគរយស្ត្រីមក សំរាលកូនដោយឆ្មបពេទ្យ មានចំនួន១០០% ភាគរយកុមារពីអាយុក្រោម១ឆ្នាំបានចាក់ថ្នាំបង្ការគ្រប់ចំនួនមាន១៤១%។ រីឯកម្មវិធីចម្បងបីរបស់សុខាភិបាល គឺ ការពិនិត្យផ្ទៃពោះ ការពន្យាកំណើត បញ្ហា ជម្ងឺឆ្លងនិង ជម្ងឺមិនឆ្លង និងបញ្ហាសុខភាពសាធារណៈត្រូវបានអនុវត្តទទួលបានលទ្ធផលល្អ។ ស្ថានភាពសុខភាពរបស់ប្រជាជនមានដូចជាៈ ការផ្តល់សេវាពិនិត្យសុខភាពស្ត្រី និងកុមារ (ពិនិត្យ ពិគ្រោះជំងឺក្រៅ ចាក់ថ្នាំបង្ការជំងឺ១១មុខដល់កុមារអាយុក្រោម១ឆ្នាំ ពិនិត្យផ្ទៃពោះមុនសម្រាល ចាក់ថ្នាំបង្ការតេតាណូសដល់ស្ត្រីក្នុងវ័យបន្តពូជ ពន្យាកំណើតដល់ស្ត្រីក្នុងវ័យបន្តពូជ សម្រាលកូននៅមូលដ្ឋានសុខាភិបាល និង ឆ្មបមានជំនាញបច្ចេកទេស) និងជំងឺទូទៅ បានកាត់បន្ថយអត្រាមរណភាពមាតា និងទារកគ្រោះថ្នាក់កើតពីជំងឺផ្សេងៗ។[១៣]

តារាងទី២១៖ ការអនុវត្តសកម្មភាព ការងាររបស់សុខាភិបាល

| ល.រ | ការបរិយាយ | ចំនួន | | | | |
|---|---|---|---|---|---|---|
| | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
| ១ | ពិនិត្យ ពិគ្រោះជំងឺ | ១១៣,៩៦៤ | ១០៩,៦៧៤ | ៩១,២១៦ | ១០២,៩២៣ | ១០១,៥៦០ |

[១២] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល ២០២២-២០២៤ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ, រដ្ឋបាលស្រុកមេមត់, បោះពុម្ពឆ្នាំ២០២២

[១៣] របាយការណ៍របស់ក្រុមប្រឹក្សាស្រុកមេមត់ អាណត្តិទី៣ ២០១៩-២០២៣, រដ្ឋបាលស្រុកមេមត់, បោះពុម្ព២០១៩

| | | | | | | |
|---|---|---|---|---|---|---|
| ២ | ចាក់ថ្នាំបង្ការជំងឺ១១មុខដល់កុមារក្រោមអាយុ១ឆ្នាំ | ២៨,៥៣៣ | ២៩,៣៣៤ | ២៧,៤៦៨ | ២៩,៣២២ | ២៩,៥៧៨ |
| ៣ | ពិនិត្យផ្ទៃពោះមុនសម្រាល | ១៧,៩៨៩ | ១៣,១២២ | ១៤,៦៩៨ | ១៤,៥៤៣ | ១៤,៧១៨ |
| ៤ | ចាក់ថ្នាំចង្ការតេតានណូសដល់ស្ត្រី | ៥,.៨៣១ | ៧,២៤៣ | ៧,៨៣៧ | ៨,៤៩៨ | ៨,០៦៤ |
| ៥ | ពន្យាកំណើតដល់ស្ត្រីក្នុងវ័យបន្តពូជ | ៩,៤៩៥ | ៩,៦០៥ | ៩,០៩៧ | ៨,៤៥៧ | ៨,៤៧៧ |
| ៦ | សម្រាលកូននៅមូលដ្ឋានសុខាភិបាល | ១៣,៦៩០ | ១១,៤៩៧ | ១១,៨៧០ | ១១.១៨៥ | ១០,៦៦១ |
| ៧ | ចំនួនអ្នកព្យាបាលជាសះស្បើយ | ៥,០៨៩ | ៦,០៥៨ | ៤,៥៤៥ | ៣,៦៨៨ | ៤,០៥០៩ |
| ៨ | អត្រាការប្រើប្រាស់គ្រែក្នុងមន្ទីពេទ្យ | ១៥៤% | ១១៨% | ១០២% | ៦៨% | ៧៦% |

## ២.៣.២. វិស័យអប់រំ

វិស័យអប់រំដែលជាវិស័យអាទិភាពចម្បងមួយរបស់ស្រុក ស្រុកមេមត់មានអគារសិក្សារដ្ឋចំនួន ១១៩ កន្លែងស្មើនឹង ១៦៤ខ្នង និងបន្ទប់សិក្សា៨០៧ និងមានអគារសិក្សារបស់វិស័យឯកជនមួយចំនួនផងដែរ។ វិស័យអប់រំដែលជាវិស័យអាទិភាពបានធ្វើឱ្យការអភិវឌ្ឍន៍ធនធានមនុស្ស និងការកាត់បន្ថយភាពក្រីក្រសម្រេចបានលទ្ធផលជាវិជ្ជមានដោយប្រជាពលរដ្ឋមានជីវភាពធូរធាជាទីគាប់ចិត្ត។ នៅក្នុងនោះការងារវិស័យអប់រំមានដូចជា៖ ការងារអប់រំកុមារតូច ការងារបឋមសិក្សា ការងារមធ្យមសិក្សា ការងារអប់រំកាយ និងកីឡា ការងារបុគ្គលិក និងបណ្តុះបណ្តាល។[១៤]

### ក. ស្ថានភាពកុមារអាយុ៣-៥ឆ្នាំ

ក្នុងនោះមត្តេយ្យសហគមន៍ចំនួន០៤ថ្នាក់សិស្សសរុបប្រមាណ១០៨នាក់ ស្រី ៦០នាក់ សាលាមេត្តេយ្យរដ្ឋចំនួន ៦៦សាលា ស្មើនឹង ១៣៨ថ្នាក់ សិស្សសរុបប្រមាណ ៣៩៧៨នាក់ ស្រី ១៩៥៨នាក់ មត្តេយ្យឯកជន

[១៤] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល ២០២២-២០២៤ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ, រដ្ឋបាលស្រុកមេមត់, បោះពុម្ពឆ្នាំ២០២២

ចំនួន០៣សាលា ស្មើនឹង១០ថ្នាក់ សិស្សសរុបប្រមាណចំនួន ៨៣នាក់ ស្រី ៤០នាក់ ហើយភាគរយកុមារអាយុ ៣ដល់៥ឆ្នាំបានចូលរៀន ៤៣,៣៨% សរុបសិស្សចំនួន ៤,១៦៩នាក់ និងស្រីចំនួន ២,០៥៨នាក់។

**ខ. ស្ថានភាពកុមារអាយុ៦-១១ឆ្នាំ**

- កុមារអាយុ ៦ឆ្នាំ ភាគរយកុមារអាយុ ៦ឆ្នាំ មិនបានចូលរៀនមាន ៣,៦២% ភាគរយកុមារអាយុ ៦ឆ្នាំ បានចូលរៀនបឋមមាន ៩៦,៣៨%។
- កុមារអាយុ ៦-១១ឆ្នាំ ភាគរយកុមារអាយុ ៦-១១ឆ្នាំ មិនបានចូលរៀនមាន ៣,៣០% ភាគរយកុមារ អាយុ ៦-១១ឆ្នាំ បានចូលរៀនបឋមមាន ៩៦,៧០%។

**គ. ស្ថានភាពកុមារអាយុ១២-១៤ឆ្នាំ**

ភាគរយកុមារអាយុ ១២-១៤ឆ្នាំ មិនបានចូលរៀនមាន១៧,៩៤% ភាគរយកុមារអាយុ ១២-១៤ឆ្នាំ បានចូលរៀន(បឋមនិងអនុវិទ្យាល័យ) មានប្រមាណ ៨២,០២%។

**ឃ. ស្ថានភាពអ្នកមិនចេះអក្សរ**

ចំនួនភាគរយអ្នកចេះអក្សររួមមានអាយុ១៥-១៧ឆ្នាំមាន៩៥.៨% ចំនួនភាគរយអ្នកចេះអក្សរមានអាយុ ១៨-៤៥ឆ្នាំ មាន៨៥,៨% ចំនួនភាគរយអ្នកចេះអក្សរមានអាយុ ១៨-៤៥ឆ្នាំមាន៨៥,៨% ចំនួនភាគរយអ្នកមិន ចេះអក្សរមានអាយុ ១៥-២៤ឆ្នាំ មាន៧,៧% ចំនួនភាគរយអ្នកមិនចេះអក្សរអាយុ២៥-៤៥ឆ្នាំមាន១៦,២%។

**ង. ស្ថានភាពសិស្ស និងគ្រូបង្រៀន**

- កម្រិតបឋមរដ្ឋមានចំនួនសាលា ១០៨ ចំនួនបន្ទប់រៀន៧៣៥ ចំនួនថ្នាក់រៀន ៧៥៧ ចំនួនសិស្ស ប្រមាណ ២៣,២៤៣នាក់ ស្រី ១១,២០នាក់ និងចំនួនគ្រូបង្រៀនប្រមាណ ៧៧៣នាក់ ក្នុងនោះគ្រូជាប់ កិច្ចសន្យាចំនួនប្រមាណ២៦០នាក់។
- កម្រិតអនុវិទ្យាល័យរដ្ឋមានចំនួនសាលា ១១ ចំនួនបន្ទប់រៀន ៦៤ ចំនួនថ្នាក់រៀន ៦៤ ចំនួនសិស្ស ប្រមាណ ៣,៥៨៦នាក់ ស្រី ២២២០នាក់ និងចំនួនគ្រូបង្រៀន ១០៩នាក់ ស្រី ៣៦នាក់។
- កម្រិតវិទ្យាល័យរដ្ឋ មានចំនួនសាលា ០៥ ចំនួនបន្ទប់រៀន ១៣១ ចំនួនថ្នាក់រៀន ១២១ ចំនួនសិស្ស ប្រមាណ ៥,៨៧០នាក់ ស្រី ២៨៦០នាក់ និងចំនួនគ្រូបង្រៀន ១៩៩នាក់ ស្រី៧៤នាក់។

### ២.៣.៣. ស្ថានភាពយេនឌ័រ

ក្នុងស្ថានភាពយេនឌ័រសេដ្ឋកិច្ចស្រុកមេមត់ ភាគរយស្ត្រីមានមុខរបរចម្បងក្រៅពីវិស័យកសិកម្មចំនួន ៤៣,៦% ភាគរយស្ត្រីមានមុខរបរបន្ទាប់បន្សំក្រៅពីវិស័យកសិកម្មចំនួន ៤០,៣% ភាគរយស្ត្រីធ្វើចំណាកស្រុកនៅក្នុងប្រទេសចំនួន៦% ភាគរយស្ត្រីធ្វើចំណាកស្រុកនៅក្រៅប្រទេសចំនួន ១%។[១៥]

- យេនឌ័រអប់រំ៖ អត្រាស្ត្រីចេះអក្សរអាយុ ១៥-១៧ឆ្នាំ មាន០,៩៧% ភាគរយស្ត្រីចេះអក្សរអាយុ១៨-៤៥ ឆ្នាំ មាន៨៥,៥% និងភាគរយស្ត្រីជាគ្រូបង្រៀនបឋមស្មើ៣៩,៣% និងអនុវិទ្យាល័យស្មើ៤២,៤%។
- យេនឌ័រងាយរងគ្រោះ ភាគរយស្ត្រីជាជនពិការចំនួន៤១,៥%។
- យេនឌ័រសម្រេចចិត្ត៖ ភាគរយស្ត្រីជាមេភូមិមាន៦,៥% ក្រុមប្រឹក្សាឃុំសង្កាត់មាន២០,២% ក្រុមប្រឹក្សាស្រុកមាន១៩% ភាគរយស្ត្រីជាមន្ត្រីតាមការិយាល័យជំនាញស្រុកមាន១១,៩%។ ការទទួលយកសេវាការចូលរួមចំណែករបស់ស្ត្រីក្នុងការសម្រេចចិត្តនានានិង សកម្មភាពសង្គម ដោយគោលនយោបាយសមភាពយេនឌ័រតាមរយៈការអនុវត្តផែនការនារីរតនៈទី៤ដោយផ្តោតលើសកម្មភាពអាទិភាពចំនួន០៧ រួមមានដូចជា៖
  - ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី
  - ការអប់រំសម្រាប់ស្ត្រី និងក្មេងស្រី និងការផ្លាស់ប្តូរឥរិយាបថ
  - យេនឌ័រ និងសុខភាព
  - យេនឌ័រ និងមេរោគអេដស៍
  - ស្ត្រីក្នុងការធ្វើសម្រេចចិត្តក្នុងវិស័យសាធារណៈ និងនយោបាយ
  - ការបញ្ជ្រាបយេនឌ័រ ក្នុងគោលនយោបាយ និងវិស័យពាក់ព័ន្ធ។

### ២.៣.៤. ស្ថានភាពនៃភាពក្រីក្រ

រដ្ឋបាលស្រុកមេមត់ បានយកចិត្តទុកដាក់ក្នុងការអនុវត្តគោលនយោបាយកាត់បន្ថយភាពក្រីក្រ ដែលរាជរដ្ឋាភិបាលបានដាក់ចេញ គឺទទួលបានលទ្ធផលគួរឱ្យកត់សម្គាល់ ហើយទូទាំងស្រុកអត្រាភាពក្រីក្រមានការថយចុះជាបន្តបន្ទាប់ផងដែរ ដែលអត្រាភាពក្រីក្រមានត្រឹមតែ២៩.៦១%។ ប៉ុន្តែដោយរងនូវវិបត្តកូវីត១៩ បានបង្កជាផលប៉ះពាល់ដល់ផ្នែកសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរផងដែរ ដែលធ្វើឱ្យអត្រាភាពក្រីក្រមានការកើនឡើង

[១៥] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល ២០២២-២០២៤ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ, រដ្ឋបាលស្រុកមេមត់, បោះពុម្ពឆ្នាំ២០២២

ដោយប្រជាជនមួយចំនួនបានធ្លាក់ចូលក្នុងវិបត្តិបំណុល និងការទទួលបានចំណូលទាប ក្នុងកំឡុងឆ្នាំ ២០២០ ដល់ ២០២១។[១៦]

### ២.៣.៥. ស្ថានភាពសាសនា

ទូទាំងស្រុកមានប្រភេទសាសនា ដូចជា សាសនាព្រះពុទ្ធ សាសនាឥស្លាម និងសាសនាគ្រិស្ត ហើយចំនួនភាគរយប្រជាពលរដ្ឋដែលកាន់សាសនាព្រះពុទ្ធគឺជាង ៩០ភាគរយ។ ស្រុកមេមត់មានវត្តសរុប ៣៧វត្ត ព្រះសង្ឃសរុបចំនួនប្រមាណ ២០៦អង្គ កន្លងមកនេះយើងសង្កេតឃើញបញ្ហាខ្លះៗ ដែលនាំឱ្យប្រជាពលរដ្ឋបាត់នូវជំជឿលើព្រះពុទ្ធសាសនា ដូចតាមវត្ត និងព្រះសង្ឃមួយចំនួន កើតមានអធិករណ៍ និងការសាមគ្គីរវាងសង្ឃ និងគណៈកម្មការវត្តពុំទាន់ល្អប្រសើរ និងការគោរពវិន័យរបស់ព្រះសង្ឃមួយចំនួនធ្វើឱ្យខូចវិន័យសេចក្ដីថ្លៃថ្នូរ និងប៉ះពាល់ព្រះពុទ្ធសាសនាដែលជាហេតុជាឱ្យប្រជាពលរដ្ឋបាត់នូវជំនឿសាសនា។[១៧]

### ២.៣.៦. ស្ថានភាពអន្តោប្រវេសន៍ និងការផ្លាស់លំនៅ

ចំពោះស្ថានភាពនៃការផ្លាស់លំនៅ និងចំណាកស្រុករបស់ប្រជាពលរដ្ឋពីតំបន់ផ្សេងៗដោយ ប្រជាជនមួយចំនួនបានចំណាកស្រុកទៅរកការងារធ្វើនៅក្រៅស្រុក និងក្រៅប្រទេសដូចជា ប្រទេសថៃ ប្រទេសកូរ៉េ ប្រទេសម៉ាឡេស៊ី និងប្រទេសផ្សេងៗទៀត ក្រៅពីនេះក៏មានពលរដ្ឋស្ត្រីខ្មែរបានរៀបការជាមួយជនបរទេស។ ចំណែកឯការធ្វើចំណាកស្រុកទាំងអស់នេះ មានខ្លះស្របច្បាប់ និងខ្លះទៀតមិនស្របច្បាប់ រដ្ឋបាលស្រុក ឃុំក៏បានណែនាំ និងចុះផ្សព្វផ្សាយពីចំណាកស្រុកដោយសុវត្ថិភាពនៅតាមភូមិ ឃុំជាប្រចាំ។

### ២.៣.៧. ស្ថានភាពធនធានធម្មជាតិ បរិស្ថាននិង ការប្រែប្រួលអាកាសធាតុ

#### ២.៣.៧.១. ការខារបរិស្ថាន

សក្ដានុពលពាក់ព័ន្ធនឹងបរិស្ថានដូចជា កន្លែងហាត់ប្រាណ សួនឧទ្យានសាធារណៈ និងទីលានចាក់សំរាម។ បញ្ហានានាដែលគំរាមកំហែងលើបរិស្ថាន ដូចជា៖

- ការបំពុលបរិយាកាសពីរោងចក្រ ការចោលកាកសំណល់រឹង និងរាវដោយរោងចក្រសហគ្រាស អាជីវកម្ម និងសិប្បកម្ម

---

[១៦] សៀវភៅផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ ឆ្នាំ២០២០-២០២៤ ស្រុកមេមត់ខេត្តត្បូងឃ្មុំ, រដ្ឋបាលស្រុកមេមត់, បោះពុម្ពឆ្នាំ២០២២

[១៧] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល ២០២២-២០២៤ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ, រដ្ឋបាលស្រុកមេមត់, បោះពុម្ពឆ្នាំ២០២២

- ប្រជាពលរដ្ឋមិនសូវយល់ដឹងពីជម្ងឺពីផលប៉ះពាល់នៃសំរាម និងបរិស្ថានដោយយកសំរាមទៅចោលពាសវាលពាសកាល
- ចំនួនគ្រួសារដែលមានបង្គន់ប្រើប្រាស់នៅមានកម្រិតទាប។

**២.៣.៧.២. ការខារគ្រោះមហន្តរាយចម្បងៗ**

ស្រុកមេមត់បានទទួលរងគ្រោះដោយធម្មជាតិ និងទទួលការបំផ្លិចបំផ្លាញដោយ ខ្យល់កន្ត្រាក់ រន្ទះបាញ់ អគ្គីភ័យ គ្រោះថ្នាក់ដោយសារលង់ទឹក ការពុលអាហារ។ គ្រោះដោយធម្មជាតិ បណ្តាលឱ្យមានការខូចខាតផ្ទះ មនុស្សរបួសនិងស្លាប់ និងប៉ះពាល់ផលដំណាំមួយចំនួនទៀតផងដែរ។

**២.៣.៧.៣. ការគ្រប់គ្រងធនធានធម្មជាតិ**

ធនធានធម្មជាតិសំខាន់ៗ ដូចជាដីធ្លី ព្រៃឈើ សត្វព្រៃ បឹង អូរ ស្ទឹង។ល។ ប្រជាជនពឹងផ្អែកលើធនធានទាំងនេះសម្រាប់ទ្រទ្រង់ជីវភាពរស់នៅរបស់ពួកគាត់ ចំណែកបញ្ហាប្រឈមទៅលើធនធានធម្មជាតិមួយចំនួនត្រូវបាត់បង់ជាបណ្តើរៗ ដោយសារគ្មានការចូលរួមថែរក្សា។ បន្ថែមពីនេះ ស្រុកមេមត់មានតំបន់រ៉ែមាស១កន្លែងដែលមានទីតាំងនៅឃុំជាំតាម៉ៅក្នុងឆ្នាំ២០១០ ក្រុមហ៊ុនធិន ស៊ីណូ សាន់បានចូលមកធ្វើអាជីវកម្មជាលក្ខណៈសាកល្បង តែត្រូវបិទទៅវិញក្នុងឆ្នាំ ២០១៥ បច្ចុប្បន្ននេះមិនដំណើរការទេ មានតែប្រជាពលរដ្ឋមួយចំនួនធ្វើអាជីវកម្មជាលក្ខណៈគ្រួសារ និងថ្មីៗនេះនៅថ្ងៃទី១០ ខែមករា ឆ្នាំ២០២៤ នេះ ក្រសួងរ៉ែ និងថាមពលបានប្រកាសពីការបើកប្រតិបត្តិការដោះស្រាយទ្រង់ទ្រាយធំ បង្ក្រាបលើទីតាំងអាជីវកម្មរ៉ែមាសអនាធិបតេយ្យស្ថិតនៅក្នុងភូមិសំពៅលូន ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ បើតាមក្រសួងរ៉ែ និងថាមពលតំបន់ភូមិសំពៅលូន ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ គឺជាតំបន់អាជីវកម្មរ៉ែមាស បែបលក្ខណៈគ្រួសារតាំងពីអំឡុងឆ្នាំ១៩៩០ ដែលមានប្រជាពលរដ្ឋមូលដ្ឋានប្រកបរបរជីកយក និងរែងមាស ដោយដៃតាមលក្ខណៈគ្រួសារ។ ប៉ុន្តែនៅប៉ុន្មានឆ្នាំចុងក្រោយនេះ មានការប្រែប្រួលពីលក្ខណៈគ្រួសារដែលធ្វើដោយដៃ និងឧបករណ៍សាមញ្ញទៅជាប្រើគ្រឿងចក្រ រំសេវជាតិផ្ទុះ និងសារធាតុគីមី ដោយកន្លែងខ្លះមានជីករូងជាអណ្តូងរ៉ែក្រោមដីទៀតផង។

#### ២.៣.៧.៤. ការប្រើប្រាស់ដីធ្លី

ការគ្រប់គ្រងប្រើប្រាស់ដីធ្លីត្រូវបានពង្រឹងការអនុវត្តតាមច្បាប់ភូមិបាលឆ្នាំ២០០១ និងបានអនុវត្តនូវសកម្មភាពដូចជា ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ និងការងារសំណង់។ បញ្ហាប្រឈមសំខាន់ៗពាក់ព័ន្ធនឹងការប្រើប្រាស់ដីរួមមាន៖[១៨]

- ចំពោះការងារវិវាទដីធ្លីកើតឡើងដោយសារមិនមានប្លង់ត្រឹមត្រូវ
- ចំពោះវិស័យសំណង់កើតឡើងនូវសំណង់គ្មានច្បាប់ និងសំណង់បណ្តោះអាសន្នច្រើន
- ការសាងសង់មួយចំនួនគ្មានប្លង់ និងពាក់ព័ន្ធលើចំណីផ្លូវ។

## ២.៤. ការគ្រប់គ្រងនគរូបនីយកម្ម

### ២.៤.១. ការងារការរៀបចំដែនដី នគរូបនីយកម្ម

ស្រុកមេមត់បានមានសកម្មភាពក្នុងការរៀបចំដែនដី នគរូបនីយកម្មដូចខាងក្រោម៖[១៩]

- បានអនុម័តផែនការនៃការប្រើប្រាស់ដីចំនួន០២ឃុំ ដែលមានដូចជា ឃុំទន្លូង និងឃុំជាំតាម៉ៅ ក្នុងឆ្នាំ២០២០
- កំពុងតែធ្វើការអនុម័តផែនការនៃការប្រើប្រាស់ដីមានចំនួន០៧ឃុំ ដូចជា ឃុំចាន់មូល ឃុំជាំ ឃុំ ដារ ឃុំរូង ឃុំត្រមូង ឃុំទ្រៀក និងឃុំជាំក្រវៀន ក្នុងឆ្នាំ២០២៣។

បន្ថែមពីនេះរដ្ឋបាលស្រុកមេមត់បានចូលរួមកំណត់ព្រំប្រទល់ភូមិ ឃុំ ទំហំផ្លូវ អូរ ប្រឡាយ នៅក្នុងតំបន់វិនិច្ឆ័យ មានភូមិឃុំដូចជា៖

- ឃុំរូង ភូមិរូង ភូមិបេង ភូមិជាំទូក ភូមិគោញ ភូមិម៉ាស៊ីន ភូមិដូង ភូមិសូទៃ ភូមិត្រពាំង ឬស្សី ភូមិអណ្តូងតាជោ ភូមិបុស្ស ភូមិដូនរ័ត្ន១ ភូមិដូនរ័ត្ន២ និងភូមិចំបក់
- ឃុំទ្រៀក ភូមិដក់ពរ ភូមិបង្កោ ភូមិមោសចូល ភូមិព្រះពន្លា ភូមិប្រិយ៍ ភូមិសំរោងត្បូង ភូមិថ្លៃ។
- ឃុំទន្លូង ភូមិក្តុលលើ ភូមិក្តុលក្រោម ភូមិបេងកោង ភូមិពងទឹក ភូមិស្លាគីឡូ ភូមិចង្កុំកណ្តាល ភូមិក្តុលផ្សារ ភូមិចង្កុំទី១ ភូមិកោះថ្ម ភូមិស្លាភ្នំ ភូមិម្ការ ភូមិល្វាលើ។

---

[១៨] សៀវភៅផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ ឆ្នាំ២០២០-២០២៤ ស្រុកមេមត់ខេត្តត្បូងឃ្មុំ, រដ្ឋបាលស្រុកមេមត់, បោះពុម្ពឆ្នាំ២០២២

[១៩] របាយការណ៍របស់ក្រុមប្រឹក្សាស្រុកមេមត់ អាណត្តិទី៣ ២០១៩-២០២៣, រដ្ឋបាលស្រុកមេមត់, បោះពុម្ព២០១៩

- ឃុំជាំតាម៉ៅ ភូមិសំពៅលូន ភូមិកន្ទួត ភូមិទួលគ្រួស ភូមិថ្នល់កែង ភូមិឡាំបោរ ភូមិបុស្សតាអឹម ភូមិថ្មទទឹងត្បូង ភូមិថ្មទទឹងជើង ភូមិអង្កាំ ភូមិជំនុំពល ភូមិតាម៉ៅកើត។
- ឃុំដារ ភូមិដារជើង ភូមិដារកណ្តាល ភូមិសំរោងជើង ភូមិចំការគរ ភូមិដារផ្សារ ដារកណ្តាល ភូមិដារលិចភូមិ៧មករា ភូមិស្ពាន ភូមិស្រែជាំ ភូមិមែកពុក ភូមិដារត្បូង ភូមិទ្រៀក ភូមិធ្វរជើង ភូមិសំរោងជើង ភូមិបេង ភូមិធ្វរកណ្តាល ភូមិសាឡង់ទី១ ភូមិសាឡង់ទី២ ភូមិតេជោសែនលិច ភូមិតេជោសែនកើត ភូមិកងកេង។
- ឃុំជាំក្រវៀន ភូមិស្រែលើសែនជ័យ ភូមិថ្មដារ ភូមិរបងចុះ ភូមិសាទុំ ភូមិម្រាន់ ភូមិដង្ខិត ភូមិក្រវៀនធំ ភូមិក្រវៀនជើង ភូមិដូង ភូមិក្បាលស្លែង ភូមិមោះ ភូមិខ្នាយ ភូមិជ្រៃឡើង ភូមិជីប្លុក ភូមិបង្ហើយហួស ភូមិប្រិយ៍ ភូមិប្បុរ ភូមិថ្មតាដោក។

### ២.៤.២. ការងារភូមិបាល

តាមរបាយការបូកសរុបទិន្នន័យពីឆ្នាំ (២០១៩-២០២៣) ការងារចុះបញ្ជីលើកដំបូងអង្កេតវាស់វែងបានចំនួន ៧២ ក្បាលដី និងចេញប័ណ្ណបានចំនួន ៥៩ប័ណ្ណ ការងារចុះបញ្ជីបន្ត ការងារផ្ទេរសិទ្ធិលក់ផ្តាច់បានចំនួន ៧២១ប័ណ្ណ និងអំណោយផ្តាច់ចំនួន ៧៨ ប័ណ្ណ និងផ្ទេរតាមសាលក្រមតុលាការចំនួន ០៥ ប័ណ្ណ ការស្នើសុំទុតិយតាចំនួន ១ប័ណ្ណ ការស្នើសុំប្តូរប្រភេទដីចំនួន ០៥ប័ណ្ណ សន្តតិកម្មចំនួន ០៣ប័ណ្ណ ស្នើសុំបង្រួមក្បាលដីចំនួន ០៦ក្បាលដី។[២០]

### ២.៤.៣. ការងារសំណង់ និងលំនៅដ្ឋាន

ការងារសំណង់បូកសរុបពី ឆ្នាំ ២០១៨-២០២៣ ការចេញលិខិតអនុញ្ញាតសាងសង់មានចំនួន ៣៥ករណី និងការងារផ្អាកសំណង់គ្មានច្បាប់ ចុះហាមឃាត់សំណង់គ្មាន់ច្បាប់ ១៥ករណី ចំណែកឯសំណង់ផ្ទះតាមព្រំដែនបានសាងសង់លំនៅឋានជូនកងទ័ព និងនគរបាលជាតិឈរជើងនៅតាមព្រំដែនកម្ពុជា-វៀតណាម អតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ និងប្រជាជនក្រីក្រទូទៅដូចជានៅ ឃុំចាន់មូល សង់ផ្ទះបាន ២៥ខ្នង ឃុំរូងសង់ផ្ទះបាន ៥០ខ្នង ឃុំទ្រៀក សង់ផ្ទះបាន ៥០ខ្នង។ រីឯការងារនីតិកម្ម និងដោះស្រាយ សម្រុះសម្រួលវិវាទនៅមូលដ្ឋាន រដ្ឋបាលស្រុកមេមត់ក៏បានយកចិត្តទុក្ខដាក់ផងដែរ។

[២០] របាយការណ៍របស់ក្រុមប្រឹក្សាស្រុកមេមត់ អាណត្តិទី៣ ២០១៩-២០២៣, រដ្ឋបាលស្រុកមេមត់, បោះពុម្ព២០១៩

តារាងទី១៨៖ ដោះស្រាយ និងសម្រុះសម្រួលទំនាស់

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | សរុប |
| ១ | ករណីដែលបានដោះស្រាយ ឬសម្រុះសម្រួលរួច | ១៩២ | ១៥៣ | ១៣១ | ២១៣ | ២២៨ | ៩៨៥ |
| ២ | ករណីដែលបានបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ | ២៤ | ២១ | ១៦ | ៣០ | ១៤ | ១០៥ |

## ២.៥. សន្តិសុខ និងការគ្រប់គ្រងសណ្តាប់ធ្នាប់សាធារណៈ

### ២.៥.១. ស្ថានភាពសន្តិសុខស្រុកមេមត់

ចំពោះការងារសន្តិសុខ និងសណ្តាប់ធ្នាប់ រដ្ឋបាលស្រុកមេមត់បានចាត់ទុកបញ្ហានេះជាកត្តាអទិភាពរបស់មូលដ្ឋានក្នុងស្រុកផងដែរ ដែលត្រូវត្រួតពិនិត្យជាប្រចាំ មុនការងារ និងប្រតិបត្តិការការងារលើគ្រប់វិស័យ។ បន្ថែមពីនេះរដ្ឋបាលស្រុកបានរៀបចំវិធានការ និងសកម្មភាពជាច្រើនសំដៅលើការប្រមូលផ្តុំនូវកម្លាំងសរុបរបស់ស្រុកដោយមានកងកម្លាំង នគរបាល យោធា និងកងរាជអាវុធហត្ថស្រុក ជាស្នូល ក្នុងយន្តការគណៈបញ្ជាការឯកភាពស្រុក ឃុំ ដោយរក្សាបានសន្តិសុខនយោបាយ និងសណ្តាប់ធ្នាប់សាធារណៈ ការងារចរាចរណ៍ផ្លូវគោក និងគ្រោះថ្នាក់ផ្សេងៗ។ល។ បញ្ហាសំខាន់ៗដែលពាក់ព័ន្ធនឹងការគ្រប់គ្រង ការរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ នៅតំបន់ទីប្រជុំជន និងជនបទ មានដូចជា៖[២១]

- អំពើហិង្សានៅក្នុងគ្រួសារនៅតែកើតមានឡើង
- ការចែកចាយ និងប្រើប្រាស់គ្រឿងញៀន និងការលួច នៅតែកើតមានឡើងបន្តបន្ទាប់
- គ្រោះថ្នាក់ចរាចរណ៍នៅតាមដងផ្លូវនៅតែមាននៅកន្លែងមួយចំនួន។

### ២.៥.២. ការបង្ក្រាបបទល្មើសផ្សេងៗ

ក្នុងរយៈពេល ៥ឆ្នាំ រដ្ឋបាលស្រុកមេមត់មានបទល្មើសកើតឡើងចំនួន ១៥៩លើកក្នុងនោះមាន៖[២២]

[២១] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល ២០២២-២០២៤ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ, រដ្ឋបាលស្រុកមេមត់, បោះពុម្ពឆ្នាំ២០២២

[២២] របាយការណ៍របស់ក្រុមប្រឹក្សាស្រុកមេមត់ អាណត្តិទី៣ ២០១៩-២០២៣, រដ្ឋបាលស្រុកមេមត់, បោះពុម្ព២០១៩

➢ បទល្មើសឧក្រិដ្ឋ មានចំនួន៣៩លើក ចាប់ឃាត់ខ្លួនជនសង្ស័យចំនួន៤២នាក់

- ឆ្នាំ២០១៩ មានចំនួន៧លើក ចាប់ឃាត់ខ្លួនជនសង្ស័យចំនួន៦នាក់
- ឆ្នាំ២០២០ មានចំនួន១២លើក ចាប់ឃាត់ខ្លួនជនសង្ស័យចំនួន១៣នាក់
- ឆ្នាំ២០២១ មានចំនួន៩លើក ចាប់ឃាត់ខ្លួនជនសង្ស័យចំនួន១៣នាក់
- ឆ្នាំ២០២២ មានចំនួន៤លើក ចាប់ឃាត់ខ្លួនជនសង្ស័យចំនួន៣នាក់
- ឆ្នាំ២០២៣ មានចំនួន៧លើក ចាប់ឃាត់ខ្លួនជនសង្ស័យចំនួន៧នាក់។

➢ បទល្មើសមជ្ឈិម មានចំនួន១២០លើក ចាប់ឃាត់ជនសង្ស័យចំនួន១៤០នាក់

- ឆ្នាំ២០១៩ មានចំនួន១៣លើក ចាប់ឃាត់ខ្លួនជនសង្ស័យចំនួន១៤នាក់
- ឆ្នាំ២០២០ មានចំនួន៣០លើក ចាប់ឃាត់ខ្លួនជនសង្ស័យចំនួន៤១នាក់
- ឆ្នាំ២០២១ មានចំនួន២៥លើក ចាប់ឃាត់ខ្លួនជនសង្ស័យចំនួន៣២នាក់
- ឆ្នាំ២០២២ មានចំនួន១៤លើក ចាប់ឃាត់ខ្លួនជនសង្ស័យចំនួន១៧នាក់
- ឆ្នាំ២០២៣ មានចំនួន៣៨លើក ចាប់ឃាត់ខ្លួនជនសង្ស័យចំនួន៣៦នាក់។

សរុបការគ្រោះថ្នាក់ និងបាត់បង់ ស្លាប់មនុស្ស១៣នាក់ របួសមនុស្ស៤៦នាក់ នារីរងគ្រោះ១២នាក់ កូនកៅស៊ូ៣៥០ដើម ជញ្ជីង២ ម៉ូតូ៤៧គ្រឿង។

- បង្ក្រាបតាមដីកា ចំនួន៥៦ដីកា ចាប់ឃាត់ខ្លួនជនល្មើសចំនួន៥៦នាក់។
- កិច្ចសហការបង្ក្រាប ចំនួន៥លើក ចាប់ឃាត់ខ្លួនជនល្មើសចំនួន៥នាក់ ក្នុងនោះបង្ក្រាបទីតាំងផលិតបារីនៅឃុំដារ គ្មានលិខិតអនុញ្ញាតិ ០១កន្លែង ពាក់ព័ន្ធករណីលួច ០១លើក ពាក់ព័ន្ធករណីហិង្សា ០១លើក ពាក់ព័ន្ធករណីលួចហិង្សា ០១លើក ពាក់ព័ន្ធករណីជួញ ដូរគ្រឿងញៀន០១លើក។
- កិច្ចប្រតិបត្តិការបង្ក្រាប ចំនួន០២លើក បង្ក្រាបករណីប៉ុនប៉ងលួច០១ករណី ចាប់ឃាត់ខ្លួនជនសង្ស័យ ០២នាក់ប្រុស បង្ក្រាបករណីប្រជល់មាន់ ០១លើក ដកហូតមាន់ជល់ ០៩ក្បាល ម៉ូតូ៨ គ្រឿង សុំក្រុងមាន់២០ ជញ្ជីង០១ ផ្លែដែក០៣គូ កន្ត្រក០៥។
- ចុះបង្ក្រាបបទល្មើសគ្រឿងញៀន ចំនួន១៩៧លើក ឃាត់ខ្លួនជនសង្ស័យ៣១៥នាក់ ស្រី១៥ នាក់ ថ្នាំញៀន១១៩១កញ្ចប់ ថ្នាំWY១០គ្រាប់ ទូរស័ព្ទ៥៤គ្រឿង រថយន្ត២គ្រឿង ម៉ូតូ៤៥ គ្រឿង ឧបករណ៍ជក់០៦ ជញ្ជីង០៧ ដាវ០៣ អាវុធកែច្នៃ០១ដើម ប្រាក់រៀល២.៥៧០.០០០៛។

- គ្រោះថ្នាក់ចរាចរណ៍ កើតឡើងចំនួន១៨១លើក ស្លាប់មនុស្ស៦៦នាក់ ស្រី៨នាក់ រងរបួស ២៣៨នាក់ ស្រី៥១នាក់ ខូចខាតទោចក្រយានយន្ត១៧១គ្រឿង រថយន្ត៦៧គ្រឿង ទោចក្រយាន០៣គ្រឿង ទោចក្រយានយន្តសណ្តោងរ៉ឺម៉ក០១គ្រឿង។
- គ្រោះថ្នាក់ផ្សេងៗ កើតឡើងចំនួន១១៥លើក សរុបការខូចខាតនិងបាត់បង់ ស្លាប់មនុស្ស ៩៤នាក់ ស្រី ១៨នាក់ រងរបួស២៦នាក់ ស្រី៦នាក់ ខូចខាតទោចក្រយានយន្ត១២គ្រឿង រថយន្ត ០៥គ្រឿង ឆេះជ័រចំហុយ៧តោន ឆេះឡចំហុយជ័រ០២ ឆេះផ្ទះ១២ខ្នង កុដិព្រះសង្ឃ០១ខ្នង ឆេះ និងបាត់ប្រាក់រៀលចំនួន ៧៨.000.000៛ មាស0,៥ជី ឆេះម្រេច០៧តោន ឆេះគ្រឿងសង្ហារឹម និងសម្ភារមួយចំនួន។

### ២.៥.៣. ការគ្រប់គ្រងច្រកព្រំដែន និងជនអន្តោប្រវេសន៍

ជារួមរយៈពេល៥ឆ្នាំ សភាពការសន្តិសុខតាមព្រំដែន(កម្ពុជា-វៀតណាម) មានលក្ខណៈល្អប្រសើរ។ ស្រុកមេមត់មានព្រំដែនជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម ដោយក្នុងនោះមានច្រកទ្វារព្រំដែនចំនួន៦ ច្រកដារ (ដូង៧ដើម)ស្ថិតនៅឃុំដារ និងច្រកទ្វារទន្លេចាមក្នុងនោះ ច្រកទ្វារទ្វេភាគីមានចំនួន២ គឺច្រកទ្វារ ស្ថិតនៅឃុំជាំក្រវៀន ច្រកទ្វារតំបន់មានចំនួន៤ គឺច្រកទ្វារទន្លេចាម ច្រកទ្វារចាន់មូល ច្រកទ្វារជាំក្រវៀន និងច្រកទ្វារទន្លូង។ ការងារចុះល្បាតតាមខ្សែបន្ទាត់តាមព្រំដែន ជាប់ជាប្រចាំតាមប៉ុស្តិ៍គោលដៅ ក្នុង១ថ្ងៃ២លើក។

ការងារគ្រប់គ្រងជនបរទេសនិងជនអន្តោប្រវេសន៍ៈជនជាតិវៀតណាមមានចំនួន៥៣គ្រួសារ មនុស្សរួម ៩៧នាក់ ប្រុស៥៣នាក់ អាយុ១៨ឆ្នាំឡើង៨០នាក់ ប្រុស៤៧នាក់។[២៣]

[២៣] របាយការណ៍របស់ក្រុមប្រឹក្សាស្រុកមេមត់ អាណត្តិទី៣ ២០១៩-២០២៣, រដ្ឋបាលស្រុកមេមត់, បោះពុម្ព២០១៩

# ជំពូកទី៣
# ដំណើរការប្រព្រឹត្តទៅនៃការគ្រប់គ្រងរដ្ឋបាលស្រុកមេមត់

# ជំពូកទី៣

# ដំណើរការប្រព្រឹត្តទៅនៃការគ្រប់គ្រងរដ្ឋបាលស្រុកមេមត់

## ៣.១. រចនាសម្ព័ន្ធរដ្ឋបាលស្រុកមេមត់ និង អង្គដឹកនាំរដ្ឋបាលស្រុក

ស្រុកមេមត់មានរចនាសម្ព័ន្ធរដ្ឋបាលចំនួន ១៤ឃុំ និងភូមិមានចំនួន ១៨២ភូមិ និងមានការកំណត់រចនាសម្ព័ន្ធរដ្ឋបាលស្រុកយ៉ាងជាក់លាក់តាមបទប្បញ្ញត្តិ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨។

### រចនាសម្ព័ន្ធរដ្ឋបាលស្រុកមេមត់

| | | | | |
|---|---|---|---|---|
| ការិ.ប្រជាពលរដ្ឋ | គណៈកម្មាធិការ | ក្រុមប្រឹក្សា | គណៈកម្មាធិការ | គណៈកម្មាធិការ |

**គណៈអភិបាល**

- -លោក **ស្រេង លី** អភិបាលស្រុក
- -លោក **ឈោ អៀត** អភិបាលរងស្រុក
- -លោក **ញ៉ឹក នៅ** អភិបាលរងស្រុក
- -លោកស្រី **នី លីហ្វាន់** អភិបាលរងស្រុក
- -លោក **តាំង ម៉េងរ៉ាត់** អភិបាលរងស្រុក
- -លោក **អ៊ុំង សំអុល** អភិបាលរងស្រុក
- -លោក **ម៉ីន សុក្រី** អភិបាលរងស្រុក

**នាយករដ្ឋបាល**

- -លោក **អ៊ុំង សំអុល** នាយករដ្ឋបាល
- -លោកស្រី **ឡី សុខឡើន** នាយករងរដ្ឋបាល
- -លោកស្រី **ហេង សុវណ្ណា** នាយករងរដ្ឋបាល

| | | | |
|---|---|---|---|
| ការិយាល័យរដ្ឋបាល និង ហិរញ្ញវត្ថុ | អង្គភាពលទ្ធកម្ម | ការិយាល័យគ្រប់គ្រងធនធានមនុស្ស | ការិយាល័យផែនការ និងគាំទ្រឃុំ |

រដ្ឋបាលស្រុកមេមត់មានអង្គដឹកនាំរដ្ឋបាលរបស់សាលាស្រុកមានសមាសភាពមន្ត្រីជំនាញ ដូចជា៖[២៤]

- ក្រុមប្រឹក្សាស្រុក មាន ២១ នាក់ ស្រី ០៤ នាក់
- គណៈអភិបាលស្រុក មានចំនួន ០៧ នាក់ ស្រី ០១នាក់
- នាយករដ្ឋបាល ០១ នាក់ និង នាយករងរដ្ឋបាល ០២នាក់
- ការិយាល័យ អង្គភាពចំណុះ រចនាសម្ព័ន្ធរដ្ឋបាលស្រុកមាន៖
  - ➢ ការិយាល័យរដ្ឋបាលសរុបចំនួន ០៣នាក់ ស្រី ០២នាក់
  - ➢ ការិយាល័យផែនការគាំទ្រឃុំសរុបចំនួន ០២នាក់ ស្រី ០១នាក់
  - ➢ អង្គភាពលទ្ធកម្មសរុបចំនួន០២នាក់ ស្រី០១នាក់
  - ➢ ការិយាល័យគ្រប់គ្រងធនធានមនុស្សចំនួន ០១នាក់ ស្រី០១នាក់
  - ➢ ការិយាល័យលេខាធិការក្រុមប្រឹក្សាចំនួន ០១នាក់
  - ➢ ការិយាល័យត្រួតពិនិត្យផ្ទៃក្នុងចំនួន ០២នាក់ ស្រី០១នាក់
  - ➢ ការិយាល័យអប់រំ យុវជន និងកីឡា ចំនួន១៣នាក់ ស្រី០១នាក់
  - ➢ ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ចំនួន០៥នាក់ ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋានចំនួន ០៣នាក់ ស្រី០២នាក់ ការិយាល័យកសិកម្ម ធនធានធម្មជាតិ និងបរិស្ថានចំនួន០៤នាក់
  - ➢ ការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍ចំនួន០២នាក់,ការិយាល័យសង្គមកិច្ច និងសុខមាលភាពសង្គមចំនួន០៣នាក់ ស្រី០២នាក់
  - ➢ ការិយាល័យច្រកចេញចូលតែមួយចំនួន ០៤នាក់ ស្រី០១នាក់
  - ➢ ការិយាល័យប្រជាពលរដ្ឋចំនួន ០២នាក់ និងមន្ត្រីជាប់កិច្ចសន្យាសរុបចំនួន ០៣ ស្រី ០២នាក់
- ក្រុមប្រឹក្សាឃុំសរុបចំនួន ១០២នាក់ ស្រី ២០នាក់
- ស្មៀនឃុំ ចំនួន ១៤នាក់ ស្រី១នាក់
- ជំនួយការឃុំសរុប ៤២នាក់ ស្រី ២៣នាក់[២៥]

---

[២៤] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល ២០២២-២០២៤ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ, រដ្ឋបាលស្រុកមេមត់, បោះពុម្ពឆ្នាំ២០២២

[២៥] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល ២០២២-២០២៤ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ, រដ្ឋបាលស្រុកមេមត់, បោះពុម្ពឆ្នាំ២០២២

| ល.រ | ការិយាល័យជំនាញជុំវិញស្រុក | ចំនួនបុគ្គលិក | | ប្រធាន | | អនុប្រធាន | |
|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី |
| ១ | ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ | ៣ | ២ | ១ | ០ | ០ | ១ |
| ២ | អង្គភាពលទ្ធកម្ម | ២ | ១ | ១ | ០ | ០ | ០ |
| ៣ | ការិយាល័យគ្រប់គ្រងធនធានមនុស្ស | ១ | ១ | ០ | ១ | ០ | ១ |
| ៤ | ការិយាល័យអប់រំ យុវជន និងកីឡា | ១៣ | ១ | ១ | ០ | ២ | ០ |
| ៥ | ការិយាល័យផែនការ និងគាំទ្រឃុំ | ២ | ១ | ០ | ១ | ១ | ០ |
| ៦ | ការិយាល័យលេខាធិការក្រុមប្រឹក្សា | ១ | ០ | ១ | ០ | ០ | ០ |
| ៧ | ការិយាល័យត្រួតពិនិត្យផ្ទៃក្នុង | ២ | ១ | ១ | ០ | ០ | ០ |
| ៨ | ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល | ៥ | ០ | ១ | ០ | ១ | ០ |
| ៩ | ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន | ៣ | ២ | ១ | ០ | ០ | ១ |
| ១០ | ការិយាល័យកសិកម្ម ធនធានធម្មជាតិ និងបរិស្ថាន | ៤ | ០ | ១ | ០ | ១ | ០ |
| ១១ | ការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍសហគមន៍ | ២ | ០ | ១ | ០ | ១ | ០ |
| ១២ | ការិយាល័យសង្គមកិច្ច និងសុខមាលភាពសង្គម | ៣ | ២ | ០ | ១ | ១ | ១ |
| ១៣ | ការិយាល័យច្រកចេញចូលតែមួយ | ៤ | ១ | ១ | ០ | ១ | ០ |
| ១៤ | ការិយាល័យប្រជាពលរដ្ឋ | ២ | ០ | ១ | ០ | ០ | ០ |

## ៣.២. តួនាទី និងភារកិច្ច

### ៣.២.១. តួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សារដ្ឋបាលស្រុកមេមត់

រដ្ឋបាលស្រុកមេមត់ ជារដ្ឋបាលមូលដ្ឋានដែលមានក្រុមប្រឹក្សាជាតំណាង។ ក្រុមប្រឹក្សាកើតឡើងតាមរយៈការបោះឆ្នោតអសកលពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងដែនដីរបស់ខ្លួន។ ក្រោយពីប្រកាសចូលកាន់តំណែងក្រុមប្រឹក្សាត្រូវបំពេញតួនាទី ភារកិច្ចស្របតាមច្បាប់ និងលិខិបទដ្ឋានគតិយុត្តជាធរមានក្នុងអាណត្តិ៥ឆ្នាំរបស់ខ្លួន។ ការងារសំខាន់ៗដែលក្រុមប្រឹក្សាត្រូវបំពេញក្នុងអាណត្តិការងាររបស់ខ្លួនក្នុងនោះរួមមាន៖[២៦]

- កិច្ចប្រជុំរបស់ក្រុមប្រឹក្សា
- ការតាក់តែងដីកា
- វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់
- ការរៀបចំផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល
- ការងារហិរញ្ញវត្ថុ
- មុខងារ
- ការងារបុគ្គលិក
- សិទ្ធិចុះហត្ថលេខា និងទង្វើមិនស្របច្បាប់របស់ក្រុមប្រឹក្សា និង
- ទង្វើត្រូវធ្វើ និងទង្វើមិនត្រូវធ្វើ។

### ៣.២.២. តួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់គណៈអភិបាលស្រុកមេមត់

គណៈអភិបាលស្រុកមេមត់ ត្រូវធ្វើការសិក្សាស្រាវជ្រាវ ដើម្បីផ្ដល់យោបល់ជូនក្រុមប្រឹក្សាស្រុក អំពីកិច្ចការនានាដែលពាក់ព័ន្ធនឹងអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិរបស់ក្រុមប្រឹក្សាស្រុក ដើម្បីក្រុមប្រឹក្សាស្រុកធ្វើការពិភាក្សា អនុម័តក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញទាក់ទងនឹង៖[២៧]

- ការពិនិត្យមុខងារ ភារកិច្ច និងធនធានទាំងអស់ដែលបានប្រគល់ ឬបានផ្ទេរមកឱ្យក្រុមប្រឹក្សាស្រុក និងរបៀបរបប បែបបទ នីតិវិធីនៃការអនុវត្តមុខងារ ភារកិច្ច និងការចាត់ចែងធនធានទាំងនោះ

---

[២៦] សៀវភៅ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា, សម្ដេចក្រឡាហោម ស ខេង, បោះពុម្ពឆ្នាំ២០១៨ ទំព័រទី ៣៥

[២៧] គេហទំព័រ https://www.ouchrovbmc.gov.kh/, ដកស្រង់ថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០២៤

- ការរៀបចំយុទ្ធសាស្ត្រ និងការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន ដើម្បីទទួលយកមុខងារ ភារកិច្ច និងធនធានដែលបានប្រគល់ ឬបានផ្ទេរ ស្របតាមច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ផែនការអភិវឌ្ឍនរយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំ
- ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងការធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ
- គម្រោងថវិកាប្រចាំឆ្នាំ
- ការងារហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ស្រុក
- ការបង្កើត ការកែសម្រួល ឬការរំសាយការិយាល័យនានា
- ការរៀបចំតួនាទី ភារកិច្ច និងល័ក្ខខ័ណ្ឌការងាររបស់បុគ្គលិក
- ការកំណត់នីតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុសម្រាប់ការិយាល័យ និងបុគ្គលិករបស់ក្រុមប្រឹក្សាស្រុក
- ការកំណត់យុទ្ធសាស្ត្រ ដើម្បីអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក និងបុគ្គលិករបស់ក្រុមប្រឹក្សាស្រុក
- ការរៀបចំរបាយការណ៍ប្រចាំឆ្នាំ ដាក់ជូនក្រុមប្រឹក្សាស្រុក ពិនិត្យ និងអនុម័ត មិនឱ្យលើសពី៤៥ថ្ងៃ បន្ទាប់ពីដំណាច់ឆ្នាំនីមួយៗ ពាក់ព័ន្ធនឹង៖
    - ដីកា និងសេចក្តីសម្រេចនានាដែលបានដាក់ចេញដោយក្រុមប្រឹក្សាស្រុក និងសកម្មភាពលទ្ធផលនៃការអនុវត្ត
    - របាយការណ៍ហិរញ្ញវត្ថុ
    - ការវាយតម្លៃអំពីការបំពេញការងាររបស់គណៈអភិបាលស្រុក និងបុគ្គលិករបស់ក្រុមប្រឹក្សាស្រុក
    - វិធានការចាំបាច់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តការងាររបស់ក្រុមប្រឹក្សាស្រុក
    - វិធានការចាំបាច់ដើម្បីលើកកម្ពស់សមភាពយេនឌ័រ
    - កិច្ចការផ្សេងៗទៀត ដែលក្រុមប្រឹក្សាស្រុកយល់ឃើញថាចាំបាច់ ត្រូវដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំខែ ត្រីមាស និងឆមាស
- ការវាយតម្លៃសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងស្រុក និងតម្រូវការគាំទ្រចំពោះឃុំ សង្កាត់ក្នុងស្រុក
- ការបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនានា តាមការចាំបាច់ដើម្បីជួយដល់ការអនុវត្តការងាររបស់ក្រុមប្រឹក្សាស្រុក

- ការរៀបចំយុទ្ធសាស្ត្រផ្សព្វផ្សាយព័ត៌មានដល់សាធារណជន ដូចជាការរៀបចំក្ដារព័ត៌មាន ការបិទផ្សាយព័ត៌មាននៅលើក្ដារព័ត៌មាន និងការស្វែងរកមធ្យោបាយផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- កិច្ចសហការ និងការគាំទ្រដល់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ នៅក្នុងស្រុករបស់ខ្លួន
- ការដោះស្រាយសំណើ សំណូមពរ និងបញ្ហាប្រឈមនានារបស់ឃុំ សង្កាត់
- កិច្ចការផ្សេងៗទៀត ដែលកំណត់ដោយច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងដែលតម្រូវដោយក្រុមប្រឹក្សាស្រុករបស់ខ្លួន។

### ៣.២.៣. តួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់នាយករដ្ឋបាល

នាយករដ្ឋបាល មានតួនាទីជាជំនួយការក្នុងការចាត់ចែងកិច្ចការរដ្ឋបាល និងធានា និរន្តរភាពកិច្ចការរដ្ឋបាលប្រចាំថ្ងៃរបស់ក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន។

ក្នុងតួនាទីខាងលើនេះ នាយករដ្ឋបាលត្រូវធ្វើសេចក្តីរាយការណ៍ និងមានគណនេយ្យភាព ចំពោះក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន។

នាយករដ្ឋបាល មានតួនាទី ភារកិច្ចដូចខាងក្រោម៖[២៨]

- អនុវត្តកិច្ចការប្រចាំថ្ងៃរបស់ក្រុមប្រឹក្សា និងគណៈអភិបាល
- ធានាឱ្យអង្គភាព បុគ្គលិករបស់ក្រុមប្រឹក្សា អនុវត្តសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន
- អនុវត្តដីការបស់ក្រុមប្រឹក្សា
- ចូលរួម និងមានយោបល់រាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា គណៈកម្មាធិការរបស់ក្រុមប្រឹក្សា និង គណៈអភិបាល ប៉ុន្តែពុំមានសិទ្ធិបោះឆ្នោតបានឡើយ
- ផ្ដល់យោបល់ដល់ក្រុមប្រឹក្សា ដល់គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា ដើម្បី ក្រុមប្រឹក្សាសម្រេចបាននូវគោលបំណងក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
- ផ្ដល់យោលបល់ដល់គណៈអភិបាល ដើម្បីគណៈអភិបាលអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព។

[២៨] ច្បាប់លេខ នស/រកម/០៥០៨/០១៧, ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨, មាត្រា១៨៤-១៨៥

## ៣.៣. ការិយាល័យចំណុះរដ្ឋបាលស្រុកមេមត់

សាលាស្រុកមេមត់មាន ការិយាល័យជំនាញចាំបាច់ចំនួន ៥ ដូចជា៖

- ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ
- ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់
- ការិយាល័យអន្តរវិស័យ
- អង្គភាពលទ្ធកម្ម។
- ការរិយាល័យគ្រប់គ្រងធនធានមនុស្ស

ការិយាល័យនីមួយៗត្រូវដឹកនាំដោយប្រធានការិយាល័យមួយរូប និងមានអនុប្រធានការិយាល័យមួយរូបជា ជំនួយការ។ ប្រធានការិយាល័យនីមួយៗត្រូវមានការទទួលខុសត្រូវ និងត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះ នាយករដ្ឋបាលសាលាស្រុក។

### ៣.៣.១. ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ

ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលស្រុកលើការងាររដ្ឋបាល និងហិរញ្ញវត្ថុ និងមានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម៖[២៩]

- ការងាររដ្ឋបាល លិខិតស្នាមផ្សេងៗ ព័ត៌មាន ពិធីការ ទំនាក់ទំនងសាធារណៈ និងសហ ប្រតិបត្តិការអន្តរជាតិ
- ការងារអត្រានុកូលដ្ឋាន
- ការគ្រប់គ្រង និងការថែរក្សាត្រា ឯកសារ លិខិតបទដ្ឋាននានារបស់រដ្ឋបាលស្រុក
- ការពិនិត្យ និងការកែសម្រួលរចនាសម្ព័ន្ធរបស់រដ្ឋបាលស្រុក
- ការរៀបចំនីតិវិធីរដ្ឋបាល និងនីតិវិធីហិរញ្ញវត្ថុសម្រាប់អង្គភាពរបស់រដ្ឋបាលស្រុកផ្អែកតាម គោលការណ៍ និងបទប្បញ្ញត្តិជាធរមាន
- ការងារហិរញ្ញវត្ថុ ថវិកា និងទ្រព្យសម្បត្តិរបស់រដ្ឋបាលស្រុក
- ការងារសណ្តាប់ធ្នាប់សាធារណៈ

[២៩] អនុក្រឹត្យលេខ១៨៨អនក្រ.បក, ចុះថ្ងៃថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ មាត្រា១៥

- ការងាររបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ និងរបាយការណ៍ ហិរញ្ញវត្ថុរបស់រដ្ឋបាលស្រុក និងការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលស្រុក។

**៣.៣.២. ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់**

ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលស្រុកលើ ការងារផែនការ និងគាំទ្រឃុំ សង្កាត់ក្នុងស្រុក និងមានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម៖

- ការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍន៍ប្រាំ (០៥)ឆ្នាំ កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ និងគម្រោងអភិវឌ្ឍន៍នានារបស់រដ្ឋបាលស្រុក
- ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តផែនការអភិវឌ្ឍន៍ប្រាំ(០៥)ឆ្នាំ កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិល ផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ និងគម្រោងអភិវឌ្ឍន៍ នានារបស់រដ្ឋបាលស្រុក
- ការងារស្ថិតិប្រជាជន
- ការគាំទ្រ ការសម្របសម្រួល និងការតាមដាន ត្រួតពិនិត្យ វាយតម្លៃរដ្ឋបាលឃុំ សង្កាត់ក្នុង ស្រុកលើការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍន៍ប្រាំ(០៥) ឆ្នាំ កម្មវិធីវិនិយោគបី(០៣)ឆ្នាំ រំកិល និងគម្រោងនានារបស់រដ្ឋបាលឃុំ សង្កាត់ក្នុងស្រុក
- ការណែនាំ និងការជំរុញការប្រមូលទិន្នន័យមូលដ្ឋានឃុំ សង្កាត់ និងទិន្នន័យថ្នាក់ស្រុកតាម ការកំណត់
- ការគ្រប់គ្រង និងការស្វែងរកការគាំទ្រការកែច្នៃទិន្នន័យមូលដ្ឋានឃុំ សង្កាត់ និងទិន្នន័យ ថ្នាក់ស្រុក
- ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាពបុគ្គលិក និងក្រុមប្រឹក្សាឃុំ សង្កាត់តាមតម្រូវ ការចាំបាច់
- ការគាំទ្របច្ចេកទេសលើការងាររដ្ឋបាល និងហិរញ្ញវត្ថុដល់រដ្ឋបាលឃុំ សង្កាត់
- ការដោះស្រាយសំណើ សំណូមពរ និងបញ្ហាប្រឈមនានារបស់រដ្ឋបាលឃុំ សង្កាត់
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលស្រុក។

**៣.៣.៣. ការិយាល័យអន្តរវិស័យ**

ការិយាល័យអន្តរវិស័យនៃសាលាស្រុក គឺជាសេនាធិការឱ្យក្រុមប្រឹក្សាស្រុក និងគណៈអភិបាលស្រុកលើកិច្ច ការសំខាន់ដូចខាងក្រោម៖

- សិក្សា និងលើកយោបល់ទៅលើការរៀបចំយុទ្ធសាស្ត្រ និងការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធានដើម្បី ទទួលយកមុខងារ ភារកិច្ច និងធនធានដែលបានប្រគល់ ឬបានផ្ទេរស្របទៅតាមច្បាប់ និងលិខិតបទដ្ឋានកំណត់

- ការងារដីធ្លី និងសំណង់ដែលរួមមានពាក្យសុំកាន់កាប់ដីធ្លី សាងសង់ រុះរើ ជួសជុល កែលម្អ សំណង់នានា
- ការអនុវត្តមុខងារ ភារកិច្ចនានាដែលបានប្រគល់ ឬបានធ្វើប្រតិភូកម្ម
- ការងារសណ្តាប់ធ្នាប់សាធារណៈ កិច្ចការច្បាប់ និងសិទ្ធិមនុស្ស
- ការងារសម្រុះសម្រួល ផ្សះផ្សាទំនាស់ផ្សេងៗក្នុងដែនសមត្ថកិច្ចរបស់ស្រុក ស្របទៅតាមច្បាប់ និងនិតិវិធីជា ធរមាន
- ការងារសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ សាសនា ការការពារបរិស្ថាន ធនធានធម្មជាតិ បេតិកភ័ណ្ឌ រមណីដ្ឋាន និងតំបន់ប្រវត្តិសាស្ត្រ ដែលកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនានា។

### ៣.៣.៤. អង្គភាពលទ្ធកម្ម

អង្គភាពលទ្ធកម្ម ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលស្រុកលើការងារលទ្ធកម្មសាធារណៈ និងមានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោមៈ[៣០]

- ការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ
- ការរៀបចំឯកសារដេញថ្លៃ ការរៀបចំ និងការផ្សព្វផ្សាយអំពីកិច្ចលទ្ធកម្ម ការផ្តល់ឯកសារ ដេញថ្លៃ ការទទួលសំណើដេញថ្លៃ ការរៀបចំទុកដាក់ឯកសារសំណើដេញថ្លៃ ការរៀបចំទី កន្លែង និងការរៀបចំបើកសំណើដេញថ្លៃ
- ការរៀបចំរបាយការណ៍ និងកំណត់ហេតុស្តីពីការបើកសំណើដេញថ្លៃ
- ការរៀបចំ និងការសម្របសម្រួលក្នុងការវាយតម្លៃលើបច្ចេកទេសនៃសំណើដេញថ្លៃ
- ការរៀបចំកិច្ចសន្យា និងលិខិតជូនដំណឹងអំពីការប្រគល់កិច្ចសន្យា
- ការផ្សព្វផ្សាយលទ្ធផលនៃការដេញថ្លៃ
- ការតាមដានការអនុវត្តកិច្ចសន្យា និងការរៀបចំរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្ម ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលស្រុក។

[៣០] អនុក្រឹត្យលេខ១៨៤អនក្រ.បក, ចុះថ្ងៃថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ មាត្រា១៦

### ៣.៣.៥. ការិយាល័យគ្រប់គ្រងធនធានមនុស្ស

ការិយាល័យគ្រប់គ្រងធនធានមនុស្សត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលស្រុកលើការងារគ្រប់គ្រងធនធានមនុស្ស និងមានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម៖

- ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់បុគ្គលិករបស់រដ្ឋបាលស្រុក
- ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាពបុគ្គលិករបស់រដ្ឋបាលស្រុក
- ការគ្រប់គ្រងបុគ្គលិកផ្សេងទៀតតាមការផ្ទេរសិទ្ធិអំណាចពីរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលស្រុក។

<u>តារាងទី៩៖ ស្ថិតិក្រុមប្រឹក្សា និងបុគ្គលិក</u>

| ល.រ | ការបរិយាយ | សរុប | ស្រី |
|---|---|---|---|
| ១ | សមាជិកក្រុមប្រឹក្សា | ២១ | ៤ |
| ២ | ប្រធានក្រុមប្រឹក្សា | ២ | ០ |
| ៣ | សមាជិកក្រុបប្រឹក្សាដែលបានផ្លាស់ប្តូក្នុងរយៈពេល៥ឆ្នាំ ២០១៨-២០២៤ | ២ | ០ |
| ៤ | អភិបាល | ១ | ០ |
| ៥ | អភិបាលរង | ៦ | ១ |
| ៦ | នាយករដ្ឋបាល | ១ | ០ |
| ៧ | នាយករងរដ្ឋបាល | ១ | ១ |
| ៨ | ប្រធានការិយាល័យ និងអង្គភាព | ១៣ | ៣ |
| ៩ | អនុប្រធានការិយាល័យ និងអង្គភាព | ១០ | ២ |
| ១០ | មន្ត្រីការិយាល័យ | ២២ | ៦ |
| ១១ | បុគ្គលិកកិច្ចសន្យា | ៣ | ២ |

### ៣.៣.៦. ការកសាងសមត្ថភាព

ដើម្បីឆ្លើយតបទៅនឹងគោលដៅនៃគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការពង្រឹង និងអភិវឌ្ឍន៍ធនធានមនុស្ស នៅរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យកាន់តែមានសមត្ថភាព ផលិតភាព ភក្តីភាព ឆន្ទៈម្ចាស់ការ គណនេយ្យភាព វប្បធម៌សេវាសាធារ ណៈ សីលធម៌ និងមនសិការវិជ្ជាជីវៈខ្ពស់ រដ្ឋបាលស្រុកមេមត់ជានិច្ចកាលធ្វើការសហការជាមួយអ្នកពាក់ព័ន្ធ លើកទឹកចិត្ត និងជម្រុញឱ្យបុគ្គលិករបស់ខ្លួនចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងវគ្គពង្រឹងសមត្ថភាពផ្សេងៗ ទៅតាមជំនាញ និងវិស័យ។

ជាក់ស្តែងក្នុងឆ្នាំ ២០២១ រដ្ឋបាលស្រុកបានបញ្ជូនមន្ត្រី ០១នាក់ ស្រី ០១ នាក់ ចូលរួមវគ្គវិក្រឹត្យការមន្ត្រីមធ្យម ជំនាញរដ្ឋបាលទូទៅ នៅសាលាភូមិន្ទរដ្ឋបាល។ ឆ្នាំ ២០២៣ រដ្ឋបាលស្រុកកបានបញ្ជូនមន្ត្រីចំនួន ០១នាក់ ចូលរៀលវគ្គសិក្សាកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ជំនាញត្រួតពិនិត្យ និងវាយតម្លៃ នៅសាលាជាតិផែនការ និងស្ថិតិ។[៣១]

<u>តារាងទី១០៖ ការកសាងសមត្ថភាព</u>

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | សរុប |
| ១ | វគ្គសិក្សា | ០ | ៣ | ០ | ៣០ | ៥៣ | ៨៦ |
| ២ | សិក្ខាកាមសរុបដែលបានចូលរួមវគ្គសិក្សា | ០ | ៦៥ | ០ | ៦៧ | ២០១ | ៣៣៣ |
| ៣ | សិក្ខាកាមជាស្ត្រីដែលបានចូលរួមវគ្គសិក្សា | ០ | ២៣ | ០ | ២៣ | ៤៥ | ៩១ |

[៣១] របាយការណ៍របស់ក្រុមប្រឹក្សាស្រុកមេមត់ អាណត្តិទី៣ ២០១៩-២០២៣, រដ្ឋបាលស្រុកមេមត់, បោះពុម្ព២០១៩

## ៣.៤. ការធ្វើផែនការ និងការគាំទ្រឃុំ

### ៣.៤.១. ការធ្វើផែនអភិវឌ្ឍន៍ប្រាំឆ្នាំ

រដ្ឋបាលស្រុកមេមត់ បានរៀបចំផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ[៣២] ដែលមានចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ ដោយផ្អែកលើការពិចារណា និងវាយតម្លៃសមស្រប មានភាពគ្រប់ជ្រុងជ្រោយ ផ្អែកលើសក្តានុពល ឧបសគ្គ ឬបញ្ហាប្រឈមដែលបានរកឃើញនៅក្នុងការវិភាគស្ថានភាពស្រុកក្នុងជំពូកទី១។ ដោយមានចក្ខុវិស័យអភិវឌ្ឍ សង្គមមួយ មាននិរន្តរភាពផ្តល់នូវបរិយាកាសប្រកបដោយសន្តិភាព សុវត្ថិភាព សុខុមាលភាពសង្គម លើកកម្ពស់សម្រាប់ការអភិឌ្ឍសង្គម និងសេដ្ឋកិច្ច និងលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ ជាពិសេសបានដាក់គោលដៅ និងគោលបំណងយ៉ាងច្បាស់ក្នុងការអភិវឌ្ឍ ផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ច វិស័យពាក់ពន្ធ័ ដូចជា ការគ្រប់គ្រងធនធានធម្មជាតិ និង ការងារផ្នែករដ្ឋបាលជាដើម។

### ៣.៤.២.គោលដៅ និង គោលបំណងក្នុងការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច

**រដ្ឋបាលស្រុកមេមត់មានគោលដៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចដូចជា៖**

- គោលដៅ បង្កើនបច្ចេកទេស ការដាំដុះ ការផលិតកាកែច្នៃនិងស្វែងរកទីផ្សារ លក់ផលិតផល ជូនកសិករ
- គោលដៅ កាត់បន្ថយការខ្ចីបុលពីអ្នកចងការប្រាក់ នៅក្នុងមូលដ្ឋាន
- គោលដៅ ជួសជុល ផ្លូវថ្នល់ ផ្លូវលំ ផ្លូវកៅស៊ូ និងផ្លូវចាក់បេតុង តាមទីសាធារណៈនៃប្រជុំជន និងជនបទ
- គោលដៅ ស្តារ និងសាងសងប្រឡាយអមផ្លូវតាមសាធារណៈ
- គោលដៅ ជំរុញឱ្យសិប្បកម្មមានការផលិតតាមបទដ្ឋានបច្ចេកទេសត្រឹមត្រូវពិសេសការផលិតទឹកបរិសុទ្ធ
- គោលដៅ ជំរុញ ការចិញ្ចឹមសត្វគោក្របី និងផ្តល់វគ្គបណ្តុះបណ្តាលដល់ប្រជាពលរដ្ឋ និងពេទ្យសត្វ។

[៣២] សៀវភៅផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ ឆ្នាំ២០២០-២០២៤ ស្រុកមេមត់ខេត្តត្បូងឃ្មុំ, រដ្ឋបាលស្រុកមេមត់, បោះពុម្ពឆ្នាំ២០២២

**រដ្ឋបាលស្រុកមេមត់មានគោលបំណងក្នុងការអភិវឌ្ឍសេដ្ឋកិច្ចដូចជា៖**

- គោលបំណង ឆ្នាំ ២០២៤ ប្រជាពលរដ្ឋរស់នៅក្នុងស្រុកមេមត់ មានជីវភាពប្រសើរឡើង ចំណូល ប្រចាំឆ្នាំកើនឡើង
- គោលបំណង ទូទាំងស្រុកនៅឆ្នាំ២០២៤មានផ្លូវគមនាគមន៍ចាំកែលម្អជួសជុលផ្លូវលំផ្លូវកៅស៊ូនិង ផ្លូវបេតុងក្នុងការជួយសម្រួល ដល់ការធ្វើដំណើរ របស់ប្រជាពលរដ្ឋ
- គោលបំណង នៅឆ្នាំ ២០២៤ ការផលិតសិប្បកម្ម និងសេវាកម្មនានា និងជួយជម្រុញឱ្យស្រុកទាំងមូលមានកំណើនសេដ្ឋកិច្ចនិងកាត់បន្ថយភាពក្រីក្រជូនប្រជាពលរដ្ឋ។

### ៣.៤.៣. គោលដៅ និងគោលបំណងអភិវឌ្ឍន៍ ផ្នែកសង្គមកិច្ច

**រដ្ឋបាលស្រុកមេមត់មានគោលគោលដៅក្នុងការអភិវឌ្ឍសង្គមកិច្ច ដូចជា៖**[៣៣]

- ផ្សព្វផ្សាយ និងចលនាជំរុញ ឱ្យអាណាព្យាបាលបញ្ជូនកុមារចូលរៀន សាលាមតេយ្យសិក្សានិងសាលាបឋមសិក្សាឱ្យបានគ្រប់គ្នា
- គោលដៅ ជំរុញឱ្យអ្នកជំងឺអេដស៍ មកពិនិត្យព្យាបាល មកបើកថ្នាំ ឱ្យបានទៀងទាត់
- គោលដៅ ដើម្បីលើកកម្ពស់សុខភាពប្រជាពលរដ្ឋ ឱ្យមានភាពប្រសើរឡើង តាមរយៈការអប់រំផ្សព្វផ្សាយ ពីជំងឺឆ្លង និងផ្តល់សេវាសុខភាពដែលមានគុណភាព
- គោលដៅ ពង្រឹង និងពង្រីកការផ្តល់សេវាសុខភាពឱ្យកាន់តែប្រសើរឡើង និងមានគុណភាព
- គោលដៅ កុមារក្រោមអាយុ៥ឆ្នាំ មានសុខភាពល្អ ទទួលបានអាហារូបត្ថម្ភគ្រប់គ្រាន់ និងចាក់ថ្នាំវ៉ាក់សាំងបានគ្រប់គ្រាន់
- គោលដៅ ស្ត្រីចំនួន៩០% នឹងទទួលបាននូវការការពារសុខភាព និងសុវត្ថិភាពក្នុងការសម្រាលកូន
- គោលដៅ  ជំរុញនិងផ្សព្វផ្សាយអំពីអនាម័យនៅតាមមូលដ្ឋានភូមិឃុំ
- គោលដៅ អប់រំដល់ប្រជាពលរដ្ឋឱ្យ មានការយល់ដឹងអំពីសុខភាព
- គោលដៅ ជំរុញ និងផ្សព្វផ្សាយអំពីជំងឺ គ្រុនចាញ់ និងជំងឺនានាដល់ប្រជាពលរដ្ឋ
- គោលដៅ ជំរុញ និងផ្សព្វផ្សាយឱ្យ អ្នកជំងឺទឹកនោមផ្អែម និងអ្នកជំងឺលើសឈាមមកទទួលសេវាព្យាបាលនៅមូលដ្ឋានសុខាភិបាល
- ជំរុញការជួសជុលអណ្តូងខូច និងបង្កើនការប្រើប្រាសទឹកស្អាតសម្រាប់ប្រជាជន

---

[៣៣] សៀវភៅផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ ឆ្នាំ២០២០-២០២៤ ស្រុកមេមត់ខេត្តត្បូងឃ្មុំ, រដ្ឋបាលស្រុកមេមត់, បោះពុម្ពឆ្នាំ២០២២

- គោលដៅ ជំរុញ និងបំផុស ពលរដ្ឋឱ្យយល់ដឹងអំពីការផ្តល់សេវាអនាម័យនៅតាមជនបទ
- គោលដៅ អប់រំ និងកាត់បន្ថយអំពើហឹង្សាក្នុងគ្រួសារ
- គោលដៅ  ទប់ស្កាត់ការជួញដូរ និងការរំលោភផ្លូវភេទលើស្ត្រី និងក្មេងស្រី
- គោលដៅ កាត់បន្ថយ និងទប់ស្កាត់ការធ្វើចំណាកស្រុក
- គោលដៅ ផ្សព្វផ្សាយ និងទប់ស្កាត់ការកេងប្រវ័ញ្ចពលកម្មលើកុមារ
- គោលដៅ បង្កើនការយល់ដឹងអំពីការអនុវត្តតួនាទីនិងភារកិច្ចរបស់អ្នកទទួល បន្ទុកកិច្ចការនារី និងកុមារឃុំ
- គោលដៅ ជំរុញឱ្យមានការអនុវត្តតួនាទីនិងភារកិច្ចរបស់គណៈកម្មការវត្តឱ្យបានល្អប្រសើរជាងមុន
- គោលដៅ អប់រំ និងផ្សព្វផ្សាយដល់ប្រជាពលរដ្ឋដើម្បីកាត់បន្ថយនូវអត្រាប្រជាពលរដ្ឋធ្វើចំណាកស្រុក
- គោលដៅ ផ្សព្វផ្សាយលើកកម្ពស់សមភាពយេនឌ័រ ផ្តល់ឱ្យស្ត្រីចូលរួមគ្រប់សកម្មភាពនានានៅក្នុងសង្គមហើយនិងច្បាប់នានា
- ផ្តល់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់អ្នកបាត់ឱកាសការងារក្រីក្រ ជនពិការ ហើយបង្កើនមុខរបរដល់ប្រជាពលរដ្ឋនៅក្នុងសហគមន៍។

**រដ្ឋបាលស្រុកមេមត់មានគោលបំណងក្នុងការអភិវឌ្ឍសង្គមកិច្ច ដូចជា៖**[៣៨]

- គោលបំណង នៅឆ្នាំ២០២៤ក្នុងស្រុកមេមត់ វិស័យអប់រំទទួលបានសេវាប្រកបដោយគុណភាព និងប្រសិទ្ធភាពនៅគ្រប់កម្រិតទាំងអស់
- គោលបំណង នៅឆ្នាំ២០២៤ ក្នុងស្រុកមេមត់ វិស័យសុខាភិបាល ទទួលបានសេវាប្រកបដោយគុណភាព និងប្រសិទ្ធភាព ហើយសុខុមាលភាពរបស់ប្រជាពលរដ្ឋត្រូវបានលើកកម្ពស់ និងកាត់បន្ថយហានិភ័យ
- គោលបំណង នៅឆ្នាំ២០២០-២០២៤ នៅស្រុកមេមត់ មានការជួសជុល និងការថែទាំប្រព័ន្ធផ្គត់ ផ្គង់ទឹកស្អាត ព្រមទាំងការផ្តល់សេវាអនាម័យជនបទ
- គោលបំណង នៅឆ្នាំ២០២៤ ស្ត្រីត្រូវបានលើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាច ដល់ស្ត្រី ក្នុងការធ្វើសេចក្តីសម្រេចកាន់តែខ្ពស់

[៣៨] សៀវភៅផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ ឆ្នាំ២០២០-២០២៤ ស្រុកមេមត់ខេត្តត្បូងឃ្មុំ, រដ្ឋបាលស្រុកមេមត់, បោះពុម្ពឆ្នាំ២០២២

- គោលបំណង នៅឆ្នាំ២០០២៤ ក្នុងស្រុកមេមត់ វិស័យព្រះពុទ្ធសាសនា និងកិច្ចការធម្មការត្រូវបាន ពង្រឹង និងកែលំអទាំងបរិមាណ និងគុណភាព
- គោលបំណង នៅឆ្នាំ២០២៤ ក្នុងស្រុកមេមត់ និងមានការថយចុះ នូវចំណាកស្រុកទៅក្រៅស្រុក
- គោលបំណង នៅឆ្នាំ២០២៤ ក្នុងស្រុកមេមត់ លើកកម្ពស់សមភាពយេនឌ័រ និងបង្កើនមុខរបរដល់ ប្រជាពលរដ្ឋនៅក្នុងសហគមន៍។

### ៣.៤.៤. គោលបំណងអភិវឌ្ឍន៍ ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់

**រដ្ឋបាលស្រុកមេមត់មានគោលដៅក្នុងការអភិវឌ្ឍផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់ដូចខាង ក្រោម៖**[៣៥]

- គោលដៅ ផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី និងសម្របសម្រួលទំនាស់ដីធ្លីជូនប្រជាពលរដ្ឋ
- គោលដៅ ជំរុញឱ្យអ្នកម៉ៅការសំរាមទុកដាក់កាកសំណល់រឹងឱ្យបានត្រឹមត្រូវ
- គោលដៅ ជំរុញឱ្យអាជ្ញាធរ និងប្រជាពលរដ្ឋចេះការពារធនធានធម្មជាតិសហគមន៍
- គោលដៅ បង្កើនថ្នាលសំរាប់ដាំកូនឈើដើម្បីចែកប្រជាពលរដ្ឋ។
- គោលដៅ ជំរុញឱ្យមានការផ្សព្វផ្សាយអំពីច្បាប់ព្រៃឈើនិងលិខិតបទដ្ឋានពាក់ព័ន្ធជូនប្រជាពលរដ្ឋ
- គោលដៅ ទប់ស្កាត់បទល្មើសព្រៃឈើសត្វព្រៃនិងការកាប់រុករានដុតឈូសឆាយវាតយកដីព្រៃឈើ។
- គោលដៅ ជំរុញឱ្យមានការចូលរួមការគ្រប់គ្រងព្រៃឈើតាមរូបភាពសហគមន៍ឈើឱ្យមានភាពប្រសើរ ឡើង។
- គោលដៅ ពង្រឹងការគ្រប់គ្រង និងការពារបរិស្ថាននានានៅក្នុងឃុំ
- គោលដៅ ជំរុញការរុករកមីន និងយុទ្ធភ័ណ្ឌមិនទាន់ ផ្ទុះ ធ្វើឱ្យប្រជាពលរដ្ឋទទួលបានសុខ សុវត្ថិភាព ក្នុងការរស់នៅ
- គោលដៅ អភិវឌ្ឍន៍ ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ
- គោលដៅ ពង្រឹងការចុះបញ្ជីអត្រានុកូលដ្ឋានប្រកបដោយ គុណភាព គណនេយ្យ និងតម្លាភាព
- គោលដៅ យល់ដឹងពីច្បាប់ចរាចរណ៍ការដឹកជញ្ជូននិងការពារសុវត្ថិភាពសម្រាប់ការបើកបរ
- គោលដៅ ផ្សព្វផ្សាយ និងជំរុញការអនុវត្តចរាចរណ៍ផ្លូវគោកមានភាពប្រសើរឡើង
- គោលដៅ ផ្សព្វផ្សាយនិងទប់ស្កាត់ក្មេងទំនើងចោរកម្មគ្រឿងញៀន

---

[៣៥] សៀវភៅផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ ឆ្នាំ២០២០-២០២៤ ស្រុកមេមត់ខេត្តត្បូងឃ្មុំ, រដ្ឋបាលស្រុកមេមត់, បោះពុម្ពឆ្នាំ២០២២

- គោលដៅ ពង្រឹងប្រជាការពារ និងបង្កើតប៉ុស្តិ៍យាមតាមភូមិ និងផ្សព្វផ្សាយនូវច្បាប់នានាក្នុង ការអនុវត្ត គោលនយោបាយភូមិឃុំមានសុវត្ថិភាពឱ្យមានប្រសិទ្ធភាព
- គោលដៅ ក្រុមប្រឹក្សាឃុំ និងមន្ត្រីរាជការស៊ីវិលក្នុងរចនាសម្ព័ន្ធស្រុកមានសមត្ថភាពគ្រប់គ្រាន់ក្នុងការ អនុវត្តការងារប្រកដោយប្រសិទ្ធភាព
- គោលដៅ បង្កើនការយល់ដឹងដល់ក្រុមប្រឹក្សាឃុំមួយចំនួនបន្ថែមទៀត
- គោលដៅ ពង្រឹងសមត្ថភាពមន្ត្រីទាំងចាស់ និងថ្មីក្នុងការទទួលខុសត្រូវលើកិច្ចការងារបញ្ជី អត្រានុកូលដ្ឋានគ្រប់ប្រភេទថ្នាក់ខេត្ត
- គោលដៅ ពង្រឹងការចុះពិនិត្យ និងតាមដានកិច្ចការងារបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទ
- គោលដៅ ជំរុញការរៀបចំរបាយការណ៍ការងារអត្រានុកូលដ្ឋាន ប្រកបដោយប្រសិទ្ធភាព
- គោលដៅ បង្កើនការគ្រប់គ្រងឯកសារអត្រានុកូលដ្ឋានរដ្ឋបាលឃុំ ឱ្យមានភាពប្រសើរឡើង។

**រដ្ឋបាលស្រុកមេមត់មានបំណងក្នុងការអភិវឌ្ឍផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់ដូចជា៖**

- គោលបំណង នៅឆ្នាំ២០២៤ សេវាសាធារណៈ និងត្រូវបានផ្តល់ជូនប្រជាពលរដ្ឋគ្រប់ៗគ្នាប្រកបដោយ មាន គុណភាពរហ័សទាន់ពេលវេលានិងតម្លាភាព
- គោលលបំណង នៅឆ្នាំ២០២៤ នៅស្រុកមេមត់ប្រជាជននិងគោរពច្បាប់ចរាចរណ៍និងយល់ដឹងពីការ បើកបររបស់ខ្លួន
- គោលបំណង នៅឆ្នាំ២០២៤ នៅស្រុកមេមត់ប្រជាពលរដ្ឋរស់នៅប្រកបដោយសេចក្តីសុខ និងសុវត្ថិ ភាព គ្មានបទល្មើសនានាក្មេងទំនើងចោរកម្មគ្រឿងញៀននឹងត្រូវបានកាត់បន្ថយជាបន្តបន្ទាប់
- គោលបំណង នៅឆ្នាំ២០២៤ នៅក្នុងរដ្ឋបាលស្រុកមេមត់ ក្រុមប្រឹក្សាស្រុក និងមន្ត្រីរាជការស៊ីវិលក្នុង រចនាសម្ព័ន្ធស្រុកមានសមត្ថភាពគ្រប់គ្រាន់ និងអនុវត្តការងារមានប្រសិទ្ធភាពខ្ពស់
- គោលបំណង នៅឆ្នាំ២០២៤ ក្នុងក្រុមប្រឹក្សាឃុំ និងគណៈកម្មការនានាក្រុមប្រឹក្សាឃុំ នឹងមានសមត្ថ ភាពកាន់តែប្រសើរឡើង
- គោលបំណង ជំរុញប្រសិទ្ធភាពការងារចុះបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទ រួមទាំងការផ្តល់សេវានានា ឱ្យកាន់តែល្អប្រសើរឡើង។

### ៣.៤.៥. យុទ្ធសាស្ត្រក្នុងការអភិវឌ្ឍ

ដើម្បីឱ្យសម្រេចឱ្យបាននូវគោលបំណង និងគោលដៅក្នុងផែនការអភិវឌ្ឍន៍ប្រាំឆ្នាំនេះ រដ្ឋបាលស្រុកមានយុទ្ធសាស្ត្រអភិវឌ្ឍន៍មានខាងក្រោម៖[៣៦]

#### យុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ច

ចំណុចនេះរដ្ឋបាលស្រុកបានរៀបចំជាយុទ្ធសាស្ត្រនានាសម្រាប់អភិវឌ្ឍន៍របស់បណ្តាវិស័យក្នុងផ្នែកសេដ្ឋកិច្ច ដើម្បីចូលរួមចំណែកក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍របស់ស្រុក៖

- បណ្តុះបណ្តាលស្តីអំពីបច្ចេកទេសការដាំដុះដំឡូងមីនិងដំណាំហូបផ្លែ
- បណ្តុះបណ្តាលស្តីអំពីបច្ចេកទេសការដាំដុះម្រេច
- បណ្តុះបណ្តាលស្តីអំពីបច្ចេកទេសការដាំដុះកៅស៊ូ
- អប់រំផ្សព្វផ្សាយកិច្ចសន្យានិងពត៌មានទីផ្សារផលិតដល់កសិករ
- បង្កើនយន្តការការផលិត ផ្សារលក់ចេញនិងមុខរបរការងារឱ្យបានច្រើនជូនកសិករ
- ជំរុញឱ្យកសិករមានសេវាដឹកជញ្ជូនដោយខ្លួនឯងដោយយានយន្ត
- ជួសជុលផ្លូវថ្លូវក្រាលគ្រួសក្រហមចាស់ដែលទ្រុឌទ្រោម
- ជួសជុលផ្លូវបេតុងចាស់ដែលទ្រុឌទ្រោម
- ជួសជុលផ្លូវកៅស៊ូចាស់ដែលទ្រុឌទ្រោម
- សាងសង់ផ្លូវបេតុងអាមេថ្មី សាងសង់ផ្លូវកៅស៊ូថ្មី សាងសង់ផ្លូវក្រាលក្រួសក្រហមថ្មី និងសាងសង់ប្រឡាយអមសងខាងផ្លូវ
- ស្តារប្រឡាយអមផ្លូវចាស់ និងសង់លូរំដោះទឹក
- ជំរុញ និងលើកទឹកចិត្ត ដល់ម្ចាស់ សិប្បកម្ម និងសេវាកម្ម ជ្រើសរើស បុគ្គលិក និងបណ្តុះ បណ្តាលឱ្យមាន ជំនាញច្បាស់លាស់។
- ណែនាំដល់ម្ចាស់ក្រុមហ៊ុននិងសិប្បកម្មឱ្យមានការផលិតតាមបែបបច្ចេកទេសត្រឹមត្រូវ
- វគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមគោក្របី ចាក់វ៉ាក់សាំងគោក្របី
- បណ្តុះបណ្តាលពង្រឹងសមត្ថភាពភ្នាក់ងារពេទ្យសត្វភូមិ។

---

[៣៦] សៀវភៅផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ ឆ្នាំ២០២០-២០២៤ ស្រុកមេមត់ខេត្តត្បូងឃ្មុំ, រដ្ឋបាលស្រុកមេមត់, បោះពុម្ពឆ្នាំ២០២២

**យុទ្ធសាស្ត្រអភិវឌ្ឍន៍សង្គមកិច្ច**

ចំណុចនេះរដ្ឋបាលស្រុកបានរៀបចំជាយុទ្ធសាស្ត្រនានាសម្រាប់អភិវឌ្ឍន៍របស់បណ្តាវិស័យក្នុងផ្នែកសង្គមកិច្ច ដើម្បីចូលរួមចំណែកក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍របស់ស្រុក៖

- កសាងមត្តេយ្យសិក្សាសហគមន៍ នៅភូមិដែលឆ្ងាយនិងពុំទាន់មានមត្តេយ្យសហគមន៍
- ជ្រើសរើសគ្រូបន្ថែមសម្រាប់មត្តេយ្យសិក្សាសហគមន៍
- ជួសជុលសាលារៀនចាស់ដែរទ្រុឌទ្រោម
- សាងសង់អគារសាលារៀនថ្មី
- អប់រំអាណាព្យាបាលឱ្យយល់ពីអត្ថប្រយោជន៍នៃការសិក្សា
- ផ្តល់អាហារូបត្ថម្ភដល់សិស្សក្រីក្រចាប់ពីថ្នាក់បឋម ដល់វិទ្យាល័យ
- លើកទឹកចិត្តនិងឧបត្ថម្ភថ្លៃធ្វើដំណើរដល់អ្នកដែលមកបើកថ្នាំ
- អប់រំនិងផ្សព្វផ្សាយអំពីការថែទាំសុខភាពដល់អ្នកជំងឺអេដស៍
- អប់រំសុខភាពអនាម័យនៅមូលដ្ឋាន
- ផ្សព្វផ្សាយពីសុវត្ថិភាពចំណីអាហារ
- បង្កើនការយល់ដឹងដល់សហគមន៍ស្តីពីជំងឺឆ្លងនិងមិនឆ្លង
- អប់រំកម្មវិធីកាត់បន្ថយជំងឺគ្រុនចាញ់
- អប់រំផ្សព្វផ្សាយពីផលប៉ះពាល់ពីជំងឺឆ្លង (អេដស៍ របេង)
- ស្នើសុំឆ្មបមធ្យម និងគ្រូពេទ្យបន្ថែមក្នុងមន្ទីរពេទ្យ និងមណ្ឌលសុខភាព
- សាងសង់អគាររង់ចាំសុខាភិបាល
- សាងសង់អគារមន្ទីរពេទ្យឱ្យបានគ្រប់គ្រាន់
- ពង្រឹងបន្ថែម ការផ្តល់សេវានៅមូលដ្ឋានសុខាភិបាលនិងមូលដ្ឋានផ្ទាល់
- ផ្តល់ថ្នាំបង្ការដល់កុមារបានគ្រប់ចំនួន
- ផ្សព្វផ្សាយដល់ស្ត្រីមានផ្ទៃពោះទៅពិនិត្យសុខភាពនៅមណ្ឌលឱ្យបានគ្រប់ចំនួននិងសម្រាលនៅមណ្ឌលសុខភាព។
- ផ្តល់ថ្លៃធ្វើដំណើរនិងអាហារដល់ស្ត្រីមានផ្ទៃពោះក្រីក្រអំឡុងពេលសំរាល និងសំរាលនៅមណ្ឌលសុខភាព
- ផ្សព្វផ្សាយពីសុវត្ថិភាពចំណីអាហារ

- អប់រំផ្សព្វផ្សាយយល់ដឹងពីអាហារូបត្ថម្ភដល់ប្រជាពលរដ្ឋ
- ផ្សព្វផ្សាយអនាម័យជូនប្រជាពលរដ្ឋនៅតាមភូមិឃុំ។

**យុទ្ធសាស្ត្រគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ**

ចំណុចនេះ រដ្ឋបាលស្រុកបានរៀបចំជាយុទ្ធសាស្ត្រនានាសម្រាប់អភិវឌ្ឍរបស់បណ្តាវិស័យក្នុងផ្នែកគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ដើម្បីចូលរួមចំណែកក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍របស់ស្រុក៖[៣៧]

- ផ្តល់ឯកសារនិងទំរង់នានាអំពីការងារអត្រានុកូលដ្ឋានឱ្យបានគ្រប់ៗគ្នា
- ទប់ស្កាត់ការដឹកជញ្ជូនលើសទំងន់
- ជំរុញឱ្យម្ចាស់យានយន្តដែលដឹកទំនិញឱ្យមានប័ណ្ណបើកបរត្រឹមត្រូវ
- ផ្សព្វផ្សាយច្បាប់ចរាចរណ៍ផ្លូវគោកដាក់ស្លាកចរាចរណ៍បន្ថែមលើផ្លូវ
- អប់រំផ្សព្វផ្សាយអ្នកប្រើប្រាស់គ្រឿងញៀននិងអាណាព្យាបាល
- អប់រំកុំឱ្យមានការសប្បាយភ្លើតភ្លើនតាមគ្នានៅក្នុងមូលដ្ឋាន
- ចុះត្រួតពិនិត្យរដ្ឋបាលចំហនៅតាមមូលដ្ឋាន
- ផ្សព្វផ្សាយ និងជំរុញបង្ក្រាបល្បែងស៊ីសង ផ្សព្វផ្សាយពីច្បាប់គ្រឿងញៀន
- ផ្សព្វផ្សាយពីគោលនយោបាយភូមិឃុំមានសុវត្ថិភាព
- ផ្សព្វផ្សាយច្បាប់សន្តិសុខសណ្តាប់ធ្នាប់ក្នុងមូលដ្ឋាន
- វគ្គបណ្តុះបណ្តាលដល់មន្ត្រីស្រុកក្នុងរចនាសម្ព័ន្ធស្រុកស្តីពីតួនាទី និងភារកិច្ចវគ្គបណ្តុះបណ្តាលដល់ក្រុមប្រឹក្សាស្រុក ស្តីពីតួនាទី និងភារកិច្ច
- វគ្គបណ្តុះបណ្តាលដល់មន្ត្រីស្រុកក្នុងរចនាសម្ព័ន្ធស្រុកស្តីពីប្រព័ន្ធព័ត៌មានវិទ្យា
- វគ្គបណ្តុះបណ្តាលដល់គ.ក.ស.ក ស្តីពីតួនាទី និងភារកិច្ច
- ដំណើរទស្សនៈកិច្ចសិក្សាប្រចាំឆ្នាំរបស់មន្ត្រីរាជការ
- វគ្គបណ្តុះបណ្តាលបង្កើនសមត្ថភាពដល់សមាជិកក្រុមប្រឹក្សាឃុំ
- វគ្គបណ្តុះបណ្តាលបង្កើនសមត្ថភាពដល់កិច្ចការនារីឃុំ
- បណ្តុះបណ្តាលដល់មន្ត្រីចាស់ និងថ្មីលើកិច្ចការងារអត្រានុកូលដ្ឋានប្រចាំឆ្នាំ

[៣៧] សៀវភៅផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ ឆ្នាំ២០២០-២០២៤ ស្រុកមេមត់ខេត្តត្បូងឃ្មុំ, រដ្ឋបាលស្រុកមេមត់, បោះពុម្ពឆ្នាំ២០២២

- បណ្តុះបណ្តាលដល់មន្ត្រីថ្នាក់ឃុំឱ្យមានទាំងចំណេះដឹងការងារអគ្រានុកូលដ្ឋាន។

### ៣.៤.៦. កម្មវិធីវិនិយោគបីឆ្នាំរំកិល

កម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុកមេមត់ ត្រូវបានរៀបចំឡើងដោយក្រុមប្រឹក្សាស្រុកមេមត់ និងក្រុមការងារកសាងផែនការស្រុក ក្រោយពីទទួលការអនុម្ញាតភាពពីរដ្ឋបាលខេត្តនូវផែនការអភិវឌ្ឍន៍ប្រាំឆ្នាំរួចមក ក្រុមប្រឹក្សាស្រុក និងរដ្ឋបាលស្រុកសេនាធិការ ដែលជាអ្នកទទួលខុសត្រូវរួមជាមួយនឹងយន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើកិច្ចអនុវត្តជាក់ស្តែង ទៅតាមជំហាននីមួយៗសម្រាប់កម្មវិធីវិនិយោគបីឆ្នាំរំកិលនេះ។[៣៨]

រដ្ឋបាលស្រុកត្រូវរៀបចំ ការងារវាយតម្លៃ ការអនុវត្តកម្មវិធីវិនិយោគ នៅពាក់កណ្តាលឆ្នាំនីមួយៗ របស់កម្មវិធីវិនិយោគ ដើម្បីវាយតម្លៃលទ្ធផល ធៀបទៅនិងផែនការគោលដៅ និងគោលបំណងដែលបានកំណត់ក្នុងសៀវភៅកម្មវិធីវិនិយោគ។

ការតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល គឺជាសកម្មភាពផ្តោតលើការសន្និដ្ឋានពីស្ថានភាព និងលទ្ធផលនៃការអនុវត្ត ៖

- គម្រោង សកម្មភាពកំពុងដំណើរការ
- គម្រោង សកម្មភាពមានថវិកាគាំទ្រ
- គម្រោង សកម្មភាពអាទិភាពដែលមិនទាន់មានថវិកាគាំទ្រ
- តើមានការគាំទ្រគម្រោង សកម្មភាពថ្មីបន្ថែមក្រៅពីគម្រោង សកម្មភាពអាទិភាពមិនទាន់មានការសន្យាគាំទ្រ ឬទេ?
- កម្មវិធីប្រតិបត្តិការសេវារដ្ឋបាលរបស់រដ្ឋបាលស្រុក និងរបស់ការិយាល័យជំនាញ
- ការដាក់ចេញលិខិតបទដ្ឋានគតិយុត្តនានា។

### ៣.៤.៧. ការរៀបចំផែនការគម្រោង

ក្រុមប្រឹក្សាស្រុកមេមត់បានរៀបចំសៀវភៅផែនការ៥ឆ្នាំ ចំនួន២ដង ពីឆ្នាំ២០១៥-២០១៩ និងឆ្នាំ២០២០-២០២៥ និងបានរៀបចំសៀវភៅកម្មវិធីវិនិយោគ៣ឆ្នាំរំកិលចំនួន ៥ដង ទី១ ចាប់ពីឆ្នាំ២០១៥-២០១៧, ទី២ ចាប់ពីឆ្នាំ២០១៦-២០១៨, ទី៣ ចាប់បីឆ្នាំ២០១៧-២០១៩, ទី៤ចាប់ពីឆ្នាំ២០១៨-២០២០ និងទី៥ ចាប់ពី

[៣៨] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល ២០២២-២០២៤ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ, រដ្ឋបាលស្រុកមេមត់, បោះពុម្ពឆ្នាំ២០២២

ឆ្នាំ២០២០-២០២៥ ដោយមានការពិគ្រោះយោបល់ពីគណៈកម្មាធិការ សម្របសម្រួលបច្ចេកទេសស្រុក និង គណៈអភិបាលស្រុក និងចុងក្រោយត្រូវបានពិនិត្យ និងអនុម័តដោយក្រុមប្រឹក្សាស្រុក។[៣៩]

## តារាងទី៧ ចំនួនគម្រោង និងថវិកាដែលគ្រោងវិនិយោគ

| ល.រ | ការបរិយាយ | ចំនួនគម្រោង និងថវិកាវិនិយោគ | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ២០១៩ | | ២០២០ | | ២០២១ | | ២០២២ | | ២០២៣ | |
| | | ចំនួន | តម្លៃ | ចំនួន | តម្លៃ | ចំនួន | តម្លៃ | ចំនួន | តម្លៃ | ចំនួន | តម្លៃ |
| ១ | សេដ្ឋកិច្ច | ៧ | ១.៧២ | ១០ | ១.៧២ | ១១ | ១០.៥ | ១១ | ១៣.៧ | ៨ | ១០.៦ |
| ២ | សង្គមកិច្ច | ១៥ | ៩១៧ | ១៧ | ១.០៩ | ២៧ | ១១.៤ | ២៧ | ៦.៦៨ | ៤២ | ៦.៨៤ |
| ៣ | គ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន | ១១ | ៤.០៨ | ១១ | ៤.០៨ | ១១ | ៤.០៨ | ១១ | ៤.០៨ | ១១ | ៤.០៨ |
| ៤ | រដ្ឋបាល សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ | ៣ | ៩០ | ៣ | ៩០ | ៧ | ១.៤២ | ៩ | ៧១០ | ៩ | ៧១០ |
| សរុប | | ៣៦ | ៦.៨១៥ | ៤១ | ៦.៨១ | ៥៦ | ២៧.៣ | ៥៨ | ២៥.២ | ៧០ | ២២.២ |

[៣៩] របាយការណ៍របស់ក្រុមប្រឹក្សាស្រុកមេមត់ អាណត្តិទី៣ ២០១៩-២០២៣, រដ្ឋបាលស្រុកមេមត់, បោះពុម្ព២០១៩

### ៣.៤.៨. ការអនុវត្តផែនការគម្រោង

ឆ្លើយតបទៅនឹងការរៀបចំគម្រោងថវិកា និងគម្រោងវិនិយោគតាមឆ្នាំនីមួយៗត្រូវបានប្រើប្រាស់ពីប្រភពថវិកាបស់ស្រុកផ្ទាល់ ឬថវិកាពីដៃគូអភិវឌ្ឍនានា ដែលត្រូវបានរាប់បញ្ចូលតាមផ្នែកនីមួយៗ។ ជាងនេះក៏មានការគាំទ្រពីមន្ទីរនានា និងការិយាល័យជំនាញក្នុងស្រុកដោយបានគាំទ្រសកម្មភាពរបស់ខ្លួនដល់រដ្ឋបាលស្រុកមេមត់ៗ[៤០]

<u>តារាងទី៨ ចំនួនគម្រោង និងថវិកាដែលបានអនុវត្ត</u>

| ល.រ | ការបរិយាយ | ចំនួនគម្រោង និងថវិកាវិនិយោគ | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ២០១៩ | | ២០២០ | | ២០២១ | | ២០២២ | | ២០២៣ | |
| | | ចំនួន | តម្លៃ | ចំនួន | តម្លៃ | ចំនួន | តម្លៃ | ចំនួន | តម្លៃ | ចំនួន | តម្លៃ |
| ១ | សេដ្ឋកិច្ច | 1 | 343,994,900 | 1 | 485,378,050 | 1 | 351,601,200 | 1 | 657,195,700 | 1 | 921,000,000 |
| ២ | សង្គមកិច្ច | 1 | 11,000,000 | 0 | 0 | 1 | 103,222,870 | 0 | 0 | 1 | 24,491,300 |
| ៣ | គ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| ៤ | រដ្ឋបាល សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |

[៤០] របាយការណ៍របស់ក្រុមប្រឹក្សាស្រុកមេមត់ អាណត្តិទី៣ ២០១៩-២០២៣, រដ្ឋបាលស្រុកមេមត់, បោះពុម្ព២០១៩

### ៣.៤.៩. ការគាំទ្រឃុំ សង្កាត់

ជាមួយនឹងការគាំទ្រទៅដល់ឃុំ ស្រុកមានការិយាល័យផែនការ និងគាំទ្រឃុំ ដែលជាការិយាល័យចំណុះ របស់សាលាស្រុក ដើម្បីជួយសម្របសម្រួលជាមួយក្រុមប្រឹក្សាឃុំ ក្នុងការរៀបចំផែនការ៥ឆ្នាំ របស់ក្រុមប្រឹក្សាឃុំ) និងកម្មវិធីវិនិយោគ ៣ឆ្នាំរំកិល ក្រៅពីនេះ ដោយមានការិយាល័យ ផែនការនិងគាំទ្រឃុំ បានជួយសម្របសម្រួលរៀបចំផែនការថវិកាប្រចាំឆ្នាំរបស់ឃុំរៀបចំការបិទបញ្ជីថវិកាប្រចាំឆ្នាំ។ សម្របសម្រួលរៀបចំការបង្កើតគណៈកម្មាការគ្រប់គ្រងគម្រោង គណៈកម្មាការលទ្ធកម្ម និងការសិក្សា និងត្រួតពិនិត្យ គម្រោង។ ជួយសម្របសម្រួលរៀបចំផែនការថវិកា និងផែនការសកម្មភាពប្រចាំឆ្នាំរបស់ គណៈកម្មាធិការទទួលបន្ទុក កិច្ចការនារី និងកុមារឃុំដំណើរកាបានល្អ និងគណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ។ ជាពិសេសសម្រួលដល់ឃុំសង្កាត់ដូចជាៈ[៤១]

- សម្របសម្រួល និងគាំទ្ររដ្ឋបាលឃុំក្នុងការប្រមូលបញ្ហា តម្រូវការនិងទិន្នន័យព្រមទាំងវិភាគស្ថានភាពសម្រាប់ការរៀបចំផែនការ០៥ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ។
- សម្របសម្រួល និងគាំទ្ររដ្ឋបាលឃុំក្នុងការរៀបចំ និងអនុវត្តផែនការ៥ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ
- សម្របសម្រួល និងផ្តល់ការគាំទ្របច្ចេកទេសក្នុងការរៀបចំ និងអនុវត្តគម្រោងឃុំ
- តាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគម្រោង ឬផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ
- សម្របសម្រួល និងដោះស្រាយសំណើ សំណូមពរ និងបញ្ហាប្រឈមនានារបស់ឃុំ

| ឆ្នាំ | ចំណូល (គិតជារៀល) | | | ចំណាយ (គិតជារៀល) | | |
|---|---|---|---|---|---|---|
| | អនុម័ត | ជាក់ស្តែង | % | អនុម័ត | ជាក់ស្តែង | % |
| ២០១៩ | 6,998,022,377 | 6,342,554,229 | 91% | 6,998,150,377 | 5,763,639,436 | 82% |
| ២០២០ | 7,951,839,543 | 7,420,861,845 | 93% | 8,458,930,474 | 5,063,251,219 | 60% |

[៤១] របាយការណ៍របស់ក្រុមប្រឹក្សាស្រុកមេមត់ អាណត្តិទី៣ ២០១៩-២០២៣, រដ្ឋបាលស្រុកមេមត់, បោះពុម្ព២០១៩

| | | | | | | |
|---|---|---|---|---|---|---|
| ២០២១ | 9,438,729,551 | 8,789,035,144 | 93% | 10,538,817,957 | 8,255,591,769 | 78% |
| ២០២២ | 10,103,612,909 | 9,397,185,609 | 93% | 11,153,526,553 | 7,409,433,364 | 73% |
| ២០២៣ | 11,718,707,055 | 8,625,390,402 | 74% | 12,635,973,678 | 9,274,509,390 | 72% |

### ៣.៤.១០. ការងារលទ្ធកម្ម

ការអនុវត្តការងារលិទ្ធកម្មរយៈពេល៥ឆ្នាំរបស់រដ្ឋបាលស្រុកមេមត់ រួមមានទាំងការងារអភិវឌ្ឍន៍ សំណង់ និងទំនិញជាច្រើនក្នុងការបំពេញនូវការចាំបាច់ដល់ការបម្រើសេវាសាធារណៈដែលមានដូចខាងក្រោម៖[៤២]

<u>តារាងទី១៣ ៖ ការធ្វើលទ្ធកម្មគម្រោង</u>

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | សរុប |
| ១ | គម្រោងដែលបានធ្វើលទ្ធកម្ម | ៥ | ៤ | ៥ | ៥ | ៥ | ៦៨ |
| ២ | តម្លៃកិច្ចសន្យាគម្រោង | ៣៦៧,០០០,០០០ | ៥២៦,០០០,០០០ | ៤៦៤,៦៨៣,០០០ | ៧៥២,៣៧៩,០០ | ១,០១៩,០០៩,៣០០ | ៣,១២៩,០៧១,៣០០ |
| ៣ | ក្រុមហ៊ុនដែលបានចូលរួមដេញថ្លៃ | ១៥ | ១២ | ១៥ | ១៥ | ១៥ | ៧២ |

[៤២] របាយការណ៍របស់ក្រុមប្រឹក្សាស្រុកមេមត់ អាណត្តិទី៣ ២០១៩-២០២៣, រដ្ឋបាលស្រុកមេមត់, បោះពុម្ព២០១៩

## ៣.៥. ហិរញ្ញវត្ថុរដ្ឋបាលស្រុកមេមត់

### ៣.៥.១. ការអនុវត្តចំណូល និងចំណាយ

ចំណូល និងចំណាយរបស់រដ្ឋបាលស្រុកមេមត់ក្នុងរយៈពេល ៥ឆ្នាំនេះ៖

តារាងទី១១៖ ការកសាងសម្ថភាព

| ឆ្នាំ | ចំណូល (គិតជារៀល) | | | ចំណាយ (គិតជារៀល) | | |
|---|---|---|---|---|---|---|
| | អនុម័ត | ជាក់ស្តែង | % | អនុម័ត | ជាក់ស្តែង | % |
| ២០១៩ | 1,227,000,000 | 1,283,855,500 | 104.63 | 1,289,200,000 | 1,250,808,850 | 97.02 |
| ២០២០ | 1,473,000,000 | 1,609,557,500 | 109.27 | 1,580,800,000 | 1,549,127,060 | 98.00 |
| ២០២១ | 2,141,600,000 | 2,235,941,260 | 104.41 | 2,231,280,000 | 2,210,406,010 | 99.06 |
| ២០២២ | 2,506,660,000 | 2,592,880,000 | 103.44 | 2,593,460,000 | 2,556,433,900 | 98.57 |
| ២០២៣ | 2,884,020,000 | 2,968,701,020 | 102.94 | 3,033,820,000 | 2,958,596,870 | 97.52 |
| សរុប | 10,232,280,000 | 10,690,935,280 | 104.48 | 10,728,560,000 | 10,525,372,690 | 98.11 |

### ៣.៥.២. ការគ្រប់គ្រងទ្រព្យសម្បត្តិ

ចំណែកឯការគ្រប់គ្រងទ្រព្យសម្បត្តិវិញរដ្ឋបាលស្រុកមេមត់មានដូចជា៖[៤៣]

តារាងទី១២៖ ការគ្រប់គ្រងទ្រព្យសម្បត្តិ

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | សរុប |
| ១ | ទ្រព្យសម្បត្តិដែលបានទិញ ឬ ទទួលថ្មី | ១៨ | ២២ | ៩ | ១២ | ៧ | ៦៨ |

[៤៣] របាយការណ៍របស់ក្រុមប្រឹក្សាស្រុកមេមត់ អាណត្តិទី៣ ២០១៩-២០២៣, រដ្ឋបាលស្រុកមេមត់, បោះពុម្ព២០១៩

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២ | ទ្រព្យសម្បត្តិដែលកាត់ចេញ | 0 | 0 | 0 | 0 | 0 | 0 |
| ៣ | ទ្រព្យសម្បត្តិសរុប | ២៧៤ | ២៩៦ | ៣០៦ | ១៣៧ | ៣២៤ | ១៣៣៦ |

## ៣.៦. ការងាររដ្ឋបាល

### ៣.៦.១. ការគ្រប់គ្រងអត្រានុកូលដ្ឋាន

រដ្ឋបាលស្រុកមេមត់បានចេញនូវឯកសារអត្រានុកូលដ្ឋាន តាមការស្នើសុំ និងតាមតម្រូវការប្រជាពលរដ្ឋ ដូចជា សេចក្តីចម្លងសំបុត្រកំណើត សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ សេចក្តីចម្លងសំបុត្រមរណភាព ដែលសរុបទាំងអស់ស្មើនឹង ៣៨៩៨៧ច្បាប់។[44]

<u>តារាងទី៣៖ ការចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន</u>

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | សរុប |
| ១ | សេចក្តីចម្លងសំបុត្រកំណើត | ១៧២១ | ៦៨៣ | ១០១១ | ១៨០១ | ៩៨៧ | ៦២០៣ |
| ២ | សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត | ៤៧៨៥ | ៤៥០៨ | ៤៦៤០ | ៩១១៣ | ៤៧៨៥ | ២៧៨៣១ |
| ៣ | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ | ១៤៣ | ៨៨ | ១០០ | ៣០៨ | ១២៤ | ៧៦៣ |
| ៤ | សេចក្តីចម្លងសំបុត្រមណភាព | ៤០ | ១៦ | ១៣ | ៨៣ | ៣៨ | ១៩០ |

[៤៤] របាយការណ៍របស់ក្រុមប្រឹក្សាស្រុកមេមត់ អាណត្តិទី៣ ២០១៩-២០២៣, រដ្ឋបាលស្រុកមេមត់, បោះពុម្ព២០១៩

### ៣.៦.២. ការចេញលិខិតស្នាម និងឯកសារប្រជាពលរដ្ឋ

ក្នុងរយៈពេល៥ឆ្នាំនៃក្រុមប្រឹក្សាស្រុកមេមត់អាណត្តិទី៣ បានផ្តល់ឯកសារតម្រូវការជូនប្រជាពលរដ្ឋដើម្បីប្រើប្រាស់រួមមាន៖[៩៥]

- ផ្តល់សៀវភៅស្នាក់នៅ **ក២** បានចំនួន១០១១គ្រួសារ
- ផ្តល់សៀវភៅគ្រួសារ **ក៤** បានចំនួន ១០៨២ គ្រួសារ
- ផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរបានចំនួន ៧២៦២៣នាក់ ស្រី ១៧៣១៤នាក់

<u>តារាងទី១៖ លិខិតស្នាម និង ឯកសារប្រជាពលរដ្ឋ</u>

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | សរុប |
| ១ | ដីកាដែលបានដាក់ចេញ | ៨ | ២ | ១០ | ១៤ | ៦ | ៤០ |
| ២ | សេចក្តីសម្រេចដែលបានដាក់ចេញ | ៣៤ | ២៥ | ៣២ | ៦៧ | ៣១ | ១៨៩ |
| ៣ | លិខិតដែលបានដាក់ចេញ | ១៨៣៩ | ៤៩៨៤ | ១១៨០៤ | ១៩៥១៩ | ១៥៤៦ | ៣៩៦៨៧ |
| ៤ | លិខិតដែលបានទទួល | ១៩៥៥ | ៦៧២ | ១២៧៥ | ១៦១០ | ១៩៧៦ | ៧៤៨៨ |

### ៣.៦.៣. ការគ្រប់គ្រងប្រជាពលរដ្ឋ

ស្រុកមេមត់មានប្រជាជនសរុបប្រមាណ ២សែននាក់ដោយមានសរុបជាគ្រួសារ ៣៨៩៤៩គ្រួសារ ក្នុងនោះមានគ្រួសារបណ្តោះអាសន្ន ៤៦២គ្រួសារ និងប្រជាពលរដ្ឋជាស្ត្រីប្រមាណ ៨៤០៤៣នាក់ និងមានប្រជាពលរដ្ឋចំណាកស្រុកប្រមាណ ៧៤៣០នាក់។

[៩៥] របាយការណ៍របស់ក្រុមប្រឹក្សាស្រុកមេមត់ អាណត្តិទី៣ ២០១៩-២០២៣, រដ្ឋបាលស្រុកមេមត់, បោះពុម្ព២០១៩

តារាងទី២៖ ការគ្រប់គ្រងប្រជាពលរដ្ឋ

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | សរុបគ្រួសារ | ៣៨៩៥៩ |
| ២ | គ្រួសារអចិន្ត្រៃយ៍ | ៣៨៤៨២ |
| ៣ | គ្រួសារបណ្ដោះអាសន្ន | ៤៦២ |
| ៤ | ប្រជាពលរដ្ឋសរុប | ១៦៥២០៤ |
| ៥ | ប្រជាពលរដ្ឋជាស្ត្រី | ៨៤០៤៣ |
| ៦ | ប្រជាពលរដ្ឋដែលមានអាយុ១៨ឆ្នាំឡើង | ១០៤៩៩៣ |
| ៧ | ប្រជាពលរដ្ឋចំណាកស្រុក | ៧៤៣០ |

### ៣.៦.៤. ការផ្សព្វផ្សាយ ព័ត៌មាន ទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ

រដ្ឋបាលស្រុកមេមត់បានចូលរួមយ៉ាងពេញលេញក្នុងកិច្ចសហប្រតិបត្តការ ទាំងក្នុងស្រុកមេមត់ និងកិច្ចសហប្រតិបត្តការអន្តរជាតិ ទាំងផ្នែកសង្គមកិច្ច សេចដ្ឋកិច្ច និងបញ្ហានានា ដែលក្នុងនោះមានដូចជា៖ [៤១]

- អង្គការសួននៃក្តីសង្ឃឹម អង្គការរតនៈអន្តរជាតិនិងអង្គការមេត្រីអន្តរជាតិ បានសហការធ្វើសមាហរណកម្មជនរងគ្រោះ ដោយអំពើជួញដូរបានចំនួន ១នាក់ ភេទស
- កាកបាទក្រហមកម្ពុជាស្រុកមេមត់ ការងារអនុសាខាកាកបាទក្រហមកម្ពុជាស្រុកមេមត់ បានផ្តល់អំណោយមនុស្សធម៌ដល់គ្រួសាររងគ្រោះដោយអគ្គីភ័យចំនួន៥គ្រួសារ រងគ្រោះដោយខ្យល់កន្ត្រាក់៥គ្រួសារ និងរន្ទះបាញ់៥នាក់
- រងគ្រោះដោយទឹកជំនន់១០គ្រួសារ គ្រួសារមានជីវភាពខ្វះខាតជួបការលំបាក (ធ្វើចត្តាឡីស័ក) ៧៣ គ្រួសារ ចាស់ជរាគ្មានទីពឹង,គ្រួសារជួបការលំបាក,អ្នកជំងឺគ្មានទីពឹង,ស្ត្រីមេម៉ាយក្រីក្រ មាន កូនក្នុង

[៤១] របាយការណ៍របស់ក្រុមប្រឹក្សាស្រុកមេមត់ អាណត្តិទី៣ ២០១៩-២០២៣, រដ្ឋបាលស្រុកមេមត់, បោះពុម្ព២០១៩

បន្ទុក, និងកុមារកំព្រាចំនួន១៧គ្រួសារ។ ផ្តល់អំណោយមនុស្សធម៌ចូលរួមបុណ្យសពចំពោះ គ្រួសារមានជីវភាពក្រលំបាកចំនួន៤សព។

- កិច្ចសហប្រតិបត្តិការអន្តរជាតិ ស្រុកមេមត់ មានព្រំប្រទល់ជាប់ជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម ផ្នែកខាងត្បូងទល់នឹង ស្រុកតិនចូវ ស្រុកតិនបៀន ខេត្តតៃនិញ ផ្នែកខាងកើតទល់នឹង ស្រុកឡុកនិញ ខេត្តប៊ិញភឿក។មានរៀបចំកិច្ចប្រជុំរវាងស្រុកនិងស្រុក ក្នុង១ឆ្នាំមានការជួបប្រជុំ ៣ដង ដើម្បីផ្លាស់ប្តូរយោបល់ និងការទំនាក់ទំនងល្អ។ការអញ្ជើញ និងចូលរួមក្នុងកម្មវិធីបុណ្យ ប្រពៃណីជាតិ (បុណ្យចូលឆ្នាំ) ជូនវត្តុអនុសាវរីយ៍ក្នុងនាមអ្នកជិតខាងល្អ។

### ៣.៦.៥. ការងារគណៈអភិបាល

ក្នុងរយៈពេល៥ឆ្នាំនេះ ថ្នាក់ដឹកនាំស្រុកមានភាពមមាញឹកក្នុងសកម្មភាពការងារជាក់ស្តែងរួមមាន៖

**១. លោក ស្រេង លី អភិបាលស្រុក អនុវត្តការងារជាប្រចាំ ដូចជា៖**

- ដឹកនាំកិច្ចប្រជុំនានាក្នុងនាមរដ្ឋបាលស្រុកចំនួន ៨១លើក
- ចូលរួមក្នុងកម្មវិធីប្រជុំ កម្មវីធីទស្សនៈកិច្ចផ្សេងៗ ចំនួន ១២៦លើក
- ចូលរួមក្នុងកម្មវិធីនានា របស់ក្រុមប្រឹក្សាស្រុកអាណត្តិទី៣ ចំនួន ៥៣លើក
- សកម្មភាពចុះតាមមូលដ្ឋាននិងការសំណេះសំណាលជាមួយប្រជាពលរដ្ឋក្នុងសហគមន៍ចំនួន១៤៣លើក

**២. លោកស្រី ទី លីហ្វាន់ អភិបាលរងស្រុក អនុវត្តការងារជាប្រចាំដូចជា៖**

- ដឹកនាំកិច្ចប្រជុំនានាក្នុងនាមរដ្ឋបាលស្រុកចំនួន ១០លើក
- ចូលរួមក្នុងកម្មវិធីប្រជុំ កម្មវីធីទស្សនៈកិច្ចផ្សេងៗ ចំនួន ៧១លើក
- ចូលរួមក្នុងកម្មវិធីនានា របស់ក្រុមប្រឹក្សាស្រុកអាណត្តិទី៣ ចំនួន ៣៨លើក
- សកម្មភាពចុះតាមមូលដ្ឋាននិងការសំណេះសំណាលជាមួយប្រជាពលរដ្ឋក្នុងសហគមន៍ចំនួន ៦៦លើក

**៣.លោក ប៉ោ ផៀត អភិបាលរងស្រុក អនុវត្តការងារជាប្រចាំដូចជា៖**

- ដឹកនាំកិច្ចប្រជុំនានាក្នុងនាមរដ្ឋបាលស្រុកចំនួន ៣៣លើក
- ចូលរួមក្នុងកម្មវិធីប្រជុំ កម្មវីធីទស្សនៈកិច្ចផ្សេងៗ ចំនួន ៨៧លើក
- ចូលរួមក្នុងកម្មវិធីនានា របស់ក្រុមប្រឹក្សាស្រុកអាណត្តិទី៣ ចំនួន ៣៥ លើក

- សកម្មភាពចុះតាមមូលដ្ឋាននិងការសំណេះសំណាលជាមួយប្រជាពលរដ្ឋក្នុងសហគមន៍ ចំនួន ១០២លើក

**៤/ លោក ញឹក នៅ អភិបាលរងស្រុក អនុវត្តការងារជាប្រចាំដូចជា៖**

- ដឹកនាំកិច្ចប្រជុំនានាក្នុងនាមរដ្ឋបាលស្រុកចំនួន ១៥ លើក
- ចូលរួមក្នុងកម្មវិធីប្រជុំ កម្មវីធីទស្សនៈកិច្ចផ្សេងៗ ចំនួន ៧៧លើក
- ចូលរួមក្នុងកម្មវិធីនានា របស់ក្រុមប្រឹក្សាស្រុកអាណត្តិទី៣ចំនួន ៣៤លើក
- សកម្មភាពចុះតាមមូលដ្ឋាននិងការសំណេះសំណាលជាមួយប្រជាពលរដ្ឋក្នុងសហគមន៍ ចំនួន ៥៨លើក

**៥. លោក តាំង ម៉េងវ៉ាត់ អភិបាលរងស្រុក អនុវត្តការងារជាប្រចាំដូចជា៖**

- ដឹកនាំកិច្ចប្រជុំនានាក្នុងនាមរដ្ឋបាលស្រុកចំនួន ២៣លើក
- ចូលរួមក្នុងកម្មវិធីប្រជុំ កម្មវីធីទស្សនៈកិច្ចផ្សេងៗ ចំនួនៈ៧១ លើក
- ចូលរួមក្នុងកម្មវិធីនានា របស់ក្រុមប្រឹក្សាស្រុកអាណត្តិទី៣ ចំនួន ៤០លើក
- សកម្មភាពចុះតាមមូលដ្ឋាននិងការសំណេះសំណាលជាមួយប្រជាពលរដ្ឋក្នុងសហគមន៍ ចំនួន ៨៤លើក

**៦.លោក អ៊ុង សំអុល អភិបាលរងស្រុក អនុវត្តការងារជាប្រចាំដូចជា៖**

- ដឹកនាំកិច្ចប្រជុំនានាក្នុងនាមរដ្ឋបាលស្រុកចំនួន ១២លើក
- ចូលរួមក្នុងកម្មវិធីប្រជុំ កម្មវីធីទស្សនៈកិច្ចផ្សេងៗ ចំនួន ២៩លើក
- ចូលរួមក្នុងកម្មវិធីនានា របស់ក្រុមប្រឹក្សាស្រុកអាណត្តិទី៣ ចំនួន ៤លើក
- សកម្មភាពចុះតាមមូលដ្ឋាននិងការសំណេះសំណាលជាមួយប្រជាពលរដ្ឋក្នុងសហគមន៍ ចំនួន ១៧លើក

**៧. លោក ម៉ឺន សុភី អភិបាលរងស្រុក អនុវត្តការងារជាប្រចាំដូចជា៖**

- ដឹកនាំកិច្ចប្រជុំនានាក្នុងនាមរដ្ឋបាលស្រុកចំនួន ៦លើក
- ចូលរួមក្នុងកម្មវិធីប្រជុំ កម្មវីធីទស្សនៈកិច្ចផ្សេងៗ ចំនួន ១៦លើក
- ចូលរួមក្នុងកម្មវិធីនានា របស់ក្រុមប្រឹក្សាស្រុកអាណត្តិទី៣ ចំនួន ៤លើក

- សកម្មភាពចុះតាមមូលដ្ឋាននិងការសំណេះសំណាលជាមួយប្រជាពលរដ្ឋក្នុងសហគមន៍ ចំនួន ៧លើក

**៨. លោក ផៃ ច័ន្ទសុភី អភិបាលរងស្រុក បានធ្វើសកម្មភាព និងអនុវត្តការងារជាប្រចាំដូចជា៖**

- ដឹកនាំកិច្ចប្រជុំនានាក្នុងនាមរដ្ឋបាលស្រុកចំនួន ១លើក
- ចូលរួមក្នុងកម្មវិធីប្រជុំ កម្មវិធីទស្សនៈកិច្ចផ្សេងៗ ចំនួន ៤លើក
- ចូលរួមក្នុងកម្មវិធីនានា របស់ក្រុមប្រឹក្សាស្រុកអាណត្តិទី៣ ចំនួន ៦លើក
- សកម្មភាពចុះតាមមូលដ្ឋាន និងការសំណេះសំណាលជាមួយប្រជាពលរដ្ឋក្នុងសហគមន៍ ចំនួន ៣លើក។

តារាងទី៤៖ កិច្ចប្រជុំគណៈអភិបាល[៤៧]

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | សរុប |
| ១ | កិច្ចប្រជុំអឌ្ឍមាសរបស់គណៈអភិបាល | ៦ | ១២ | ១២ | ១២ | ១២ | ៥៩ |
| ២ | កិច្ចប្រជុំប្រចាំខែរបស់គណៈអភិបាល | ៨ | ១២ | ១២ | ១២ | ១២ | ៥៦ |

[៤៧] របាយការណ៍របស់ក្រុមប្រឹក្សាស្រុកមេមត់ អាណត្តិទី៣ ២០១៩-២០២៣, រដ្ឋបាលស្រុកមេមត់, បោះពុម្ព២០១៩

### ៣.៦.៦. ការងារក្រុមប្រឹក្សា និងគណៈកម្មាធិការនានា

ក្រុមប្រឹក្សាស្រុកមេមត់ និងគណៈកម្មាធិការ មានតួនាទីចូលរួមប្រជុំផ្សេងដូចជា កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាកិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា កិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ កិច្ចប្រជុំរបស់គណៈកម្មាធិការលទ្ធកម្ម។[៤៨]

តារាងទី៥៖ កិច្ចប្រជុំក្រុមប្រឹក្សាស្រុកមេមត់ និងគណៈកម្មាធិការនានា

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | សរុប |
| ១ | កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា | ១២ | ១១ | ១២ | ១២ | ១២ | ៥៩ |
| ២ | កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា | ៣ | ១ | ៣ | ២ | ៤ | ១៣ |
| ៣ | កិច្ចប្រជុំសម្ងាត់របស់ក្រុមប្រឹក្សា | ០ | ០ | ០ | ០ | ០ | ០ |
| ៤ | កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស | ០ | ០ | ០ | ០ | ០ | ០ |
| ៥ | កិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ | ០ | ០ | ៣ | ១២ | ១២ | ២៧ |
| ៦ | កិច្ចប្រជុំរបស់គណៈកម្មាធិការលទ្ធកម្ម | ១៦ | ១៣ | ១៦ | ១៦ | ១៦ | ៧៧ |

[៤៨] របាយការណ៍របស់ក្រុមប្រឹក្សាស្រុកមេមត់ អាណត្តិទី៣ ២០១៩-២០២៣, រដ្ឋបាលស្រុកមេមត់, បោះពុម្ព២០១៩

### ៣.៦.៧. ការរៀបចំវេទិកា

រដ្ឋបាលស្រុកមេមត់បានរៀបចំឱ្យមានវេទិការសាធាណៈ ដើម្បីលើកកម្ពស់ការឆ្លើយតបដល់តម្រូវការអាទិភាពរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន និងដើម្បីឆ្លើយតបនូវបញ្ហាកង្វល់សំណូមពរជូនប្រជាពលរដ្ឋឱ្យបានកាន់តែមានប្រសិទ្ធភាពក្នុងការដោះស្រាយ។[៥៩]

តារាងទី៦៖ ការរៀបចំវេទិការ

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | សរុប |
| ១ | ការរៀបចំវេទិកាសាធារណៈ | ១ | ១ | ០ | ១ | ១ | ៤ |
| ២ | ប្រជាពលរដ្ឋដែលបានចូលរួម | ៧២៨ | ១.២៤៨ | ០ | ១.៥៤៧ | ៤១៧ | ៣.២១២ |
| ៣ | ប្រជាពលរដ្ឋជាស្ត្រីដែលបានចូលរួម | ២០៥ | ១៨៥ | ០ | ២០២ | ៨១ | ៤៦៨ |

## ៣.៧. ចក្ខុវិស័យនាពេលអនាគត

នៅក្នុងស្រុកកម្មវិធីនៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០១៤-២០២៦)គឺដើម្បីឆ្លើយតបទៅនិងផែនការអភិវឌ្ឍក្នុងរយៈពេល៥ឆ្នាំ និងតម្រង់ទិសរដ្ឋបាលស្រុកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច នៅក្នុងមូលដ្ឋានដើម្បីលើកកម្ពស់គុណភាពសេវាកម្មកែលម្អជីវភាពរស់នៅ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ ឱ្យកាន់តែប្រសើរឡើងដែលសំដៅរួមចំណែកកាត់បន្ថយភាពក្រីក្រពីមួយឆ្នាំទៅមួយឆ្នាំ។ កម្មវិធីវិនិយោគបីឆ្នាំរំកិលនេះត្រូវបានចាប់ផ្ដើមអនុវត្តនៅពេលដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាស្រុកមេមត់ នាកិច្ចប្រជុំវិសាមញ្ញ ដែលគណៈអភិបាលស្រុកត្រូវធ្វើការផ្សព្វផ្សាយកម្មវិធីនេះដល់ប្រជាពលរដ្ឋ និងពាក់ព័ន្ធនានានៅក្នុងដែនសមត្ថកិច្ចដោយមានការសម្របសម្រួល និងកៀរគរធនធាននានាក្នុងការអនុវត្តកម្មវិធីនេះដើម្បីប្រកបដោយការចូលរួមតម្លាភាពគណនេយ្យភាពនិងមានប្រសិទ្ធភាពខ្ពស់។ ដោយកម្មវិធីនេះមានសារៈសំខាន់ចំពោះស្រុកមេមត់អភិបាលស្រុកនិងក្រុមប្រឹក្សាស្រុកជាមួយមន្ត្រីការិយាល័យជំនាញទាំង ១២ បានខិតខំចាប់ផ្ដើមរៀបចំអនុវត្តនូវកម្មវិធីនេះ

[៥៩] របាយការណ៍របស់ក្រុមប្រឹក្សាស្រុកមេមត់ អាណត្តិទី៣ ២០១៩-២០២៣, រដ្ឋបាលស្រុកមេមត់, បោះពុម្ព២០១៩

បន្ទាប់បានអនុម័តរួចរាល់នោះដើម្បី ធ្វើឱ្យស្រុកមេមត់ ទទួលបាននូវភាពរីកចម្រើន និងជឿនលឿន នាពេលខាងមុខជាពិសេស គឺអាចធ្វើឱ្យប្រជាជនទទួលបាននូវភាពធូរធារ និងរស់នៅយ៉ាងសុខសប្បាយដែលមានប្រាក់គ្រប់គ្រាន់ក្នុងការចំណាយផ្សេងៗនៅក្នុងគ្រួសារ។

## ៣.៨. បញ្ហាប្រឈមផ្សេង

រដ្ឋបាលស្រុក នៃអាណត្តិទី៣ របស់ក្រុមប្រឹក្សាស្រុកមេមត់ មានបញ្ហាប្រឈមនានា មួយចំនួនដូចជា ខ្វះមន្ត្រីសម្រាប់បំពេញការងារតាមការិយាល័យ អង្គភាពជំនាញសរុបចំនួន៤២នាក់ បច្ចុប្បន្នរដ្ឋ បាលស្រុកបានប្រើប្រាស់មន្ត្រីកិច្ចសន្យាចំនួន៣នាក់សម្រាប់ជួយការងាររដ្ឋបាល២នាក់និងការងារអនាម័យ១នាក់ តែប៉ុណ្ណោះមន្ត្រីរដ្ឋបាលស្រុកដែលកំពុងបម្រើការងារនៅរដ្ឋបាលស្រុកបច្ចុប្បន្នមិនសមមូលនិងទំហំការងារបច្ចុប្បន្នឡើយ។ ទន្ទឹមនឹងលទ្ធផលដែលទទួលបានខាងលើរដ្ឋបាលស្រុកក៏នៅមានបញ្ហាប្រឈម មួយចំនួនទៀតដែលដូចជា៖ ការងារក្រុមប្រឹក្សា ពុំទាន់មានទីកន្លែងធ្វើការងារ (មានតែប្រធាន ក្រុមប្រឹក្សា) ទើបរៀបចំកន្លែងថ្មី, ពុំមានថវិកាសម្រាប់ចុះប្រឹក្សាយោបល់ជាមួយក្រុមប្រឹក្សាឃុំ, ពុំមានថវិកា សម្រាប់ធ្វើវេទិកាផ្សព្វផ្សាយ និងថវិកាជាតិគាំទ្រការអភិវឌ្ឍន៍សមត្ថភាពដល់ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំនៅមាន កម្រិតនៅឡើយ។ ចំពោះសមត្ថភាពជំនាញ ចំណេះដឹងនៃក្រុមប្រឹក្សាគឺនៅមានកម្រិត ដោយសារពួកគាត់ត្រូវបាន ជ្រើសរើសធ្វើការបោះឆ្នោតអសកលចេញពីក្រុមប្រឹក្សាឃុំ ដែលមានទៅលើក្នុងមុខដំណែងគណៈបក្សនយោបាយតែ ប៉ុណ្ណោះ។

ដោយឡែកការងាររបស់គណៈអភិបាល មន្ត្រីបំពេញការងារ មិនបញ្ចេញឱ្យអស់លទ្ធភាពដោយសាខ្វះខាត ផ្នែកជីវភាពនិងឆន្ទៈ។ ការងារថវិកាជាកិច្ចការថ្មីសម្រាប់ស្រុកតែចំណេះដឹងមន្ត្រីបំពេញបំពេញការងារនេះនៅមាន កម្រិតមិនទាន់សមស្របទៅនឹងទំហំការងារបច្ចុប្បន្ន។ មន្ត្រីការិយាល័យជុំវិញស្រុកមានតិច (ភាគច្រើនមានតែ ១ ឬ២ នាក់) ខ្វះការិយាល័យបំពេញការងារ ហើយការផ្តល់របាយការណ៍របស់ការិយាល័យឃុំមួយចំនួនមានការយឺតយ៉ាវ។ ប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងបញ្ចូលទិន្នន័យក្នុងប្រព័ន្ធអេឡិចត្រូនិច (ព័ត៌មានវិទ្យា) តាមបណ្តាការិយាល័យ និងឃុំ មិនទាន់ប្រើប្រាស់បានធ្វើឱ្យជួបបញ្ហាក្នុងការប្រមូលទិន្នន័យ។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

យោងតាមការសិក្សាស្រាវជ្រាវនូវសាណារខាងលើទាក់ទងជាមួយនឹងប្រធានបទ "**ការគ្រប់គ្រងរដ្ឋបាលស្រុកមេមត់ ឆ្នាំ២០១៨-២០២៣**" នេះក្រុមរបស់យើងខ្ញុំពិតជាមានសេចក្តីសប្បាយរីករាយជាពន់ពេកព្រោះបានទទួលនូវចំណេះដឹងថ្មីៗបន្ថែមទាក់ទងនឹងដំណើរការ ការអនុវត្តការងារ និងបញ្ហាប្រឈមដែលរាំងស្ទះដល់ការអភិវឌ្ឍនៅក្នុងស្រុកមេមត់។

ជាក់ស្តែងការគ្រប់គ្រងស្រុកមេមត់ក្រុមរបស់យើងខ្ញុំបានសង្កេតឃើញថារដ្ឋបាលស្រុកបានយកចិត្តទុកដាក់ និងលើកកម្ពស់វិស័យសាធារណៈ និងធ្វើយ៉ាងណាដើម្បីឱ្យវិស័យនានានៅក្នុងស្រុកមានការរីកចម្រើនតួយ៉ាងដូចជា វិស័យអប់រំ ដែលមានការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការអប់រំកុមារតូច ការរៀបចំសាលាបឋមសិក្សា មធ្យមសិក្សា ការអប់រំកាយ កីឡា និងការបណ្តុះបណ្តាលបុគ្គលិក។ ចំពោះវិស័យសុខាភិបាលមានមណ្ឌលសុខភាពការដាក់ចេញនូវកម្មវិធីចម្បងបីរបស់សុខាភិបាលគឺការពិនិត្យផ្ទៃពោះ ការពន្យាកំណើតបញ្ហាជម្ងឺឆ្លងនិងជម្ងឺមិនឆ្លងព្រមទាំងបញ្ហាសុខភាពសាធារណៈ។ រីឯវិស័យកសិកម្មជាវិស័យដ៏សំខាន់ក្នុងការទ្រទ្រង់សេដ្ឋកិច្ចស្រុកទាំងមូល និងមានការផ្គត់ផ្គង់តម្រូវការក្នុងស្រុក និងនាំចេញទៅក្រៅស្រុកផងដែរ។ ជាពិសេសរដ្ឋបាលស្រុកមេមត់តែងតែខិតខំបង្កើននូវកិច្ចសហប្រតិបត្តិការជាមួយបណ្តាក្រុមហ៊ុនវិនិយោគ និងមន្ត្រីពាក់ពន្ធ័ដើម្បីធានាបានការរក្សាតម្លៃទីផ្សារលើកសិផលរបស់ប្រជាកសិករ និងបានរៀបចំផែនការវិនិយោគ និងការគាំទ្រឃុំលើផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងថវិកា។ ម៉្យាងទៀតរដ្ឋបាលស្រុកមេមត់បានយកចិត្តទុកដាក់ពាក់ព័ន្ធលើបញ្ហាព្រំដែន និងប្រជាពលរដ្ឋដែលរស់នៅតាមបណ្តោយព្រំដែន ដោយមានក្រុមការងារចុះល្បាតតាមខ្សែបន្ទាត់តាមព្រំដែនជាប់ជាប្រចាំតាមប៉ុស្តិ៍គោលដៅក្នុង ១ថ្ងៃចំនួន ២លើក។

សរុបសេចក្តីមកបានបង្ហាញឱ្យឃើញថាតាមរយៈការខិតខំប្រឹងប្រែងរបស់គណៈអភិបាលស្រុកអាជ្ញាធរគ្រប់លំដាប់ថ្នាក់ក៏ដូចជាការចូលរួមពីសំណាក់ប្រជាជននៅក្នុងស្រុកមេមត់ផ្ទាល់ទើបបណ្តាលឱ្យស្រុកមេមត់មានការរីកចម្រើនលូតលាស់យ៉ាងឆាប់រហ័សពីមួយឆ្នាំទៅមួយឆ្នាំប្រជាជនរស់នៅដោយជ្រកក្រោមម្លប់សន្តិភាព មិនមានភាពភ័យខ្លាច សុខសប្បាយទាំងផ្លូវកាយ និងផ្លូវចិត្ត មានការយល់ដឹង និងមានចំណេះជំនាញ ទើបធ្វើឱ្យស្រុកមេមត់មានការឈានទៅរកការកាត់បន្ថយភាពក្រីក្រ ដែលធ្វើឱ្យសេដ្ឋកិច្ចជាតិមានការអភិវឌ្ឍជាលំដាប់។

# អនុសាសន៍

# អនុសាសន៍

ឆ្លងតាមការបកស្រាយខាងលើក្រុមរបស់នាងខ្ញុំ/ខ្ញុំបាទបានសង្កេតឃើញថាស្រុកមេមត់ពិតជាមានការអភិវឌ្ឍនិងរីកចម្រើនយ៉ាងខ្លាំងដោយសារការខិតខំរបស់គណៈអភិបាលស្រុកមន្ត្រីនៅថ្នាក់ក្រោមជាតិ និងការសហការពីប្រជាពលរដ្ឋទើបធ្វើឱ្យស្រុកមេមត់ក្លាយជាស្រុកមួយដែលមានសក្ដានុពលទាំងផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងការងារផ្នែកសេវាសាធារណៈ។ ទាំងអស់នេះជាគោលនយោបាយនិងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលដែលលោកបានខិតខំប្រឹងប្រែងអភិវឌ្ឍប្រទេសដើម្បីឱ្យសេដ្ឋកិច្ចជាតិរីកចម្រើន បង្កើនសមត្ថភាពរបស់ប្រជាជនក្នុងការកាត់បន្ថយភាពក្រីក្រ។ ទន្ទឹមនឹងនេះទោះបីជាអគណៈអភិបាលស្រុកមេមត់ខិតខំប្រឹងប្រែងក្នុងការធ្វើឱ្យស្រុកមានការលូតលាស់រីកចម្រើនយ៉ាងណាក៏ដោយក្រុមនាង/ខ្ញុំបាទបានមើលឃើញនូវចំណុចខ្វះខាតមួយចំនួនដែលជាកត្តាធ្វើឱ្យការអភិវឌ្ឍស្រុកនូវមានភាពទន់ខ្សោយនិងមិនសូវមានប្រសិទ្ធភាព។ ជាគំនិតក៏ដូចជាសំណូមពរដើម្បីកែលម្អនូវចំណុចខ្វះខាតក្នុងនាមជាអ្នកសិក្សាសូមចូលរួមចំណែកបញ្ចេញជាមតិយោបល់ខ្លះៗដូចខាងក្រោម៖

- ការបើកវគ្គបណ្ដុះបណ្ដាលដល់មន្ត្រីរាជការគ្រប់ផ្នែកទាំងអស់ដើម្បីបង្កើនសមត្ថភាពឱ្យកាន់តែខ្លាំង
- ការត្រួតពិនិត្យ និងវាយតម្លៃការងាររបស់ បុគ្គលិក មន្ត្រីរាជការនៅតាមផ្នែកនីមួយៗជាប្រចាំ
- ការមានជាកញ្ចប់រង្វាន់សម្រាប់លើកទឹកចិត្តចំពោះ បុគ្គលិក មន្ត្រីរាជការណាដែលខិតខំធ្វើការ និងមានស្នាដៃល្អក្នុងការបំពេញការងារ
- ការបន្ថែមមន្ត្រីរាជការឱ្យសមស្របទៅនឹងទំហំការងារ ក្នុងការបម្រើការងារជូនប្រជាពលរដ្ឋ ក៏ដូចជាង្កើនប្រសិទ្ធភាពការងារបានឆាប់រហ័ស និងទាន់ពេលវេលា
- ពង្រឹងឥរិយាបទរបស់ បុគ្គលិក មន្ត្រីរាជការក្នុងការបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋ
- បង្កើន ក៏ដូចជាស្វែងរកថវិកាបន្ថែមអភិវឌ្ឍស្រុកដើម្បីឆ្លើយតបនឹងតម្រូវការ
- ពង្រឹងនិងរក្សាការពារសន្តិសុខជូនប្រជាពលរដ្ឋឱ្យបានខ្ជាប់ខ្ជួន
- ពង្រឹងនិងដាក់កំហិតខ្លាំងជាងមុនទៅលើជនទាំងឡាយណាដែលមិនគោរពច្បាប់ចរាចរណ៍ សេពគ្រឿងញៀន លេងល្បែងស៊ីសង ចោរកម្មនិងបង្កអសន្តិសុខផ្សេងៗនៅក្នុងសង្គម
- ពង្រឹង និងពង្រីកវិស័យអប់រំ ជាពិសេសអភិវឌ្ឍការសិក្សាតាមបែបឌីជីថលទៅតាមសាលារៀនដែលមានធនធាន និងសាងសង់អាគារសិក្សាបន្ថែមនៅតាមភូមិឃុំដែលនៅឆ្ងាយ
- បង្កើនកិច្ចសហប្រតិបត្តិការបន្ថែមដើម្បីជួយប្រជាពលរដ្ឋក្នុងការស្វែងរកទីផ្សារលក់ផលិតផលកសិកម្ម សិប្បកម្ម...។ល។

# ឯកសារយោង

# ឯកសារយោង


- ច្បាប់ស្តីពីការគ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខនស/រកម/០៥០៨/០១៧, ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨, មាត្រា១២
- ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ, លេខនស/រកម/០៦១១/០១១ អនុម័តថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១១
- អនុក្រឹត្យលេខ២១៦ អនក្រ ប.កចុះថ្ងៃទី១៤ ធ្នូ ឆ្នាំ២០០៩ ស្តីពី តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- អនុក្រឹត្យលេខ២៤០ អនក្រ ប.ក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅឱ្យគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ក្នុងការគ្រប់គ្រងបុគ្គលិកបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- អនុក្រឹត្យលេខ១៩ អនក្រ ប.ក ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ ២០១៧ ស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- អនុក្រឹត្យលេខ១៨៤ អនក្រ.បក,ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក
- **សម្តេចក្រឡាហោម ស ខេង**,. (២០១៨). *សៀវភៅប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា.* ភ្នំពេញៈ ក្រសួងមហាផ្ទៃ។
- **រដ្ឋលេខាធិការ សក់ សេដ្ឋា**,. (២០១៩). *សៀវភៅការគ្រប់គ្រងរដ្ឋបាលស្រុកតាមបែបវិមជ្ឈការ.* ភ្នំពេញ ក្រសួងមហាផ្ទៃៈ សាលាជាតិរដ្ឋបាលមូលដ្ឋាន។
- **សម្តេចក្រឡាហោម ស ខេង**,. (២០២៣). *សៀវភៅស្តីពីការគ្រប់គ្រងកិច្ចការរដ្ឋបាលរបស់រដ្ឋបាលក្រុង ស្រុក.* ភ្នំពេញ ក្រសួងមហាផ្ទៃៈ អគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ។
- **រដ្ឋបាលស្រុកមេមត់**,.(២០២២). *សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល ២០២២-២០២៤ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ.* មេមត់ៈ សាលាស្រុកមេមត់។
- **រដ្ឋបាលស្រុកមេមត់**,. (២០១៩). *របាយការណ៍របស់ក្រុមប្រឹក្សាស្រុកមេមត់ អាណត្តិទី៣ ២០១៩-២០២៣.* មេមត់ៈ សាលាស្រុកមេមត់។
- **រដ្ឋបាលស្រុកមេមត់**,.(២០២២). *សៀវភៅផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ ២០២២-២០២៤ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ.* មេមត់ៈ សាលាស្រុកមេមត់។
- **ក.យ៉ុង គីមឃី**, **ក.ជា លាងអេង**,. (២០២០) *ការគ្រប់រដ្ឋបាលស្រុកមេមត់.* ភ្នំពេញៈ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

- **ក. ឈៀង លីណា, ក.អឿន ស្រីនិច**,. (២០២២). *កំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការនៅប្រទេសកម្ពុជា.* ភ្នំពេញៈ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។
- **Fresh News,** (2019) *ស្វែងយល់អំពីតួនាទីដ៏សំខាន់របស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ* Available at: https://www.freshnewsasia.com/index.php/en/?ref=1 (Accessed 05 May 2024).
- **រដ្ឋបាលស្រុកអូរជ្រៅ**,. (២០២១) *ទំនាក់ទំនងរវាងក្រុមប្រឹក្សាស្រុក និងគណៈអភិបាលស្រុក* Available at: https://www.ouchrovbmc.gov.kh/ (Accessed: N/A).
- **រដ្ឋបាលស្រុលអូរជ្រៅ**,. (២០២១) *តួនាទី និងភារកិច្ចរបស់គណៈអភិបាលស្រុក* Available at: https://www.ouchrovbmc.gov.kh/ (Accessed: N/A).
- **អេង គីមហុង**,. (2024) *មានឈ្មួញធំៗឈរពីក្រោយការធ្វើអាជីវកម្មរ៉ែមាសជាលក្ខណៈគ្រួសារ* Available at: https://www.rfi.fr/km/ (Accessed: 01 January 2024).

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

## ១.ឧបសម្ព័ន្ធរូបភាព

**ឧបសម្ព័ន្ធទី១៖** ផែនទីស្រុកមេមត់ ខេត្តត្បូងឃ្មុំ។

**ឧបសម្ព័ន្ធទី២៖** ទិដ្ឋភាពទូទៅនៃស្រុកមេមត់។

**ឧបសម្ព័ន្ធទី៣៖** រដ្ឋបាលស្រុកមេមត់ រៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាស្រុក ចិតនៅបរិវេណវត្តបុព្វសុវណ្ណារាម ហៅវត្តដារ ឃុំដារ ស្រុកមេមត់។

**ឧបសម្ព័ន្ធទី៤៖** លោក ស្រេង លី អភិបាល នៃគណៈអភិបាលស្រុក អញ្ជើញចុះធ្វើការផ្សព្វផ្សាយស្តីពី យើងរួមគ្នាវិនិយោគការបង្ការ ទប់ស្កាត់ និងលើកកម្ពស់ការអប់រំ ដើម្បីសហគមន៍គ្មានគ្រឿងញៀន និងគ្មានក្មេង ទំនើង នៅវិទ្យាល័យប៊ុន រ៉ានីហ៊ុនសែនមេមត់។

**ឧបសម្ព័ន្ធទី៥៖** ទិដ្ឋភាព លោក ញឹក នៅ ប្រធានស.ស.យ.ក.ស្រុកមេមត់ និងអភិបាលរងស្រុក បាន អញ្ជើញជួបសំណេះសំណាលជាមួយសិស្សានុសិស្សនៃវិទ្យាល័យប៊ុន រ៉ានី ហ៊ុន សែន មេមត់ នៅសាលប្រជុំ វិទ្យាល័យប៊ុន រ៉ានី ហ៊ុន សែន មេមត់។

## ២.ឧបសម្ព័ន្ធគតិយុត្តិ

**ឧបសម្ព័ន្ធទី១៖** ច្បាប់ស្តីពីការគ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខនស/រកម/០៥០៨/០១៧, ចុះថ្ងៃទី២៨  ខែឧសភា ឆ្នាំ២០០៨។

**ឧបសម្ព័ន្ធទី២៖** អនុក្រឹត្យលេខ១៨៤ អនក្រ.បក,ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនា សម្ព័ន្ធរដ្ឋបាលស្រុក

# ឧបសម្ព័ន្ធរូបភាព

# ឧបសម្ព័ន្ធរូបភាព

## ឧបសម្ព័ន្ធទី១៖ ផែនទីស្រុកមេមត់ ខេត្តត្បូងឃ្មុំ




## ឧបសម្ព័ន្ធទី២៖ ទិដ្ឋភាពទូទៅនៃស្រុកមេមត់















ឧបសម្ព័ន្ធទី៣៖ រដ្ឋបាលស្រុកមេមត់ រៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាស្រុកចិតនៅបរិវេណវត្តបុព្វសុវណ្ណារាម ហៅវត្តដារ ឃុំដារ ស្រុកមេមត់។






ឧបសម្ព័ន្ធទី៤៖ លោក ស្រេង លី អភិបាល នៃគណៈអភិបាលស្រុក អញ្ជើញចុះធ្វើការផ្សព្វផ្សាយស្តីពីយើងរួមគ្នាវិនិយោគការបង្ការ ទប់ស្កាត់ និងលើកកម្ពស់ការអប់រំ ដើម្បីសហគមន៍គ្មានគ្រឿងញៀន និងគ្មានក្មេងទំនើង នៅវិទ្យាល័យប៊ុន រ៉ានីហ៊ុនសែនមេមត់។











ឧបសម្ព័ន្ធទី៥៖ ទិដ្ឋភាព លោក ញ៉ឹក នៅ ប្រធានស.ស.យ.ក.ស្រុកមេមត់ និងអភិបាលរង ស្រុក បានអញ្ជើញជួបសំណេះសំណាលជាមួយសិស្សានុសិស្សនៃវិទ្យាល័យប៊ុន រ៉ានី ហ៊ុន សែន មេមត់ នៅសាលប្រជុំវិទ្យាល័យប៊ុន រ៉ានី ហ៊ុន សែន មេមត់។







# ឧបសម្ព័ន្ធគតិយុត្តិ

# ព្រះរាជក្រម

នស/រកម/០៥០៨/០១៧

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានអនុម័តកាលពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំរដ្ឋសភា លើកទី ៧ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ ២០០៨ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី ៤ នីតិកាលទី ២ ហើយក្រុមប្រឹក្សាធម្មនុញ្ញបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមរយៈសេចក្តីសម្រេចលេខ០៩៦/០០១/២០០៨ កបធ.ចចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០០៨ ដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

ROYAUME DU CAMBODGE
MINISTERE DU PALAIS ROYAL

# ច្បាប់

# ស្តីពី

# ការគ្រប់គ្រងរដ្ឋបាល

# រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី ១
# អំពីបទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងកំណត់ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ២.-**

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាព ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ តាមរយៈនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ។

**មាត្រា ៣.-**

ឃុំ សង្កាត់ត្រូវគ្រប់គ្រងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ លើកលែងតែបញ្ហាទាំងឡាយណាដែលបានចែងក្នុងច្បាប់នេះ ។

**មាត្រា ៤.-**

ភ្នំពេញ ជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា ។

រាជធានីភ្នំពេញ ចែកជាខណ្ឌ ។

ខណ្ឌ ចែកជាសង្កាត់ ។

**មាត្រា ៥.-**

ខេត្ត ចែកជាក្រុង និងជាស្រុក ។

ក្រុង ចែកជាសង្កាត់ ។

ស្រុក ចែកជាឃុំ និងជាសង្កាត់ ។

**មាត្រា ៦.-**

ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់ និងការកំណត់ឈ្មោះខេត្ត ត្រូវសម្រេចដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្តីស្នើសុំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ការកំណត់ព្រំប្រទល់រាជធានីភ្នំពេញ ត្រូវសម្រេចដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្តីស្នើសុំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៧.-**

ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់ និងការកំណត់ឈ្មោះក្រុង ស្រុក ខណ្ឌ ត្រូវសម្រេចដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៨.-**

ការបង្កើតរដ្ឋបាលឯកភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ គឺសំដៅដល់ការពង្រឹងអង្គឯកភាពរបស់រដ្ឋ ដើម្បីសម្របសម្រួលនូវរាល់សកម្មភាពរដ្ឋបាលសាធារណៈនៅក្នុងដែនដីរបស់ខ្លួន ។

**មាត្រា ៩.-**

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជានីតិបុគ្គលនៃនីតិសាធារណៈ ។

**មាត្រា ១០.-**

នីតិបុគ្គលនីមួយៗ ត្រូវមានក្រុមប្រឹក្សាមួយជាតំណាងដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើង ស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ។

**មាត្រា ១១.-**

នីតិបុគ្គលនីមួយៗត្រូវបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

**មាត្រា ១២.-**

ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យរួមមាន :

-ភាពជាតំណាងសាធារណៈ

-ស្វ័យភាពរបស់មូលដ្ឋាន

-ការពិគ្រោះយោបល់ និងការចូលរួម

-ការឆ្លើយតប និងគណនេយ្យភាព

-ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជននៅក្នុងមូលដ្ឋាន

-ការលើកស្ទួយសមធម៌

-តម្លាភាព និងសុចរិតភាព

-វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច ។

**មាត្រា ១៣.-**

នីតិបុគ្គលទទួលសិទ្ធិអំណាចរបស់ខ្លួន ដោយរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានដទៃទៀត ដែលស្របនឹងច្បាប់នេះ ។

## ជំពូកទី ២
## អំពីក្រុមប្រឹក្សា

### ផ្នែកទី ១
### ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**មាត្រា ១៤.-**

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវមានក្រុមប្រឹក្សារបស់ខ្លួន ដែលត្រូវបានជ្រើសរើសឡើង តាមការបោះឆ្នោតអសកល ស្របតាមនីតិវិធីដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលហៅកាត់ថា “ក្រុមប្រឹក្សា” ។

**មាត្រា ១៥.-**

ក្រុមប្រឹក្សាមានអាណត្តិប្រាំ(០៥)ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលក្រុមប្រឹក្សាថ្មីចូលកាន់តំណែង ។

អាណត្តិរបស់ក្រុមប្រឹក្សា ត្រូវគិតចាប់ពីថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងផុតកំណត់នៅថ្ងៃបោះឆ្នោតបន្ទាប់ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

**មាត្រា ១៦.–**

ក្នុងពេលរង់ចាំក្រុមប្រឹក្សាថ្មីចូលកាន់មុខតំណែង ក្រុមប្រឹក្សាដែលចប់អាណត្តិមានសិទ្ធិអនុវត្តតែកិច្ចការរដ្ឋបាលប្រចាំថ្ងៃតែប៉ុណ្ណោះ ។

**មាត្រា ១៧.–**

ក្រុមប្រឹក្សានីមួយៗ ត្រូវមានប្រធានម្នាក់ ។

ប្រធានក្រុមប្រឹក្សា គឺជាបេក្ខជនដែលស្ថិតនៅលំដាប់លេខរៀងលើគេនៃបញ្ជីបេក្ខជនដែលមានអាសនៈច្រើនជាងគេ នៅក្នុងក្រុមប្រឹក្សា ។

ក្នុងករណីដែលបញ្ជីបេក្ខជនមានអាសនៈស្មើគ្នានៅក្នុងក្រុមប្រឹក្សា ប្រធានក្រុមប្រឹក្សា ត្រូវជ្រើសរើសយកបេក្ខជន ដែលមានលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលមានសំឡេងឆ្នោតបានការច្រើនជាងគេ ។

**មាត្រា ១៨.–**

ចំនួនសមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ដោយផ្អែកតាមកត្តាប្រជាសាស្ត្រនិងកត្តាភូមិសាស្ត្រ ដូចខាងក្រោម :

-ក្រុមប្រឹក្សារាជធានីភ្នំពេញ មានចំនួនសមាជិកមិនលើសពីម្ភៃមួយ(២១)រូប

-ក្រុមប្រឹក្សាខេត្ត មានចំនួនសមាជិកពីប្រាំបួន(០៩)រូប ដល់ម្ភៃមួយ(២១)រូប

-ក្រុមប្រឹក្សាក្រុង មានចំនួនសមាជិកពីប្រាំពីរ(០៧)រូប ដល់ដប់ប្រាំ(១៥)រូប

-ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ មានចំនួនសមាជិកពីប្រាំពីរ(០៧)រូប ដល់ដប់ប្រាំបួន(១៩)រូប ។

ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងរយៈពេលយ៉ាងតិចមួយរយម្ភៃ (១២០)ថ្ងៃ មុនពេលផុតកំណត់អាណត្តិរបស់ក្រុមប្រឹក្សា ។

ក្នុងករណីគ្មានអនុក្រឹត្យ ចែងអំពីចំនួនសមាជិកក្រុមប្រឹក្សាអាណត្តិបន្ទាប់ទេនោះ ចំនួនសមាជិកសរុបរបស់ក្រុមប្រឹក្សា សម្រាប់ក្រុមប្រឹក្សានីមួយៗ ត្រូវយកតាមចំនួនសរុប ក្រុមនៃក្រុមប្រឹក្សាអាណត្តិចាស់ ។

**មាត្រា ១៣៩.-**

គណៈអភិបាលរួមមាន ប្រធានមួយរូប ដែលហៅថា អភិបាល និងអភិបាលរងមួយចំនួន ។

**មាត្រា ១៤០.-**

គណៈអភិបាលរាជធានីភ្នំពេញមានចំនួនយ៉ាងច្រើនប្រាំពីរ(០៧)រូប ។

គណៈអភិបាលខេត្តមានចំនួនពីបី(០៣)រូប ទៅប្រាំពីរ(០៧)រូប ។

គណៈអភិបាលក្រុង ស្រុក ខណ្ឌមានចំនួនពីបី(០៣)រូប ទៅប្រាំ(០៥)រូប ។

ចំនួនជាក់ស្តែងនៃគណៈអភិបាល សម្រាប់ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ១៤១.-**

អភិបាលរាជធានី អភិបាលខេត្ត ត្រូវតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្តីស្នើសុំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

អភិបាលរងរាជធានី អភិបាលរងខេត្ត អភិបាលក្រុង អភិបាលស្រុក អភិបាលខណ្ឌ ត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

អភិបាលរងក្រុង អភិបាលរងស្រុក អភិបាលរងខណ្ឌ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ១៤២.-**

អភិបាលរាជធានី អភិបាលខេត្ត ត្រូវជ្រើសរើសពីក្នុងចំណោមមន្ត្រីទាំងពីរភេទ ដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ដែលមានលក្ខណសម្បត្តិដូចខាងក្រោម :

-មានឋានន្តរសក្តិឧត្តមមន្ត្រី

-មានអាយុចាប់ពីសាមសិបប្រាំ(៣៥)ឆ្នាំឡើង គិតដល់ថ្ងៃតែងតាំង

-មានបទពិសោធន៍ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចចំនួនប្រាំពីរ(០៧) ឆ្នាំ ឬ/និងមានសញ្ញាបត្របរិញ្ញាបត្រដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា

## ផ្នែកទី ២

## នាយករដ្ឋបាល

**មាត្រា ១៨៣.-**

ក្រុមប្រឹក្សានីមួយៗ ត្រូវមាននាយករដ្ឋបាលមួយរូបដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ១៨៤.-**

នាយករដ្ឋបាល មានតួនាទីជាជំនួយការក្នុងការចាត់ចែងកិច្ចការរដ្ឋបាល និងធានានិរន្តរភាពកិច្ចការរដ្ឋបាលប្រចាំថ្ងៃរបស់ក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន ។

ក្នុងតួនាទីខាងលើនេះ នាយករដ្ឋបាលត្រូវធ្វើសេចក្ដីរាយការណ៍ និងមានគណនេយ្យភាព ចំពោះក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន ។

**មាត្រា ១៨៥.-**

នាយករដ្ឋបាល មានតួនាទី ភារកិច្ចដូចខាងក្រោម :

-អនុវត្តកិច្ចការប្រចាំថ្ងៃរបស់ក្រុមប្រឹក្សា និងគណៈអភិបាល

-ធានាឱ្យអង្គភាព បុគ្គលិករបស់ក្រុមប្រឹក្សា អនុវត្តសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន

-អនុវត្តដីការបស់ក្រុមប្រឹក្សា

-ចូលរួម និងមានយោបល់រាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា គណៈកម្មាធិការរបស់ក្រុមប្រឹក្សា និងគណៈអភិបាល ប៉ុន្តែពុំមានសិទ្ធិបោះឆ្នោតបានឡើយ

-ផ្ដល់យោបល់ដល់ក្រុមប្រឹក្សា ដល់គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា ដើម្បីក្រុមប្រឹក្សាសម្រេចបាននូវគោលបំណងក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

-ផ្ដល់យោបល់ដល់គណៈអភិបាល ដើម្បីគណៈអភិបាលអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ត្រូវពិនិត្យឡើងវិញនូវច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងលិខិតបទដ្ឋានពាក់ព័ន្ធ ដើម្បីស្នើធ្វើវិសោធនកម្ម ឬ ដាក់ចេញនូវលិខិតបទដ្ឋានថ្មី ឱ្យសមស្របសម្រាប់ទ្រទ្រង់ដល់គោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យដែលចែងក្នុងច្បាប់នេះ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ២៨៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២៨៦.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី២៤ ខែឧសភាឆ្នាំ ២០០៨

ពរល.០៥០៥.៥៩៩

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
**ហត្ថលេខា**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ហត្ថលេខា**

**ស ខេង**

លេខ: ៥៥៦ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ,ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០០៨
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៩៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## មុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

- បានឃើញអនុក្រឹត្យលេខ១៩១ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការប្រគល់មុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធឱ្យទៅដល់រដ្ឋបាលក្រុង ស្រុក
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងលើកកម្ពស់ប្រសិទ្ធភាពក្នុងការគ្រប់គ្រងរដ្ឋបាល ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាននៅថ្នាក់ស្រុក។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីមុខងារ រចនាសម្ព័ន្ធ តួនាទី ភារកិច្ច ទំនាក់ទំនងការងារ និងគណនេយ្យភាពរបស់រដ្ឋបាលស្រុក។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះរដ្ឋបាលស្រុកទូទាំងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## មុខងាររបស់រដ្ឋបាលស្រុក

**មាត្រា ៤.-**

រដ្ឋបាលស្រុកត្រូវបំពេញមុខងារតាមការកំណត់នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមុខងារដែលបានផ្ទេរពីរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់។

មុខងារពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានក្នុងវិស័យនីមួយៗត្រូវបានប្រគល់ និងប្រតិភូកម្មទៅឱ្យរដ្ឋបាលស្រុកដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ លើកលែងតែមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡារបស់រដ្ឋបាលស្រុកនានានៃខេត្តបាត់ដំបងមានចែងក្នុងជំពូកទី៧នៃអនុក្រឹត្យនេះ។

ក្រៅពីមុខងារដែលបានកំណត់ក្នុងវាក្យខណ្ឌទី១ និងវាក្យខណ្ឌទី២នៃមាត្រានេះ រដ្ឋបាលស្រុកបំពេញមុខងារជាភ្នាក់ងាររបស់ក្រសួង ស្ថាប័ន រដ្ឋបាលខេត្ត មន្ទីរ និងអង្គភាពនានាតាមការកំណត់ដោយលិខិតបទដ្ឋានគតិយុត្តជាធរមាន ឬតាមកិច្ចព្រមព្រៀងរវាងក្រសួង ស្ថាប័ន រដ្ឋបាលខេត្ត មន្ទីរ និងអង្គភាពនានាជាមួយរដ្ឋបាលស្រុក។

**មាត្រា ៥.-**

មុខងារផ្តល់សេវាសាធារណៈ និងអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលស្រុករួមមានមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើស។

រដ្ឋបាលស្រុកត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាកាតព្វកិច្ចនានាដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយផ្អែកតាមគោលការណ៍ នីតិវិធី ស្តង់ដាសេវា និងធនធានដែលបានផ្ទេរមានភ្ជាប់លក្ខខណ្ឌ ព្រមទាំងអាចប្រើប្រាស់ធនធានរបស់ខ្លួន ឬធនធានដែលគៀរគរបានពីប្រភពស្របច្បាប់ផ្សេងទៀត ដើម្បីអនុវត្តមុខងារជាកាតព្វកិច្ចទាំងនោះឱ្យកាន់តែមានប្រសិទ្ធភាព។

គោលការណ៍ នីតិវិធី និងស្តង់ដាសេវាសម្រាប់គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាកាតព្វកិច្ចត្រូវរៀបចំ និងកំណត់ដោយក្រសួង ស្ថាប័ននៃវិស័យនីមួយៗ។

**មាត្រា ៦.-**

រដ្ឋបាលស្រុកមានស្វ័យភាពក្នុងការសម្រេចជ្រើសរើស ឬមិនជ្រើសរើសយកមុខងារជាជម្រើសណាមួយមកអនុវត្ត ផ្អែកតាមតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

រដ្ឋបាលស្រុកត្រូវគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើសក្នុងកម្រិតអតិបរមានៃលទ្ធភាព និងធនធានឆន្ទានុសិទ្ធិរបស់ខ្លួន និងធនធានដែលរដ្ឋបាលស្រុកគៀរគរបានពីប្រភពស្របច្បាប់។

រដ្ឋបាលស្រុកមានសិទ្ធិសម្រេចអំពីរបៀបគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើសដោយអនុលោមតាមបទដ្ឋាន និងនីតិវិធីដែលមានចែងក្នុងច្បាប់ ឬព្រះរាជក្រឹត្យ ឬអនុក្រឹត្យ ឬប្រកាស ឬលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ក្នុងករណីដែលរដ្ឋបាលស្រុកសម្រេចក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើសដែលមិនធ្លាប់បានគ្រប់គ្រង ចាត់ចែង និងអនុវត្តពីមុនមកដោយក្រសួង ស្ថាប័ន រដ្ឋបាលស្រុកមានសិទ្ធិសម្រេច ឬស្នើសុំមកក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីកំណត់អំពីបទដ្ឋាន នីតិវិធី និងធនធានសម្រាប់គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារទាំងនោះ។

ក្រសួង ស្ថាប័នអាចផ្តល់ការណែនាំ ការគាំទ្រ និងឬធនធានទៅឱ្យរដ្ឋបាលស្រុកសម្រាប់គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើស។

**មាត្រា ៧.-**

ក្រសួង ស្ថាប័ន និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ត្រូវពិនិត្យមើលឡើងវិញនូវមុខងារនានារបស់ខ្លួនដើម្បីបន្តផ្ទេរមុខងារសមស្របទៅឱ្យរដ្ឋបាលស្រុក ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល។

## ផ្នែកទី២

## តួនាទី ភារកិច្ចរបស់ការិយាល័យ និងអង្គភាពនានាចំណុះរដ្ឋបាលស្រុក

**មាត្រា ១៥.-**

**ការិយាល័យរដ្ឋបាល** និងហិរញ្ញវត្ថុត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលស្រុកលើការងាររដ្ឋបាល និងហិរញ្ញវត្ថុ និងមានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម៖

- ការងាររដ្ឋបាល លិខិតស្នាមផ្សេងៗ ព័ត៌មាន ពិធីការ ទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ
- ការងារអគ្រានុកូលដ្ឋាន
- ការគ្រប់គ្រង និងការថែរក្សាត្រា ឯកសារ លិខិតបទដ្ឋាននានារបស់រដ្ឋបាលស្រុក
- ការពិនិត្យ និងការកែសម្រួលរចនាសម្ព័ន្ធរបស់រដ្ឋបាលស្រុក
- ការរៀបចំនីតិវិធីរដ្ឋបាល និងនីតិវិធីហិរញ្ញវត្ថុសម្រាប់អង្គភាពរបស់រដ្ឋបាលស្រុកផ្អែកតាមគោលការណ៍ និងបទប្បញ្ញត្តិជាធរមាន
- ការងារហិរញ្ញវត្ថុ ថវិកា និងទ្រព្យសម្បត្តិរបស់រដ្ឋបាលស្រុក
- ការងារសណ្តាប់ធ្នាប់សាធារណៈ
- ការងាររបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ និងរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋបាលស្រុក
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលស្រុក។

**មាត្រា ១៦.-**

**អង្គភាពលទ្ធកម្ម**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលស្រុកលើការងារលទ្ធកម្មសាធារណៈ និងមានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម៖

- ការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ
- ការរៀបចំឯកសារដេញថ្លៃ ការរៀបចំ និងការផ្សព្វផ្សាយអំពីកិច្ចលទ្ធកម្ម ការផ្តល់ឯកសារដេញថ្លៃ ការទទួលសំណើដេញថ្លៃ ការរៀបចំទុកដាក់ឯកសារសំណើដេញថ្លៃ ការរៀបចំទីកន្លែង និងការរៀបចំបើកសំណើដេញថ្លៃ
- ការរៀបចំរបាយការណ៍ និងកំណត់ហេតុស្តីពីការបើកសំណើដេញថ្លៃ
- ការរៀបចំ និងការសម្របសម្រួលក្នុងការវាយតម្លៃលើបច្ចេកទេសនៃសំណើដេញថ្លៃ
- ការរៀបចំកិច្ចសន្យា និងលិខិតជូនដំណឹងអំពីការប្រគល់កិច្ចសន្យា
- ការផ្សព្វផ្សាយលទ្ធផលនៃការដេញថ្លៃ
- ការតាមដានការអនុវត្តកិច្ចសន្យា និងការរៀបចំរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្ម
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលស្រុក។



k

**មាត្រា ១៧.-**

**ការិយាល័យគ្រប់គ្រងធនធានមនុស្ស**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលស្រុកលើការងារគ្រប់គ្រងធនធានមនុស្ស និងមានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម៖

- ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់បុគ្គលិករបស់រដ្ឋបាលស្រុក
- ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាពបុគ្គលិករបស់រដ្ឋបាលស្រុក
- ការគ្រប់គ្រងបុគ្គលិកផ្សេងទៀតតាមការផ្ទេរសិទ្ធិអំណាចពីរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ន
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលស្រុក។

**មាត្រា ១៨.-**

**ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលស្រុកលើការងារផែនការ និងគាំទ្រឃុំ សង្កាត់ក្នុងស្រុក និងមានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម៖

- ការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍន៍ប្រាំ(០៥)ឆ្នាំ កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិល ផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ និងគម្រោងអភិវឌ្ឍន៍នានារបស់រដ្ឋបាលស្រុក
- ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តផែនការអភិវឌ្ឍន៍ប្រាំ(០៥)ឆ្នាំ កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិល ផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ និងគម្រោងអភិវឌ្ឍន៍នានារបស់រដ្ឋបាលស្រុក
- ការងារស្ថិតិប្រជាជន
- ការគាំទ្រ ការសម្របសម្រួល និងការតាមដាន ត្រួតពិនិត្យ វាយតម្លៃរដ្ឋបាលឃុំ សង្កាត់ក្នុងស្រុកលើការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍន៍ប្រាំ(០៥)ឆ្នាំ កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិល និងគម្រោងនានារបស់រដ្ឋបាលឃុំ សង្កាត់ក្នុងស្រុក
- ការណែនាំ និងការជំរុញការប្រមូលទិន្នន័យមូលដ្ឋានឃុំ សង្កាត់ និងទិន្នន័យថ្នាក់ស្រុកតាមការកំណត់
- ការគ្រប់គ្រង និងការស្វែងរកការគាំទ្រការកែច្នៃទិន្នន័យមូលដ្ឋានឃុំ សង្កាត់ និងទិន្នន័យថ្នាក់ស្រុក
- ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាពបុគ្គលិក និងក្រុមប្រឹក្សាឃុំ សង្កាត់តាមតម្រូវការចាំបាច់
- ការគាំទ្របច្ចេកទេសលើការងាររដ្ឋបាល និងហិរញ្ញវត្ថុដល់រដ្ឋបាលឃុំ សង្កាត់
- ការដោះស្រាយសំណើ សំណូមពរ និងបញ្ហាប្រឈមនានារបស់រដ្ឋបាលឃុំ សង្កាត់
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលស្រុក។

**មាត្រា ១៩.-**

**ការិយាល័យត្រួតពិនិត្យផ្ទៃក្នុង**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលស្រុកលើការត្រួតពិនិត្យការបំពេញការងាររបស់ការិយាល័យ និងអង្គភាពនានាចំណុះរដ្ឋបាលស្រុក និងមានភារកិច្ចចាត់ចែង

- ការរៀបចំមុខតំណែងប្រធាន និងអនុប្រធាននៃការិយាល័យផ្សេងទៀតក្រៅពីការិយាល័យ និងអង្គភាពដូចបានកំណត់ក្នុងចំណុចត្រេទាំង៤ខាងលើនៃមាត្រានេះត្រូវជ្រើសរើសចេញពីប្រធាន ឬអនុប្រធានការិយាល័យនានាដែលត្រូវបានធ្វើសមាហរណកម្មបញ្ចូលមកក្នុងរចនាសម្ព័ន្ធថ្មី។ ការរៀបចំមុខតំណែងទាំងនេះត្រូវផ្អែកលើសមត្ថភាព ចំណេះដឹង ជំនាញ និងបទពិសោធន៍ការងារ
- បុគ្គលិកដែលត្រូវបានផ្ទេរពីការិយាល័យជំនាញនានាត្រូវរៀបចំបញ្ចូលទៅក្នុងការិយាល័យដែលពាក់ព័ន្ធនឹងវិស័យជំនាញរបស់ខ្លួន
- ក្នុងករណីមុខងារនៃវិស័យណាមួយដែលបានផ្ទេរមក ហើយពុំមានបុគ្គលិកត្រូវបានផ្ទេរមកជាមួយ រដ្ឋបាលស្រុកត្រូវរៀបចំឱ្យមានបុគ្គលិកទទួលខុសត្រូវលើមុខងារនោះ។ ក្នុងករណីនេះ ក្រសួង ស្ថាប័ននៃវិស័យជំនាញត្រូវផ្តល់ការបណ្តុះបណ្តាលជាបន្ទាន់ដល់មន្ត្រីទាំងនោះ។

**មាត្រា ៧៦.-**

គ.ជ.អ.ប. ដោយមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានាត្រូវសម្រេចអំពីការរៀបចំផ្ទេរបុគ្គលិក និងមុខតំណែងគ្រប់គ្រងតាមការិយាល័យ និងអង្គភាពនានាចំណុះរដ្ឋបាលស្រុកក្នុងដំណាក់កាលសមាហរណកម្មនេះ។

ក្រោយពេលធ្វើសមាហរណកម្ម ការតែងតាំង និងការបញ្ចប់មុខតំណែងនានានៃការិយាល័យ និងអង្គភាពចំណុះរដ្ឋបាលស្រុកត្រូវអនុវត្តតាមគោលការណ៍ នីតិវិធី និងបែបបទនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិជាធរមាន។

គ.ជ.អ.ប. អាចបង្កើតក្រុមការងារអន្តរក្រសួងមួយដែលមានសមាសភាពមកពីក្រសួងមហាផ្ទៃ ក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លេខាធិការដ្ឋានគ.ជ.អ.ប. និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា ដើម្បីជួយដល់គ.ជ.អ.ប. ក្នុងការរៀបចំកិច្ចការទាំងនេះ។

**មាត្រា ៧៧.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយមានកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រោមការសម្របសម្រួលរបស់គ.ជ.អ.ប. ត្រូវកំណត់ទំហំធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ ដើម្បីផ្ទេរទៅឱ្យរដ្ឋបាលស្រុកសម្រាប់គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារនានាដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី៤នៃអនុក្រឹត្យនេះចាប់ពីខែមករា ឆ្នាំ២០២០តទៅ។

## ជំពូកទី៩

## អវសានប្បញ្ញត្តិ

**មាត្រា ៧៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៧៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត ក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ...ច័ន្ទ ៦ កើត...ខែ...មិគសិរ... ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...២......ខែ...ធ្នូ.......ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមមេត្តាចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៧៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ